ម.ឌុខ សៅ សុវណ្ណ
ប្រមូលរៀបរៀង

# ទទឹមឃ្លុំមុំតំក្កហា

## បុប្ផា~ទិសឃ្នា

គ្រប់ទិដ្ឋភាព បញ្ហា

៙ ពីលំបាកមកងាយ

៙ ពីពាក់ចូលទៅក្រៅ

៙ អនុលោម បដិលោម

ការផ្សាយ
មូលមិត្ត បណ្ណាគារផ្សារចាស់

១៩៧០

ផ្សាយចេញពី

www.haotrai.com

ចែកជាធម្មទានដោយ

MEKONGNET
CONNECTING YOU ALL

ANANA
Computer
Trusted Service & Quality

# ប្រស្នាអភិធម្មសង្គហ

ស. បុព្វនិមិត្តទាំង ៣ នោះ បានដល់ធម៌ដូចម្តេច ?

ឆ. កម្មនោះ បានដល់កុសល, អកុសល ដែលសត្វសន្សំធ្វើដោយកាយវាចាចិត្ត ក្នុងជាតិនេះ ។ កាលបើមានជម្ងឺឈឺជិតនឹងស្លាប់ ក៏រលឹកនឹកនូវកុសលនឹងអកុសលទាំងពួង ។ កាលបើរលឹកដល់កុសល ៗ ក៏នាំឲ្យបដិសន្ធិក្នុងសុគតិ ។ កម្មនិមិត្តនោះ បានដល់កុសលអកុសលដ៏ទៀវិញ មកបណ្តាលឲ្យកើតក្នុងមនោទ្វារ, បើជាចំណែកកុសល ក៏ឲ្យឃើញនិមិត្តល្អ គឺឃើញព្រះពុទ្ធរូប, ព្រះចេតិយ, ភិក្ខុសាមណេរជាដើម បើជាចំណែកអកុសល ក៏ឃើញនិមិត្តអាក្រក់ មានសត្វផ្សេង ៗ ដែលខ្លួនបានសម្លាប់អំពីមុន មកប្រាកដឲ្យឃើញក្នុងមនោទ្វារ សេចក្តីដែលឃើញនូវនិមិត្តដូចម្តេចដែលកើតក្នុងមនោទ្វារ ក៏បង្អោនចិត្តកាន់យកនូវនិមិត្តនោះជាអារម្មណ៍ ទើបនាំឲ្យបដិសន្ធិវិញ្ញាណតាមយថាកម្ម ដែលជាកុសលនឹងអកុសល ។

គតិនិមិត្តនោះ បំណែកខាងកុសល គឺបានឃើញវិមានមាសវិមានប្រាក់ជាដើម កើតប្រាកដក្នុងមនោទ្វារ ។ បំណែកខាងអកុសល គឺបានឃើញអណ្ដាតភ្លើងក្នុងនរក ឬបានឃើញនាយនិរយបាល កាន់ដាវលំពែងជាដើម កើតប្រាកដក្នុងមនោទ្វារ ។ ការដែលសត្វឃើញនូវនិមិត្តឯណា ដែលកើតឡើងក្នុងមនោទ្វារ ក៏ត្រេកអរប្រកាន់ខ្ជាប់នូវនិមិត្តនោះជាអារម្មណ៍ ទើបនាំឲ្យបដិសន្ធិវិញ្ញាណក្នុងសុគតិនឹងទុគ្គតិ តាមកុសលនឹងអកុសល ដែលខ្លួនឃើញនោះ ។ និមិត្តទាំងពីរ គឺកម្មនិមិត្ត ១ គតិនិមិត្ត ១ ជាកម្មអំពីជាតិមុន ឲ្យផលខ្លះ កម្មជាតិនេះឲ្យផលខ្លះ ជាពីរបំណែកដូច្នេះ ។

ស. នាមរូបចាស់បែករលត់ហើយ តើនាមរូបថ្មីកើតអំពីណា ?

ឆ. នាមរូបថ្មីអាស្រ័យនឹងនាមរូបចាស់, ប្រៀបដូចគ្រាប់ស្រូវយកទៅសាបព្រោះចុះក្នុងស្រែ ក៏ដុះឡើងជាសំណាប ចេញគួរជាគ្រាប់ស្រូវថ្មី, គ្រាប់ស្រូវចាស់ក៏ស្អុយរលួយទៅ ។ ឯ



គ្រាប់ស្រូវដែលកើតឡើងថ្មី ក៏អាស្រ័យគ្រាប់ស្រូវចាស់ដូចម្ដេចមិញ ? នាមរូបថ្មីក៏អាស្រ័យនាមរូបចាស់ដូច្នោះដែរ ព្រោះនាមរូបចាស់ធ្វើបុណ្យធ្វើបាបទុកឲ្យជាបច្ច័យ ដល់នាមរូបថ្មី ដោយន័យដូច្នេះ ។

ស. សត្វដែលនឹងកើតឡើងនោះ តើកើតពីបិតាឬមាតា?

ឆ. អាស្រ័យនូវគ្នានឹងគ្នាហើយកើត ។ នឹងថាកើតអំពីមាតាឬបិតាមួយ ៗ ក៏ថាមិនបាន ប្រៀបដូចឈើពួតភ្លើង, ឈើបំនួតមួយនៅខាងលើ ក៏អាស្រ័យឈើបំនួតមួយនៅខាងក្រោម បើបុគ្គលចង់បានអគ្គីដែលកើតអំពីឈើបំនួត ក៏ពួតឲ្យភ្លើងឆេះឡើង នឹងថាភ្លើងឆេះឡើងអំពីឈើបំនួតខាងលើឬខាងក្រោមក៏ថាមិនបាន ។ ឈើបំនួតត្រូវអាស្រ័យនូវគ្នានឹងគ្នាដូចម្ដេចមិញ ? សត្វដែលនឹងកើតឡើង ត្រូវអាស្រ័យមាតានឹងបិតាក៏ដូច្នោះដែរ ។ ម្យ៉ាងទៀត សត្វដែលនឹងកើតឡើងបាន លុះតែព្រមដោយអង្គ ៣ គឺ រាគសន្និបាត ប្រជុំអ្នកទាំងពីរនាក់ មានចិត្តជំរេកព្រមគ្នា ១ ឧតុសន្និបាត ប្រជុំនៃ

សុក្កសម្ភវៈព្រមគ្នាទាំងពីរ ១ ឱកន្តិសន្និបាត បដិសន្ធិវិញ្ញាណនៃសត្វក៏ចុះមកកាន់គភ៌ ១ ។ ព្រមដោយអង្គ ៣ ដូច្នេះ ទើបសត្វកើតឡើង ។

ស. គ្រូឧបជ្ឈាយាចារ្យប្រព្រឹត្តខុសចាកធម៌វិន័យជាពុទ្ធបញ្ញត្តហើយ កុលបុត្រជាសិស្សប្រតិបត្តិតាមសេចក្តីខុសនោះ តើនឹងមានទោសខ្លះដែរឬទេ ?

ឆ. មានទោស ។ ព្រោះលោកប្រព្រឹត្តខុសចាកធម៌វិន័យ កុលបុត្រនឹងប្រព្រឹត្តតាមសេចក្តីខុស ជាអំពើទុច្ចរិត មិនមានប្រយោជន៍ ទាំងជាតិនេះនឹងជាតិមុខ គង់មានទោស ដូចព្រះសារីបុត្រនឹងមោគ្គល្លាន ទៅនៅនឹងអាចារ្យសញ្ជ័យ មិនបានសម្រេចប្រយោជន៍អ្វី ទាំងសិស្សនឹងអាចារ្យ ។

ស. សព្វថ្ងៃនេះ មគ្គផលនៅមានឬទេ ?

ឆ. នៅមាន បើអដ្ឋង្គិកមគ្គទាំង ៨ មាននៅដរាបណា មគ្គផលក៏មាននៅដរាបនោះ ។

ស. អ្វីជាផ្លូវមគ្គ ?



ឆ. សីលសមាធិបញ្ញា សម្រាប់សម្លាប់កិលេសជាផ្លូវមគ្គ។ ព្រោះហេតុបុគ្គលឯណា ញ៉ាំងសីលសមាធិបញ្ញាឲ្យតាំងនៅខ្ជាប់ខ្ជួនក្នុងសន្តាន បុគ្គលនោះក៏បានឈ្មោះថា តាំងនៅក្នុងមគ្គ ។

ស. មគ្គមានប៉ុន្មានប្រការ ?

ឆ. មាន ២ ប្រការ គឺលោកិយមគ្គ ១ លោកុត្តរមគ្គ ១ ។ បុគ្គលសាងកុសលមានទានសីលភាវនាជាដើម ប្រាថ្នាសម្បត្តិមនុស្សនឹងសម្បត្តិសួគ៌ បង្កើតជាឥន្ទព្រហ្ម តាមសេចក្តីនិយមចូលចិត្ត ហៅថាលោកិយមគ្គ ជាផ្លូវយ៉ាងទាប ដែលជារបស់នាំឲ្យសត្វវិលវល់កើត ចាស់ ឈឺ ស្លាប់ នៅក្នុងវដ្តសង្សារ ។ បុគ្គលធ្វើបុណ្យឲ្យទានចំរើនមេត្តាភាវនា ប្រាថ្នាព្រះនិព្វានជាទីរលត់កិលេសនឹងកងទុក្ខ ហៅថា លោកុត្តរមគ្គ ជាផ្លូវយ៉ាងខ្ពស់ដើម្បីជាបច្ច័យនឹងកាត់បង់នូវសេចក្តីកង្វល់ក្នុងវដ្តសង្សារ ។

ស. សភាវៈដូចម្តេច ឈ្មោះថា វដ្តសង្សារ ?

ឆ. ភពទាំង ៣ គឺៈ កាមភព ១ រូបភព ១ អរូបភព ១ ។

ភពទាំង ៣ នេះ ជាទីអាស្រ័យនៃសត្វ ទើបហៅថាវដ្តសង្សារ សេចក្តីវិលវល់ កើតចាស់ឈឺស្លាប់មិនមានទីបំផុត ទាំងមនុស្សនឹងទេវតាមារព្រហ្ម ដែលមានអវិជ្ជាតណ្ហា ឧបាទាន ព័ន្ធព័ទ្ធរួបរឹតនូវសន្តាន ។

ស. ភពទាំង ៣ មានសេចក្តីអធិប្បាយដូចម្តេច ?

ធ. កាមភព ជាទីកើត ទីអាស្រ័យនៃមនុស្សនឹងទេវតា ព្រមទាំងសត្វនរក ប្រេត អសុរកាយ សត្វតិរច្ឆាន ។ រូបភព ជាទីកើត ទីអាស្រ័យនៃព្រហ្មដែលមានរូបទាំង ១៦ ជាន់ ។

អរូបភព ជាទីកើត ទីអាស្រ័យនៃព្រហ្មដែលមិនមានរូបទាំង ៤ជាន់ ។

ស. សត្វទាំងឡាយ ដែលវិលវល់នៅក្នុងភពទាំង ៣ អាស្រ័យហេតុអ្វី ?

ធ. អាស្រ័យហេតុគឺកម្មជាកុសលនឹងអកុសល ដែលសត្វធ្វើដោយកាយវាចាចិត្ត ១ អាស្រ័យវិបាក គឺផលនៃកុសលនឹងអកុសល នាំសត្វបដិសន្ធិតាមយថាកម្ម ដែល



ខ្លួនសន្សំធ្វើមក ១ អាស្រ័យកិលេស សេចក្តីសៅហ្មងដែលកើតឡើងដោយលោភៈទោសៈមោហៈ ១ ។ ធម៌ទាំង ៣ នេះ ជាហេតុជាបច្ច័យ ឲ្យសត្វទាំងឡាយវិលវល់នៅក្នុងភពទាំង ៣ មិនមានទីបំផុត បីដូចជាកង់បក្រដែលវិលនឹងរបិដូរបោះ ។

ស. ព្រះនិព្វាននោះជាទីសុខដូចម្តេច ?

ធ. សេចក្តីសុខក្នុងព្រះនិព្វាននោះ ជាបរមត្ថសុខ ជាសុខដ៏ឧត្តម នឹងរកសុខដទៃមកប្រៀបឲ្យស្មើគ្មាន ។ សត្វជាលោកិយបុថុជ្ជន មិនអាចដឹងបាន តែព្រះអដ្ឋកថាពោលទុកនូវគាថានេះថា អជាតំ ព្រះនិព្វានមិនមានកើតនូវខន្ធ ៥, អាយតនៈ ១២, ធាតុ ១៨, ឥន្ទ្រិយ ២២, អជរា ព្រះនិព្វានមិនមានសេចក្តីចាស់ជរាគ្រាំគ្រា ១, អព្យាធិ ព្រះនិព្វានមិនមានជម្ងឺរោគាព្យាធិ ១, និព្វុយំ គតា ព្រះនិព្វានជាទីដល់នូវសេចក្តីរលត់កិលេស នឹងកងទុក្ខ ជាបរមសុខដ៏ប្រសើរ មិនមានសេចក្តីកើត ចាស់ ឈឺស្លាប់ មិនបានវិលវល់ក្នុងភព.

ទាំង ៣ មិនបានប្រារព្ធនូវជាតិនេះនឹងជាតិមុខ ដូចពាក្យវិសជ្ជនាមកដូច្នេះ ។

ស. ព្រះនិព្វានមានប៉ុន្មានប្រការ ?

ឆ. មាន ២ ប្រការ គឺឧបាទិសេសនិព្វាន រលត់ភ្លើងកិលេសដាច់បាកសន្តាន តែនៅមានខន្ធ ៥ ដែលជាក្រសែឧបាទានមិនទាន់រលត់ ១ អនុបាទិសេសនិព្វាន រលត់ភ្លើងកិលេសនឹងភ្លើងទុក្ខ គឺខន្ធ អាយតនៈ ធាតុ ឥន្ទ្រិយ ឲ្យអស់ទៅរកសេសសល់គ្មាន ។

ស. ខ្យល់ចេញ-ចូល កើតដោយធម្មជាតិអ្វី ?

ឆ. កើតដោយស្ទួតកំរើក ។

ស. ស្ទួតនឹងកំរើក អាស្រ័យធម្មជាតិដូចម្តេច ?

ឆ. អាស្រ័យនូវខ្យល់ជីពចរ ដែលប្រព្រឹត្តទៅក្នុងកាយ ។

ស. ខ្យល់ជីពចរ អាស្រ័យនូវអាការដូចម្តេច ?

ឆ. អាស្រ័យហទយវត្ថុកំរើក ( បេះដូងកំរើក ) ។

ស. ហទយវត្ថុនឹងកំរើក អាស្រ័យហេតុអ្វី ?



ឆ. អាស្រ័យកុសលនឹងអកុសល ។

មនុស្សទេវតាជាដើម អាស្រ័យកុសល, សត្វនរកប្រេតអសុរកាយតិរច្ឆាន អាស្រ័យអកុសល ។

ស. មនុស្សដែលសន្លប់ មិនមានខ្យល់ដង្ហើមចេញចូល ហេតុអ្វីទើបមិនស្លាប់ ?

ឆ. រូបជីវិតនឹងតេជោធាតុឥន្ទ្រិយ មិនទាន់រលត់ ទើបមិនស្លាប់ ។

ស. បុគ្គលនឹងបាននូវមគ្គផល អាស្រ័យឧបាយដូចម្តេច ?

ឆ. អាស្រ័យធម៌ ៤ ប្រការ គឺៈ

១- សប្បុរិសូបសំសេវោ សេពគប់នូវអ្នកប្រាជ្ញដ៏មានបញ្ញា ដែលដឹងធម៌វិន័យជារបស់ព្រះពុទ្ធ ១

២- សទ្ធម្មស្សវនំ ស្តាប់ធម៌នៃអ្នកប្រាជ្ញដែលពោលប្រដៅ ។

៣- យោនិសោមនសិការំ ស្តាប់ហើយធ្វើទុកក្នុងចិត្តដោយឧបាយនៃប្រាជ្ញា ។

៤- ធម្មានុធម្មប្បដិបត្តិ ស្តាប់ហើយក៏បដិបត្តិតាមធម៌ គឺសីលសមាធិបញ្ញា មានសភាពដ៏សមគួរដល់នវលោកុត្តរធម៌ ។ បុគ្គលដែលដល់ព្រមដោយធម៌ទាំង ៤ នេះ គង់នឹងបានសម្រេចនូវមគ្គផលជាពុំខាន ។

ស. ពោធិបក្ខិយធម៌ ៣៧ ប្រការនោះ បានដល់ធម៌អ្វីខ្លះ ?

ឆ. បានដល់ធម៌គឺៈ សតិបដ្ឋាន ៤, សម្មប្បធាន ៤, ឥទ្ធិបាទ ៤, ឥន្ទ្រិយ ៥, ពល ៥, ពោជ្ឈង្គ ៧, អដ្ឋង្គិកមគ្គ ៨ ត្រូវជា ៣៧ ដូច្នេះ ។

សតិបដ្ឋាន ៤ នោះគឺៈ ពិចារណានូវកាយខាងក្នុងនឹងខាងក្រៅ ១ ពិចារណានូវវេទនាខាងក្នុងនឹងខាងក្រៅ ១ ពិចារណានូវចិត្តខាងក្នុងនឹងខាងក្រៅ ១ ពិចារណានូវធម៌ខាងក្នុងខាងក្រៅ ១ ។

សម្មប្បធាន ៤ នោះគឺៈ ព្យាយាមលះបាបដែលមិនទាន់កើត មិនឲ្យកើតឡើង ១ ព្យាយាមលះបាបដែលកើតឡើងហើយ ឲ្យវិនាសទៅ ១ ព្យាយាមញុំាងកុសលដែលមិនទាន់



កើតឡើង ឲ្យកើតឡើង ១ ព្យាយាមញុំាងកុសលដែលមានហើយ ឲ្យចំរើនលើសឡើងទៅ ១ ។

ឥទ្ធិបាទ ៤ នោះគឺៈ សេចក្តីប្រាថ្នាក្នុងការកុសល ជាទីតាំងនៃកុសល ១ សេចក្តីព្យាយាមក្នុងការកុសល ជាទីតាំងនៃកុសល ១ សេចក្តីត្រិះរិះគិតក្នុងការកុសល ជាទីតាំងនៃកុសល ១ បញ្ញាពិចារណាក្នុងការកុសល ជាទីតាំងនៃកុសល ១ ។

ឥន្ទ្រិយ ៥ នោះគឺៈ សទ្ធា សេចក្តីជឿជាក់ជាធំក្នុងការកុសល ១ សេចក្តីព្យាយាមជាធំក្នុងការកុសល ១ សេចក្តីរលឹកត្រិះរិះជាធំក្នុងការកុសល ១ សេចក្តីតាំងចិត្តទុកខ្ជាប់ជាធំក្នុងការកុសល ១ បញ្ញាពិចារណាក្នុងការកុសល ដែលជាទីតាំងនៃកុសល ១ ។

ពលៈ ៥ យ៉ាងនោះគឺៈ សទ្ធា ជាកម្លាំងក្នុងការកុសល១ សេចក្តីព្យាយាមជាកម្លាំងក្នុងការកុសល ១ សេចក្តីរលឹកត្រិះរិះជាកម្លាំងក្នុងការកុសល ១ ចិត្តតាំងនៅខ្ជាប់ខ្ជួនជាកម្លាំងក្នុងការកុសល ១ បញ្ញាពិចារណាជាកម្លាំងក្នុងកុសល ១ ។

ពោជ្ឈង្គ ៧ គឺៈ សតិជាអង្គត្រាស់ដឹង ១ បញ្ញា ជាអង្គត្រាស់ដឹង ១ សេចក្ដីព្យាយាម ជាអង្គត្រាស់ដឹង ១ បីតិ ជាអង្គត្រាស់ដឹង ១ បស្សទ្ធិ ជាអង្គត្រាស់ដឹង ១ សមាធិ ជាអង្គត្រាស់ដឹង ១ ឧបេក្ខា ជាអង្គត្រាស់ដឹង ១ ។

អដ្ឋង្គិកមគ្គ ៨ គឺៈ សេចក្ដីឃើញប្រពៃ ១ សេចក្ដីគិតត្រិះរិះប្រពៃ ១ ពោលវាចាប្រពៃ ១ ធ្វើការងារប្រពៃ ១ ចិញ្ចឹមជីវិតប្រពៃ ១ សេចក្ដីព្យាយាមប្រពៃ ១ សេចក្ដីរឭកប្រពៃ១ តាំងចិត្តខ្ជាប់ប្រពៃ ១ រួមត្រូវជា ៣៧ ប្រការដូច្នេះ ។

ស. នាមធម៌ ដែលហៅថាចិត្ត ១ ហៅថាចេតសិក ១ ទាំងពីរនេះ អ្វីហៅថាចិត្ត? អ្វីហៅថាចេតសិក ?

ធ. វិញ្ញាណ ៨៩ ដួង ហៅថាចិត្ត, សង្ខារ ៥២ ដួង ហៅថាចេតសិក ។

ស. ចិត្តមានលក្ខណៈដូចម្ដេច ?

ធ. ចិត្ត មានលក្ខណៈឲ្យគិតឲ្យនឹកនូវអារម្មណ៍ ហើយដឹង ដោយអត្ថថា : ចិន្តេតីតិ ចិត្តំ ជានាតិ អត្ថោ ប្រែថា



ចិត្ត មានអាការៈឲ្យគិត ឲ្យនឹកនូវអារម្មណ៍ហើយដឹង

ចេតសិក មានអាការៈឲ្យកើតឲ្យរលត់ព្រមជាមួយចិត្ត ហើយទំនុកបំរុងនូវចិត្តឲ្យថាស់ក្លា ក្នុងការបុណ្យការបាប ដោយអត្ថថា: សហចិត្តំ ឧបត្ថម្ភលក្ខណាតីតិ ចេតសិកំ ប្រែថា នាមធម៌ដែលកើតជាមួយនឹងចិត្ត ហើយឧបត្ថម្ភចិត្តឲ្យថាស់ក្លា ហៅថា ចេតសិក ។

ស. ធ្វើបុណ្យ ធ្វើបាប ឲ្យសម្រេចដោយចេតសិកឬចិត្ត ?

ធ. ធ្វើបុណ្យ ធ្វើបាបឲ្យសម្រេចដោយចិត្ត ព្រោះចិត្តជាធំ ដោយអត្ថថា : មនោ បុព្វង្គមា ធម្មា មនោសេដ្ឋា មនោមយា ប្រែថា ធម៌ទាំងឡាយ គឺកុសលនឹងអកុសល មានចិត្តដល់មុន មានចិត្តប្រសើរដោយវិសេស ។ ហេតុនេះ បុណ្យបាប ត្រូវសម្រេចដោយចិត្ត ។

ស. ដូចម្ដេច ទើបហៅថាចិត្ត ? មនោវិញ្ញាណ មិនមែនរបស់ជាមួយគ្នាទេឬ ទើបហៅផ្សេងៗ គ្នា ?

ធ. ធម្មជាតិជាមួយគ្នា, មនោ ប្រែថា ចិត្ត ជានាមធម៌

បង្អោនទៅកាន់អារម្មណ៍ ។ ចិត្ត គឺវិញ្ញាណ ជានាមធម៌ឱ្យ
គិតនឹកនូវអារម្មណ៍ហើយទើបដឹង ។

ស. ចិត្តនោះបានដល់សភាវៈដូចម្តេច ?

ឆ. បានដល់តួភវង្គជារបស់ថ្លាបរិសុទ្ធ ។ កាលសេចក្តីក្រោធ លោភ វង្វេង ជាសត្រូវចូលមកគ្របសង្កត់ នាំឱ្យរបស់ថ្លាក្លាយទៅជាមិនបរិសុទ្ធ ។ ព្រោះហេតុនោះ ព្រះយោគាវចរដែលចំរើនព្រះកម្មដ្ឋាន ត្រូវជំរះសន្តានចិត្តឱ្យបរិសុទ្ធដូចដើម ។

ស. សេចក្តីក្រោធលោភវង្វេង អាស្រ័យធម៌អ្វី ទើបកើតឡើង ។

ឆ. អាស្រ័យអាយតនៈខាងក្រៅ ៦ គឺៈ រូប, សំឡេង, ក្លិន, រស, សម្ផស្ស, ធម្មារម្មណ៍ ។

ស. អាយតនៈខាងក្រៅ អាស្រ័យធម៌អ្វី ?

អាស្រ័យអាយតនៈខាងក្នុង ៦ គឺៈ ភ្នែក, ត្រចៀក, ច្រមុះ, អណ្តាត, កាយ, ចិត្ត ។ សេចក្តីថា ភ្នែកបានឃើញរូប ត្រចៀក បានស្តាប់សំឡេង, ច្រមុះ បានហិតក្លិន, អណ្តាត



បានដឹងរស, កាយ បានពាល់ត្រូវ, ចិត្តបានបង្អោននឹកអារម្មណ៍ដែលដឹងដោយចិត្ត បំណែកដែលល្អ ដែលប្រពៃ ដែលគាប់ចិត្តឱ្យកើតសេចក្តីលោភ វង្វេង ស្រឡាញ់ពេញចិត្ត មានសេចក្តីប្រាថ្នាចង់បាន ។ បំណែកដែលមិនល្អ មិនប្រពៃ មិនចូលចិត្ត ឱ្យកើតសេចក្តីក្រោធគ្នាន់ក្នាញ់ផ្សេង ៗ ដូច្នេះ ។

ស. ដែលមិនឱ្យក្រោធលោភវង្វេងនោះ នឹងធ្វើដូចម្តេច?

ឆ. ឱ្យមានសេចក្តីសំវរៈ សង្រួមរវាំង ធ្វើយោនិសោ-មនសិការៈ ដោយឧបាយនៃបញ្ញាពិចារណាថាៈ រូបសំឡេងក្លិនរសសម្ផស្សធម្មារម្មណ៍ ដែលមកប៉ះទង្គិចនឹងភ្នែកត្រចៀកច្រមុះអណ្តាតកាយចិត្ត ជារបស់មិនទៀង ជាទុក្ខ ជាអនត្តាដូច្នេះ ជាវិធីនាំឱ្យរម្ងាប់សេចក្តីក្រោធលោភវង្វេង ត្រូវឱ្យយកបញ្ញាពិចារណាអាយតនៈខាងក្រៅ ឱ្យឃើញជាអនិច្ចំទុក្ខំអនត្តាដូចម្តេចមិញ គប្បីយកបញ្ញាទៅពិចារណាអាយតនៈខាងក្នុងឱ្យឃើញជាអនិច្ចំទុក្ខំអនត្តា ក៏ដូច្នោះដែរ ។

នេះឯងជាសេចក្តីបដិបត្តិដ៏ពិសេស សម្រាប់រម្ងាប់កិលេស

គឺៈ ក្រោធ, លោភ រង្វេងឲ្យឆ្ងាយចាកសន្តាន

ស. មនុស្សដូចម្តេច ទើបហៅថាជាឧបាសក-ឧបាសិកា បាន ?

ឆ. មនុស្សដែលដល់នូវព្រះត្រៃសរណគមន៍ទាំង ៣ ថាជាទីពឹង ជាទីរឭករាប់អាន ក្រាបសំពះបូជា ទើបហៅថាជា ឧបាសក-ឧបាសិកា ។

ស. ព្រះត្រៃសរណគមន៍ទាំង ៣ បានដល់វត្ថុអ្វី ?

ឆ. បានដល់ព្រះពុទ្ធ ១ ព្រះធម៌ ១ ព្រះសង្ឃ ១ រតនៈទាំង ៣ នេះឯង ហៅថា ត្រៃសរណគមន៍ ។

ស. បុគ្គលនឹងដល់នូវព្រះត្រៃសរណគមន៍នោះ ដោយហេតុប៉ុន្មានប្រការ ?

ឆ. ដោយហេតុ ២ ប្រការ គឺៈ មានសទ្ធា សេចក្តីជឿក្នុងគុណព្រះពុទ្ធព្រះធម៌ព្រះសង្ឃ ១ មានបញ្ញាពិចារណាដឹងច្បាស់នូវគុណនៃព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ១ ។

ស. ព្រះពុទ្ធព្រះធម៌ព្រះសង្ឃទាំង ៣ នោះ មានគុណ



ដូចម្តេច ?

ឆ. ព្រះពុទ្ធអង្គមានសេចក្តីបរិសុទ្ធិ ទ្រង់បញ្ញា មានព្រះទ័យករុណាប្រដៅសត្វ ដោយសេចក្តីបតិបត្តិ ឲ្យស្គាល់ផ្លូវមនុស្សផ្លូវសួគ៌និព្វាន ។ ព្រះធម៌ ពាក្យប្រដៅព្រះសាស្តា ជាធម៌នាំសត្វឲ្យរួចចាកកងទុក្ខទាំងពួង ។ ព្រះសង្ឃ ទ្រង់សីលសមាធិបញ្ញា ជាខេត្តស្រែបុណ្យ ដែលទ្រង់ទុកនូវព្រះពុទ្ធសាសនារហូតមកដល់សព្វថ្ងៃនេះ ។

ស. ត្រូវធ្វើដូចម្តេច ទើបនឹងដល់នូវព្រះត្រៃសរណគមន៍

ឆ. ឲ្យប្រគល់កាយថ្វាយខ្លួនដល់ព្រះសង្ឃថាៈ

អហំ ពុទ្ធញ្ច ធម្មញ្ច សង្ឃញ្ច សរណំ {គតោ / គតា}

ឧបា{សកត្តំ / សិកត្តំ} ទេសេសឹ ភិក្ខុសង្ឃស្ស សម្មុខា

ឯតំ មេ សរណំ ខេមំ ឯតំ សរណមុត្តមំ

ឯតំ សរណមាគម្ម សព្វទុក្ខា បមុច្ចយេ

ដូច្នេះក៏បាន ។ ន័យមួយទៀតថា

ឯសាហំ ភន្តេ សុចិរបរិនិព្វុតម្បិ តំ ភគវន្តំ សរណំ គច្ឆាមិ ធម្មញ្ច ភិក្ខុសង្ឃញ្ច ឧបាសកំ-ឧបាសិកំ មំ សំឃោ ធារេតុ អជ្ជតគ្គេ បាណុបេតំ សរណំ គតំ ប្រែថា: បពិត្រព្រះករុណាដ៏ចំរើន ខ្ញុំព្រះករុណា សូមដល់នូវព្រះដ៏មានព្រះភាគនោះ សូម្បីព្រះអង្គបរិនិព្វាន ទៅហើយអស់កាលដ៏យូរ ព្រមទាំងព្រះធម៌នឹងព្រះសង្ឃថាជាទីពឹងទីរឭក សូមព្រះភិក្ខុសង្ឃ ទ្រង់ចាំទុកនូវខ្ញុំព្រះករុណាថាជាឧបាសក-ឧបាសិកា អ្នកដល់នូវព្រះរតនត្រៃជាទីពឹងទីរឭកស្មើដោយជីវិត ចាប់តាំងពីថ្ងៃនេះទៅ ដូច្នេះក៏បាន ។

ស. ព្រះត្រៃសរណគមន៍នឹងដាច់ ដោយហេតុប៉ុន្មានប្រការ ?

ឆ. ដោយហេតុ ២ ប្រការគឺ: អ្នកដល់នូវព្រះត្រៃសរណគមន៍ហើយ ត្រឡប់ទៅកាន់លទ្ធិខាងក្រៅព្រះពុទ្ធសាសនា ទៅគោរពបូជាមនុស្សនឹងទេវតា ដែលជាមិច្ឆាទិដ្ឋិ ហើយត្រឡប់តិះដៀលព្រះពុទ្ធសាសនាវិញ ព្រះត្រៃសរណគមន៍ដាច់



ហើយ ថែមទាំងមានទោសទៀតផង ១ អ្នកដល់ព្រះត្រៃសរណគមន៍ហើយ ក៏រក្សាទុកយ៉ាងល្អ លុះធ្វើកាលកិរិយាស្លាប់ទៅ ក៏ដាច់ចាកព្រះត្រៃសរណគមន៍ តែមិនមានទោស១ ។

ស. ព្រះត្រៃសរណគមន៍ដាច់ហើយ តើនឹងធ្វើដូចម្ដេច?

ឆ. ឲ្យសូមស្មារណាទោសនឹងព្រះសង្ឃ មានព្រះពុទ្ធរូបជាដើម ហើយក៏សូមសមាទានប្ដេជ្ញាថ្វាយខ្លួនជាថ្មី ក្នុងទីចំពោះមុខព្រះភិក្ខុសង្ឃ ទើបត្រឡប់បានជាឧបាសក-ឧបាសិកាវិញ ហើយត្រូវរក្សាព្រះត្រៃសរណគមន៍តទៅ ។

ស. ព្រះត្រៃសរណគមន៍នឹងសៅហ្មងដោយហេតុអ្វី ?

ឆ. ដោយហេតុដែលខ្លួនដល់ព្រះត្រៃសរណគមន៍ ហើយទៅគោរពមនុស្សនឹងទេវតា ដែលជាមិច្ឆាទិដ្ឋិមុន មិនគោរពនូវគុណព្រះរតនត្រៃមុន ។ ធ្វើដូច្នេះ ព្រះត្រៃសរណគមន៍ឈ្មោះថា សៅហ្មង ។ មួយទៀត បុរាណាចារ្យលោកពោលថា ការគោរពមនុស្សនឹងទេវតា ដែលជាសម្មាទិដ្ឋិ មានសីល មានធម៌ល្អ ព្រះត្រៃសរណគមន៍មិនសៅហ្មងទេ ។

ពាក្យនេះក៏ឃើញថាសមប្រកបដែរ ព្រោះថា មនុស្សដែលគួរនឹងគោរព មាន ៣ ជំពូក គឺៈ

១- វយវុឌ្ឍោ មនុស្សមានអាយុចាស់ជាងខ្លួន

២- គុណវុឌ្ឍោ មនុស្សមានអាយុតិចជាងខ្លួន តែមានសីល មានធម៌ល្អជាងខ្លួន ៗ គួរនឹងសំពះ

៣- ជាតិវុឌ្ឍោ មនុស្សមានជាតិត្រកូលខ្ពស់ មានក្សត្រជាដើម ដែលក្មេងជាង តែគួរនឹងសំពះ ។

កាលបើសំពះមនុស្សមានបុណ្យ ឲ្យគិតដល់គុណធម៌ ៥ប្រការថាៈ អ្នកនេះ អំពីជាតិមុន ជាមនុស្សមានសទ្ធា សេចក្តីជឿបុណ្យជឿបាប ១ មានសីល សេចក្តីលះវៀរចាកបាបដោយកាយវាចា ១ មានសុតៈ ត្រងត្រាប់ស្តាប់ធម៌ ១ មានចាគៈ លះសេចក្តីកំណាញ់ ហើយបរិច្ចាគទាន ១ មានបញ្ញា សេចក្តីពិចារណាដឹង ១ ។ ធម៌ទាំង ៥ ប្រការនេះ មានក្នុងសន្តានរបស់ខ្លួន ទើបបានមកកើតក្នុងត្រកូលខ្ពស់ ដូច្នេះសិន ហើយទើបសំពះ ។



ស. ព្រះត្រៃសរណគមន៍សៅហ្មងហើយ តើត្រូវធ្វើដូចម្តេច?

ឆ. ឲ្យសមាទានជាថ្មី, ឲ្យត្រចៀករបស់ខ្លួនបានឮ ក្នុងសំណាក់នៃភិក្ខុសាមណេរ នឹងឧបាសកក្តី ឬសមាទានយកដោយខ្លួនឯងក្តី ក៏បាន ។

ស. ព្រះត្រៃសរណគមន៍នឹងឡើង ដោយហេតុដូចម្តេច? នឹងតាំងនៅដោយហេតុដូចម្តេច? នឹងដាច់ទៅដោយហេតុដូចម្តេច ?

ឆ. នឹងឡើង ក៏ដោយចិត្ត, នឹងតាំងនៅ ក៏ដោយចិត្ត, នឹងដាច់ទៅវិញ ក៏មកតែពីចិត្ត ។ ដែលព្រះពុទ្ធអង្គទ្រង់ត្រាស់ថា មនោ បុព្វង្គមា ធម្មា ធម៌ទាំងឡាយ គឺកុសលនឹងអកុសល រមែងមានចិត្តដល់មុន មនោសេដ្ឋា មានចិត្តប្រសើរដោយវិសេស មនោមយា សម្រេចដោយចិត្ត ។

ស. ចិត្តនោះនឹងធ្វើដូចម្តេច ?

ឆ. ទុកមានចិត្តឲ្យមានសទ្ធា ជឿគុណព្រះរតនត្រៃ មិនឲ្យជឿអ្នកដទៃ ១ ចិត្តមិនប្រមាទ មានសតិរឭកដល់គុណ

ព្រះរតនត្រៃនៅអស់កាលជានិច្ច១ បញ្ញាតិបារណាឃើញគុណព្រះរតនត្រៃ ថាប្រសើរជាងរតនៈទាំងពួងក្នុងភពទាំង បី ១ ។

ស. អ្នកដល់ព្រះត្រៃសរណគមន៍ហើយ មានគុណានិសង្សដូចម្ដេច ?

ធ. មានគុណានិសង្ស គឺមិនបានទៅកាន់អបាយភូមិទាំង ៤ មាននរកជាដើម ដោយព្រះបាលីថា: យេ កេចិ ពុទ្ធំ សរណំ គតាសេ ន តេ គមិស្សន្តិ អបាយភូមឹ ប្រែថា បុគ្គលឯណាមួយ ដល់នូវព្រះត្រៃសរណគមន៍ហើយ មិនបានទៅកាន់អបាយភូមិ លុះធ្វើកាលកិរិយាស្លាប់ហើយ ក៏នឹងទៅកាន់សុគតិ ។

ស. អ្នកដល់ព្រះត្រៃសរណគមន៍ជាឧបាសក-ឧបាសិកាហើយ នឹងឲ្យបដិបត្តិដូចម្ដេច ?

ធ. ឲ្យរក្សាសីល ៥ ៨ កម្មបថ ១០ ឲ្យបរិបូណ៌ ។ សីល



១- បាណាតិបាតា វេរមណី វៀរបាកសម្លាប់សត្វដែលមានជីវិត មានស្រមោចស្រមើលជាដើមឲ្យស្លាប់ ដោយកាយវាចាឬប្រើអ្នកដទៃ

២- អទិន្នាទានា វេរមណី វៀរលែងលួចលាក់ទ្រព្យអ្នកដទៃ ដោយខ្លួនឯង ឬប្រើអ្នកដទៃឲ្យលួចលាក់

៣- កាមេសុមិច្ឆាចារា វេរមណី វៀរបាកកន្លងប្រវេណី ប្រព្រឹត្តខុសក្នុងស្ត្រីដែលគេហ្វាងហែង

៤- មុសាវាទា វេរមណី វៀរបាកពោលពាក្យកុហកបញ្ឆោត ភូតបំព្រាងអ្នកដទៃ

៥- សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី វៀរបាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺក្រេបផឹកនូវសុរានឹងមេរ័យ

ឯសីល ៨ គ្រាន់តែបញ្ចូលសិក្ខាបទ ៣ មកទៀតគឺ :

១- វិកាលភោជនា វេរមណី វៀរបាកបរិភោគអាហារក្នុងពេលវិកាល គឺតាំងពីព្រះអាទិត្យជ្រេទៅ

២- នច្ចគីតវាទិតវិសូកទស្សន មាលាគន្ធវិលេ-

បនធារណាមណ្ឌនវិភូសនដ្ឋានា វេរមណី វៀរចាកមើល ស្តាប់ច្រៀងរាំប្រគំនូវគ្រឿងតូរ្យដន្ត្រី នឹងគ្រឿងប្រដាប់តាក់តែងរាងកាយ មានផ្កាឈើនឹងគ្រឿងក្រអូបជាដើម

៣- ឧច្ចាសយនមហាសយនា វេរមណី វៀរចាកដេកអង្គុយលើគ្រែ លើតាំងមានជើងខ្ពស់លើសប្រមាណ មានពូកប្រកគរនឹងសំឡីខាងក្នុង ។ រួមត្រូវជា ៨ ដូច្នេះ ។ សីល ៨ រក្សាក្នុងថ្ងៃ ៥.៨.១៤.១៥ កើត រោច ក្នុង ១ខែ រក្សា ៨ ដង ។

កុសលកម្មបថ ១០ គឺៈ កាយកម្ម ៣ វចីកម្ម ៤ មនោ.កម្ម ៣ ។ កាយកម្ម ៣ នោះ គឺៈ វៀរចាកសម្លាប់សត្វ១ វៀរចាកលួចទ្រព្យគេ ១ វៀរចាកកន្លងប្រវេណី ប្រព្រឹត្តខុសក្នុងស្ត្រីដែលមានគេហួងហែង ១ ។ វចីកម្ម ៤ នោះ គឺៈ មិននិយាយកុហកគេ ១ មិននិយាយពាក្យស៊ិកសៀត ឬញុះញង់អ្នកដទៃឲ្យបែកបាក់គ្នា ១ មិននិយាយពាក្យអាក្រក់ គឺជេរដោយជាតិត្រកូលជាដើម ១ មិននិយាយពាក្យរោយរាយឥតប្រយោជន៍ និយាយតែពាក្យដែលមានប្រយោជន៍ ១ ។



មនោកម្ម ៣ គឺៈ ចិត្តមិនលោភរំពៃសំឡឹង គិតចង់បានរបស់អ្នកដទៃ ១ ចិត្តមិនគិតព្យាបាទអាឃាតចងពៀរ ដល់មនុស្សនឹងសត្វដទៃ ១ មិនមានទិដ្ឋិឃើញខុសចាកព្រះពុទ្ធសាសនា១។ ទាំង ១០ នេះ សំដែងដោយកម្មបថដែលជាចំណែកកុសល ។ ចំណែកកម្មបថដែលជាអកុសលក៏មាន ១០ដែរ គឺៈ កាយកម្ម៣ វចីកម្ម ៤ មនោកម្ម ៣ ។ កាយកម្ម ៣ នោះគឺៈ សម្លាប់សត្វ ១ លួចទ្រព្យគេ ១ ធ្វើកាមេសុមិច្ឆាចារ ១ ។ វចី-កម្ម ៤ នោះគឺៈ និយាយកុហក ១ និយាយស៊ិកសៀត ១ និយាយអាក្រក់ ១ និយាយពាក្យមិនមានប្រយោជន៍ ១ ។ មនោកម្ម ៣ នោះគឺៈ ចិត្តគិតរំពៃចង់បានទ្រព្យអ្នកដទៃ ១ ចិត្តគិតព្យាបាទចំពោះមនុស្សនឹងសត្វដទៃ ១ ចិត្តជាមិច្ឆាទិដ្ឋិយល់ឃើញខុសចាកព្រះពុទ្ធសាសនា ១ ។ ទាំង ១០ នេះជាអកុ-សល ។

ស. កម្មបថ ១០ មានអ្វីជាមូល ( ឫសគល់ )

ឆ. បំណែកខាងកុសល មានមិនលោភ មិនក្រោធ មិនវង្វេងជាមូល ។ បំណែកខាងអកុសល មានសេចក្ដីលោភ ក្រោធ វង្វេងជាមូល ។

អទិន្នាទាន លួចទ្រព្យគេ ១ មុសាវាទ ពោលពាក្យកុហក ១ បិសុណាវាទ ពោលញុះញង់ ១ សម្ផប្បលាបវាទ ពោលពាក្យមិនមានប្រយោជន៍ ១ ទាំង ៤ នេះជាត្រៃហេតុ ។ បាណាតិបាត សម្លាប់សត្វ ១ ផរុសវាទ ពោលពាក្យអាក្រក់ ១ ព្យាបាទ ញ៉ាំងមនុស្សនឹងសត្វឲ្យវិនាស ១ ទាំង ៣ នេះ ជាទោសមូល ។ កាមេសុមិច្ឆាចារ កន្លងប្រពៃណីក្នុងស្ត្រីដែលគេហួងហែង ១ អភិជ្ឈា សំឡឹងចង់លួចទ្រព្យគេ ១ មិច្ឆាទិដ្ឋិ សេចក្ដីយល់ឃើញខុស ១ ទាំង ៣ នេះជាមោហមូល ។

ស. បុគ្គលដែលមានសទ្ធា ចេញបួសក្នុងព្រះពុទ្ធសាសនានោះ ដើម្បីប្រយោជន៍អ្វី ?

ឆ. ដើម្បីប្រយោជន៍នឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន ។

ស. ដើម្បីធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាននោះ តើត្រូវធ្វើ



ដូចម្ដេច ?

ឆ. ត្រូវធ្វើសីលសមាធិបញ្ញា ឲ្យបរិសុទ្ធឡើងក្នុងសន្ដាន ។

ស. គ្រហស្ថនឹងធ្វើសីលសមាធិបញ្ញាឲ្យបរិបូណ៌មិនបានឬ?

ឆ. មិនបានទេ, ព្រោះគ្រហស្ថ មានកិច្ចធុរៈច្រើន ហើយប្រឡូកប្រឡំទៅដោយកាមគុណទាំង៥ មិនអាចនឹងញ៉ាំងសីលសមាធិបញ្ញា ឲ្យបរិបូណ៌ក្នុងសន្ដានបាន ។ មួយទៀត ភេទបព្វជិត ជាភេទដ៏ពិសេសពិសាលណាស់ អាចនឹងទ្រទ្រង់ទុកនូវព្រះពុទ្ធសាសនា រៀនសូត្រសិក្សាធម្មវិន័យ ដែលជាទីជ្រះថ្លានៃមនុស្សនឹងទេវតា នឹងបានជាប់ជាញាតិក្នុងព្រះពុទ្ធសាសនា ។

ស. បួសហើយមិនសិក្សារៀនសូត្រ មិនបដិបត្តិតាមធម៌វិន័យត្រៃសិក្ខា តើនឹងមានប្រយោជន៍អ្វីទេ ?

ឆ. បួសដូច្នោះអាស្រ័យចិញ្ចឹមជីវិតក្នុងសាសនា បួសញ៉ាំញីសាសនា សង្កត់សង្កិនព្រះពុទ្ធសាសនាឲ្យសៅហ្មង បួសវង្វេងដូចគោខ្វាក់, ដេកឱបសាសនា មិនដឹងច្បាស់

នូវសាសនា ។ បួសដូចសំដែងមកនេះ ឈ្មោះថាបួសរកប្រយោជន៍គ្មាន ។

ស. ដែលបួសជាភិក្ខុសាមណេរ ហេតុអ្វីទើបចាំបាច់កោរសក់ ?

ធ. ព្រោះហេតុឲ្យខុសបាកភេទឃរាវាស, ការមានសក់នាំឲ្យរវល់ស្អិតស្អាង ដែលមិនមែនជាផ្លូវនៃសមណៈ ថែមទាំងនាំឲ្យខាតពេលវេលា ខានបានរៀនសូត្រធម៌វិន័យ, មិនបានញុំាងសីលសមាធិបញ្ញាឲ្យចំរើន ។

ស. ដែលបួសជាភិក្ខុសាមណេរ មិនបរិភោគភោជនាហារក្នុងវេលាថ្ងៃរសៀលនោះ ព្រោះហេតុអ្វី ?

ធ. ព្រោះហេតុនឹងបន្ទោរបង់នូវរាគៈ សេចក្ដីជម្រេកត្រេកអរនឹងសេចក្ដីងងុយដេក សេចក្ដីខ្ជិលច្រអូស ដើម្បីនឹងបានចំរើនភាវនាកម្មដ្ឋាន ។

ស. កុសលមានប៉ុន្មានប្រការ ?

ធ. មាន ២ ប្រការ គឺៈ វដ្ដគាមិនីកុសល កុសលដែល



បុគ្គលធ្វើដោយសេចក្ដីប្រាថ្នា នូវជាតិភពប្រារព្ធនូវសម្បត្តិមនុស្សសួគ៌ជាន់ព្រហ្មលោក ១ វិវដ្ដគាមិនីកុសល កុសលដែលបុគ្គលធ្វើ ដោយមិនមានសេចក្ដីប្រាថ្នានូវសម្បត្តិមនុស្សនឹងសួគ៌, តាំងចិត្តឈោងយកព្រះនិព្វាន សេចក្ដីរលត់កងទុក្ខទាំងអស់ ១ ។

ស. សភាវៈដូចម្ដេចជាទីតាំងនៃបុណ្យកុសល ?

ធ. សទ្ធា សេចក្ដីជឿក្នុងគុណព្រះរតនត្រៃកែវទាំង ៣ ប្រការ ជឿក្នុងទានសីលភាវនាជាដើម ។ សភាវៈទាំងអម្បាលនេះ ជាទីតាំងនៃបុណ្យកុសល ។

ស. អ្វីជាតួបុណ្យ ?

ធ. សេចក្ដីបរិសុទ្ធកាយ ១ បរិសុទ្ធវាចា ១ បរិសុទ្ធចិត្ត ១ ទាំង ៣ នេះហៅថា បុណ្យកុសល ដោយមានបាលីថា សព្វបាបស្ស អករណំ ការមិនធ្វើនូវអំពើបាបទាំងពួងដោយកាយវាចាចិត្ត ១ កុសលស្សូបសម្បទា ការញុំាងកុសលឲ្យដល់ព្រមដោយកាយវាចាចិត្ត ១ សចិត្តបរិ.

យោទបនំ ការជំរះចិត្តឲ្យបរិសុទ្ធ មិនមានកិលេសជាគ្រឿងសៅហ្មង ១ ឯតំ ពុទ្ធាន សាសនំ ពាក្យនេះឯងជាសាសនៈ ពាក្យប្រៀនប្រដៅនៃព្រះពុទ្ធទាំងឡាយ ។

ស. ធម៌អ្វីឈ្មោះថា សាសនា ?

ឆ. ព្រះបរិយត្តិធម៌ គឺព្រះសូត្រ ព្រះវិន័យ ព្រះបរមត្ថ ១ បដិបត្តិធម៌ គឺសីលសមាធិបញ្ញា ១ បដិវេធធម៌ គឺសេចក្តីត្រាស់ដឹងមគ្គផល ១ ។

ស. កាលព្រះពុទ្ធអង្គមិនទាន់បានត្រាស់ដឹងនោះ មានសាសនាឬទេ ?

ឆ. មានដែរ ឈ្មោះថា ព្រហ្មញ្ញសាសនា ប្រដៅផ្លូវសួគ៌ខ្លះ ផ្លូវមនុស្សខ្លះ ផ្លូវព្រហ្មលោកខ្លះ តែផ្លូវព្រះនិព្វាន មិនមានប្រដៅទេ; លុះតែព្រះពុទ្ធអង្គបានត្រាស់ដឹង ទើបទ្រង់ប្រដៅផ្លូវព្រះនិព្វាន ឈ្មោះថា សាមញ្ញសាសនា ។

ស. ព្រះអង្គប្រដៅនូវផ្លូវព្រះនិព្វាននោះ ដោយធម៌អ្វី ?

ឆ. ប្រដៅដោយសីលសមាធិបញ្ញា កាត់នូវអវិជ្ជា តណ្ហា



ឧបាទានឲ្យដាច់ចាកសន្តាន ជាសមុច្ឆេទប្បហាន ដោយញាណគឺបញ្ញា ។

ស. យោនិសោមនសិការៈ នឹងបញ្ញានោះ ដូចគ្នាឬទេ ?

ឆ. មិនដូចគ្នាទេ; យោនិសោមនសិការៈ មានទូទៅគ្រប់មនុស្សនឹងសត្វតិរច្ឆាន ។ ឯតូបញ្ញា មានតែព្រះអរិយៈជាអម្ចាស់មួយជំពូក ព្រោះយោនិសោមនសិការៈ ប្រែថា សេចក្តីកំណត់ក្នុងកិរិយាធ្វើទុកក្នុងចិត្ត; បញ្ញា ប្រែថា សេចក្តីដឹង ឃើញទូទៅ ក្នុងខន្ធអាយតនៈធាតុឥន្ទ្រិយ ហើយដឹងទីកើតនៃសង្ខារ នឹងទីរលត់នៃសង្ខារ ។

ស. ទីកើតនឹងទីរលត់នៃសង្ខារនោះ បានដល់ធម៌អ្វី ?

ឆ. ទីកើតនៃសង្ខារ បានដល់ធម៌ ៤ ប្រការគឺៈ អវិជ្ជា ១ តណ្ហា ១ កម្ម ១ អាហារ ១ ។ ទីរលត់នៃសង្ខារ គឺព្រះនិព្វាន; ព្រោះព្រះនិព្វានជាទីរលត់ភ្លើងកិលេសនឹងភ្លើងទុក្ខ ។

ស. ភ្លើងកិលេសនឹងភ្លើងទុក្ខ បានដល់ធម៌អ្វី ?

ឆ. ភ្លើងកិលេស បានដល់រាគៈ សេចក្តីត្រេកត្រអាល

ក្នុងកាមគុណទាំង ៥ មានរូបជាដើម ១ ទោសៈ សេចក្ដីទឹងក្រេវក្រោធប្រទូសរ៉ាយ ១ មោហៈ សេចក្ដីវង្វេងក្នុងអារម្មណ៍ផ្សេងៗ ដែលគួរស្រឡាញ់គួរស្អប់ ១ ភ្លើងទុក្ខគឺជាតិទុក្ខមានវដ្ដ ៥ជាដើម ១ ។

ស. ធម៌ ៤ប្រការ មានអវិជ្ជាជាដើម មានសេចក្ដីអធិប្បាយដូចម្ដេច ?

ឆ. អវិជ្ជា ប្រែថា សេចក្ដីមិនដឹងនូវសង្ខារ ឲ្យកើតសង្ខារ ១ តណ្ហា សេចក្ដីប្រាថ្នាត្រេកអរក្នុងកាមភព រូបភពនឹងអរូបភព ១ កម្ម គឺកុសលនឹងអកុសល ១ អាហារ ៤ មានផស្សាហារជាដើម ១ ទាំង ៤ នេះឲ្យកើតសង្ខារ ។

ស. ធម៌អ្វីឈ្មោះថា សង្ខារ ?

ឆ. សង្ខារមាន ២ គឺៈ ឧបាទិន្នកសង្ខារ សង្ខារដែលមានរូប មានចិត្ត មានវិញ្ញាណ ១ អនុបាទិន្នកសង្ខារ សង្ខារដែលមានតែរូប មិនមានចិត្តវិញ្ញាណ ១ ។



ស. អ្វីជាហេតុឲ្យកើតបុណ្យ-បាប ?

ឆ. សេចក្ដីក្រោធ-លោភ-វង្វេង ជាហេតុឲ្យកើតបាប; សេចក្ដីមិនក្រោធៈមិនលោភ-មិនវង្វេង ជាហេតុឲ្យកើតបុណ្យ។

ស. បុណ្យបាប កើតអំពីទ្វារដូចម្ដេច ?

ឆ. បុណ្យបាប កើតអំពីអាយតនៈខាងក្នុង ដែលអាស្រ័យអាយតនៈខាងក្រៅ ។ អាយតនៈខាងក្នុង ៦ គឺៈ ភ្នែកត្រចៀកច្រមុះអណ្ដាតកាយចិត្ត; អាយតនៈខាងក្រៅ ៦ គឺៈ រូប សំឡេងក្លិន រស សម្ផស្ស ធម្មារម្មណ៍ ។ សេចក្ដីថា បុណ្យបាបកើតអំពីទ្វារភ្នែកអាស្រ័យរូប កាលចក្ខុឃើញរូបហើយ ឲ្យកើតចក្ខុសម្ផស្ស សំឡឹងមើលរូប ឲ្យកើតចក្ខុវិញ្ញាណ ដឹងច្បាស់នូវរូបល្អ រូបអាក្រក់ ; កាលបើដឹងច្បាស់នូវរូបល្អរូបអាក្រក់ហើយ ឲ្យកើតវេទនា ៣ គឺ សោមនស្ស ១ ទោមនស្ស ១

ឧបេក្ខា ១ ។

អធិប្បាយថាៈ ភ្នែកឃើញរូបដែលល្អ ឲ្យកើតសោមនស្សវេទនា; ឃើញរូបមិនល្អ ឲ្យកើតសេចក្ដីទោមនស្សវេទនា; ឃើញរូបដែលមិនល្អមិនអាក្រក់ ឲ្យកើតឧបេក្ខាវេទនា ។ កាលវេទនាមានហើយ ក៏ឲ្យកើតតណ្ហា សេចក្ដីប្រាថ្នា ដែលល្អ ឲ្យកើតលោភៈ សេចក្ដីចង់បាន; ដែលអាក្រក់ក៏ចង់ឲ្យវិនាសទៅ; កាលតណ្ហាមានហើយ ក៏ឲ្យកើតឧបាទានសេចក្ដីប្រកាន់ខ្ជាប់ ឲ្យធ្វើបុណ្យបាបដោយទ្វារភ្នែក ១ ទ្វារត្រចៀកក៏អាស្រ័យសំឡេង ទ្វារច្រមុះ ក៏អាស្រ័យក្លិន ទ្វារអណ្ដាតក៏អាស្រ័យរស ទ្វារកាយ ក៏អាស្រ័យសម្ផស្ស ទ្វារចិត្ត ក៏អាស្រ័យធម្មារម្មណ៍ ដែលដឹងដោយចិត្ត ឲ្យកើតផស្សៈ សេចក្ដីសំទ្បឹង ឲ្យកើតវិញ្ញាណ សេចក្ដីដឹង ឲ្យកើតវេទនា សេចក្ដីសោយអារម្មណ៍ ឲ្យកើតតណ្ហា សេចក្ដីប្រាថ្នា ឲ្យកើតឧបាទានសេចក្ដីប្រកាន់ខ្ជាប់ ទើបកើតបុណ្យបាប តាមទ្វារភ្នែកត្រចៀកច្រមុះអណ្ដាតកាយចិត្ត ដោយន័យដូចបានរិសជ្ជនាមកនេះ ។



មួយទៀត បុគ្គលនឹងធ្វើបុណ្យបាប ត្រូវអាស្រ័យតណ្ហាឧបាទាន ព្រោះហេតុនោះ ទើបសំដែងឲ្យឃើញថា តណ្ហាឧបាទានជាបច្ច័យទំនុកបំរុង ទាំងចំណែកបុណ្យនឹងចំណែកបាប ។ ចំណែកបុណ្យ ឲ្យកើតក្នុងសុគតិ មានមនុស្សជាដើម ។ ចំណែកបាប ឲ្យទៅកើតក្នុងទុគ្គតិ មាននរកជាដើម ពោលដោយតណ្ហាមាន ៣ គឺ កាមតណ្ហា ១ ភវតណ្ហា ១ វិភវតណ្ហា ១ ។ កាមតណ្ហា បានដល់សេចក្ដីប្រាថ្នាក្នុងកាមភព ១១ គឺ អបាយភូមិ៤ មនុស្ស ១ សួគ៌ ៦ ជាន់ ត្រូវជា ១១ ។ ភវតណ្ហានោះ បានដល់បុគ្គលបំរើននូវរូបឈាន លុះទម្លាយសង្ខារ ក៏ទៅកើតក្នុងរូបព្រហ្ម ១៦ ជាន់ ។ វិភវតណ្ហានោះ បានដល់បុគ្គលដែលបំរើនអរូបឈាន លុះទម្លាយសង្ខារ ក៏ទៅកើតក្នុងអរូបព្រហ្ម ៤ ជាន់ ។ មួយទៀត ព្រះសោតា ព្រះសក្កិទាគាមី ព្រះអនាគាមី ក៏នៅមានតណ្ហាឧបាទាន ជួយទំនុកបំរុង ទើបឲ្យបំរើនវិបស្សនា សម្លាប់អវិជ្ជាតណ្ហាឧបាទាន ឲ្យដាច់ចាកសន្តាន . ដល់ព្រះអរហត្តកាត់

កិលេស ជាសមុច្ឆេទប្បហាន រំលត់ទុក្ខចូលកាន់ព្រះនិព្វាន រួចបាកកងទុក្ខទាំងអស់ ។

ស. តណ្ហា ១០៨ នោះ បានដល់ធម៌អ្វីខ្លះ ?

ឆ. បានដល់តណ្ហាខាងក្នុង ៦ ខាងក្រៅ ៦ ជា ១២, បំណែកខាងកាមតណ្ហា ១២ ភវតណ្ហា ១២ វិភវតណ្ហា ១២ ជា ៣៦ បាត់ជាអតីត ៣៦ អនាគត ៣៦ ជាបច្ចុប្បន្ន ៣៦ ទើបត្រូវជាតណ្ហា ១០៨ ដូច្នេះ ។ តណ្ហាខាងក្នុង ៦ គឺភ្នែក ត្រចៀក ប្រមុះ អណ្តាត កាយ ចិត្ត ត្រូវជា ៦ ។ តណ្ហាខាងក្រៅ ៦ គឺៈ រូបសំឡេងក្លិនរសសម្ផស្សធម្មារម្មណ៍ ត្រូវជា៦ ។

ស. វេទនា ១០៨ បានដល់ធម៌អ្វីខ្លះ ?

ឆ. បានដល់វេទនាខាងក្នុង ៦ ខាងក្រៅ ៦ ជា ១២ បំណែកសោមនស្សសុខវេទនា១២, ទោមនស្សទុក្ខវេទនា១២, ឧបេក្ខាវេទនា១២ ជា ៣៦ បាត់ជាអតីតវេទនា ៣៦ អនាគតវេទនា ៣៦ បច្ចុប្បន្នវេទនា ៣៦ ត្រូវជាវេទនា ១០៨ ដូច្នេះ។



ស. បុគ្គលធ្វើបុណ្យធ្វើបាប តើបុណ្យបាបនឹងឲ្យផលក្នុងពេលណា ?

ឆ. ឲ្យផលតាមកាល បើមិនទាន់ដល់កាល ក៏មិនទាន់ឲ្យផល ប្រៀបដូចផ្លែស្វាយ ដល់កំណត់កាល ក៏ចេញផ្លែ បើមិនទាន់ដល់កំណត់កាល ក៏មិនទាន់ចេញផ្លែ ។

ស. កាលនោះ បានដល់អ្វី ?

ឆ. បានដល់វ័យទាំង ៣ គឺៈ បឋមវ័យ ១ មជ្ឈិមវ័យ ១ បច្ឆិមវ័យ ១ ។ បុណ្យបាបខ្លះដែលធ្វើក្នុងបឋមវ័យ ឲ្យផលក្នុងបឋមវ័យ, បុណ្យបាបខ្លះធ្វើក្នុងមជ្ឈិមវ័យ ឲ្យផលក្នុងមជ្ឈិម-វ័យៈ បុណ្យបាបខ្លះធ្វើក្នុងបច្ឆិមវ័យ ឲ្យផលក្នុងបច្ឆិមវ័យ, សុទ្ធសឹងតែខ្លួនបានធ្វើទុកពិត បើធ្វើទុកក្នុងវ័យណា ក៏ឲ្យផលក្នុងវ័យនោះ ។

ស. វ័យទាំង ៣ កំណត់ដូចម្តេច ?

ឆ. កំណត់ ៧៦ ឆ្នាំ ជាអាយុក្ខ័យ ហើយបែងអាយុក្ខ័យ ជា ៣ បំណែក ។ បំណែកទី ១ ហៅថាបឋមវ័យ, បំណែកទី ២ ហៅថា មជ្ឈិមវ័យ, បំណែកទី ៣ ហៅថា បច្ឆិមវ័យ ដោយន័យដូចវិសជ្ជនាមកនេះ ។

ស. កិច្ចក្នុងព្រះពុទ្ធសាសនា មានប៉ុន្មានប្រការ?

ឆ. មាន ២ ប្រការ គឺៈ គន្ថធុរៈ សូត្ររៀនព្រះសូត្រ ព្រះវិន័យ ព្រះបរមត្ថ ១ វិបស្សនាធុរៈ បំរើនសមថកម្មដ្ឋាន នឹងវិបស្សនាកម្មដ្ឋាន ១ ។

ស. ព្រះពុទ្ធសាសនា មានប្រភេទប៉ុន្មានប្រការ?

ឆ. មាន ៣ ប្រការ គឺ បរិយត្តិសាសនា បានដល់ព្រះបរិយត្តិធម៌ គឺព្រះត្រៃបិដក ៨ ហ្មឺន ៤ ពាន់ព្រះធម្មក្ខន្ធ គឺៈ ព្រះសូត្រ ២១.០០០ ព្រះធម្មក្ខន្ធ ព្រះវិន័យ ២១.០០០ ព្រះធម្មក្ខន្ធ ព្រះបរមត្ថ ៤២.០០០ ព្រះធម្មក្ខន្ធ ១ បដិបត្តិសាសនា បានដល់សេចក្តីបដិបត្តិ គឺសីលសមាធិបញ្ញា ១ បដិវេធសាសនា បានដល់សេចក្តីត្រាស់ដឹងនូវមគ្គផល ១ ។



ស. ដែលហៅថា ធម្មក្ខន្ធនោះកំណត់ដូចម្តេច?

ឆ. ដែលហៅថា ព្រះធម្មក្ខន្ធនោះ ប្រែថាជាកងនៃធម៌ គឺបទធម៌១ ឬគាថា ១ ឬបាទគាថា ១ ចាត់ជាធម្មក្ខន្ធមួយ ៗ ។

ស. គាថានោះមានកំណត់ដូចម្តេច?

ឆ. រាប់ស្រៈ ៨ តួ នឹងអក្សរៈ ៨ តួ ជាបាទ ១ ៗ ៤ បាទ ជា ១ គាថាដូច្នេះ ។

ស. ដែលឈ្មោះថាធម៌នោះ គឺអ្នកណាពោល ទើបឈ្មោះថាធម៌?

ឆ. ធម៌មាន ៤ គឺ ពុទ្ធភាសិត ព្រះពុទ្ធអង្គទ្រង់សំដែង ដោយព្រះអង្គឯង ចាត់ជាធម៌មួយពួក ឥសិភាសិត ឫសីសំដែង ចាត់ជាធម៌ពួកមួយ ។ សាវកភាសិត សាវ័កនៃព្រះពុទ្ធអង្គសំដែង ចាត់ជាធម៌មួយពួក ។ ទេវតាភាសិត ទេវតាសំដែង ចាត់ជាធម៌មួយពួក ។

ស. មនុស្សពួកណា ដែលឈ្មោះថា សាវ័ក?

ឆ. មនុស្សដែលតាំងនៅក្នុងឱវាទ ពាក្យប្រដៅនៃព្រះ

ពុទ្ធអង្គ មានសីល ៥ សីល ៨ ជាដើម ឈ្មោះសាវ័ក ។

ស. បុគ្គលដែលជាសាវ័ក ត្រូវបដិបត្តិដូចម្តេច ?

ឆ. បើជាគ្រហស្ថឲ្យបដិបត្តិក្នុងអាចារវត្ត សេចក្តីសុចរិតទាំង ៣ គឺៈ កាយសុចរិត ១ វចីសុចរិត ១ មនោសុចរិត១ នឹងសីលវត្ត គឺរក្សាសីល ៥ សីល ៨ ឲ្យបរិបូណ៌ ។ បើជាបព្វជិត ឲ្យបដិបត្តិក្នុងអាចារវត្ត សង្រួមឥន្ទ្រីយទាំង ៦ គឺភ្នែក ត្រចៀកច្រមុះអណ្តាតកាយចិត្ត ១ នឹងសីលវត្ត គឺរក្សាសីលតាមភូមិរបស់ភិក្ខុ នឹងសាមណេរឲ្យបរិបូណ៌ ១ ធុតង្គវត្ត គឺរក្សាធុតង្គ ១៣ តាមពុទ្ធប្បញ្ញត្ត ១ ។

ស. ធម៌នឹងសាបសូន្យដោយហេតុប៉ុន្មាន ?

ឆ. ដោយហេតុ ៣ ប្រការ គឺគ្មានអ្នកត្រាស់ដឹងនូវមគ្គនឹងផល ១ គ្មានអ្នកបដិបត្តិក្នុងសីលសមាធិបញ្ញា ១ គ្មានភេទអ្នកបួស ១ ។

ស. អាពាធ សេចក្តីឈឺចាប់នឹងកើតឡើងដោយហេតុប៉ុន្មាន ?



ឆ. ដោយហេតុ៨ប្រការ គឺៈ បិត្តសមុដ្ឋានា អាពាធា អាពាធកើតអំពីប្រមាត់កំរើក ១ សេម្ហសមុដ្ឋានា អាពាធា អាពាធកើតអំពីស្លេស្មកំរើក ១ វាតសមុដ្ឋានា អាពាធា អាពាធកើតអំពីខ្យល់កំរើក ១ សន្និបាតិកា អាពាធកើតអំពីធាតុ ៤ ប្រជុំគ្នាឲ្យទោស ១ ឧតុបរិណាមជា អាពាធកើតអំពីរដូវប្រែប្រួល ១ វិសមបរិហារជា អាពាធា អាពាធកើតអំពីការរក្សានូវឥរិយាបថមិនស្មើ ១ ឱបក្កមិកា អាពាធា អាពាធកើតអំពីសេចក្តីព្យាយាមខ្លាំង ១ កម្មវិបាកជា អាពាធកើតអំពីកម្ម គឺអកុសល ១ ត្រូវជា ៨ ប្រការដូច្នេះ ។

រោគកើតអំពីកម្ម មានពីរប្រការ គឺៈ រោគដែលពេទ្យរក្សាបាន ហៅថា ឧបបីឡកកម្ម ១ រោគដែលពេទ្យរក្សាមិនបាន គឺថា បើរក្សាក៏ស្លាប់ មិនរក្សាក៏ស្លាប់ ហៅថា ឧបច្ឆេទកកម្ម ១ ។

ហេតុដែលឲ្យកើតខ្យល់មាន ១០ គឺត្រជាក់ណាស់ ១ ក្តៅណាស់ ១ ឃ្លានបាយណាស់ ១ ស្រេកទឹកណាស់ ១ បរិភោគអាហារច្រើនណាស់ ១ ឈររច្រើន ១ អង្គុយច្រើន ១ ដើរច្រើន១

ព្យាយាមច្រើន ១ ខ្យល់កើតដោយអកុសលកម្ម ១ ត្រូវជា ១០ ដូច្នេះ ។

ស. បុណ្យនឹងបាបទាំងពីរ; ខាងណាខ្លាំងជាងខាងណា?

ឆ. បុណ្យខ្លាំងជាងបាប; បើបុគ្គលឯណាធ្វើបាបហើយស្លាប់ទៅ ក៏ធ្លាក់ទៅក្នុងនរក រួចបាកនរកហើយ ក៏មកកើតក្នុងមនុស្ស ឬក៏ទៅកើតក្នុងស្ថានសួគ៌ក៏បាន ប៉ុន្តែបុគ្គលដែលធ្វើកុសល សម្រេចមគ្គផល មានព្រះនិព្វានជាទីបំផុតហើយ មិនបានមកកើតទៀតឡើយ ។

ស. បុគ្គលដែលមិនដឹងច្បាស់នូវបុណ្យនឹងបាប ហើយធ្វើបុណ្យនឹងបាបទៅ តើខាងណាមានផលច្រើនជាង?

ឆ. ដែលមិនបានដឹងច្បាស់នូវបុណ្យហើយធ្វើបុណ្យ បានផលតិចណាស់ ដែលដឹងច្បាស់នូវបុណ្យហើយធ្វើបុណ្យ ទើបបានផលច្រើន ប្រៀបដូចមនុស្សដែលបេះរកទ្រព្យនឹងមិនបេះរកទ្រព្យ ។ មនុស្សដឹងច្បាស់នូវបាប ហើយធ្វើបាប បានផលតិច មនុស្សដែលមិនដឹងច្បាស់នូវបាប ហើយធ្វើបាប



បានផលច្រើន ប្រៀបដូចមនុស្សពីរនាក់ មនុស្សម្នាក់ដែលដឹងច្បាស់នូវថ្នាំពិស រមែងផឹកតែបន្តិចបន្តួច; មនុស្សម្នាក់ដែលមិនដឹងច្បាស់នូវថ្នាំពិស រមែងផឹកច្រើន មិនដឹងច្បាស់នូវប្រមាណ ក៏បានទុក្ខច្រើនក៏ដូច្នោះដែរ ។

ស. ព្រះពុទ្ធអង្គចូលនិព្វានហើយ មិនមានចិត្តមិនមានវិញ្ញាណ នឹងសេចក្តីត្រេកអរ បុគ្គលទាំងពួងនាំគ្នាបូជា នឹងមានផលដោយហេតុអ្វី?

ឆ. ដែលមានផលដោយហេតុគឺចេតនា ព្រោះព្រះសាស្តាត្រាស់ថា ចេតនាហំ ភិក្ខវេ បុញ្ញំ វទាមិ ម្នាលភិក្ខុទាំងឡាយ តថាគតពោលទុកថា បុណ្យនឹងកើតឡើងដោយហេតុគឺចេតនា ប្រៀបដូចភេរីស្គរជ័យ ដែលមានសំឡេង ក៏អាស្រ័យមនុស្សជាអ្នកវាយ ទើបឮ ។

ស. វិវេកទាំង ៣ បានដល់អ្វី?

ឆ. បានដល់កាយវិវេក សេចក្តីស្ងប់កាយ គឺចេញបព្វជ្ជា ឬនៅក្នុងទីស្ងាត់តែម្នាក់ឯង១ ចិត្តវិវេក សេចក្តីស្ងប់ចិត្ត

បានដល់ឈានសមាបត្តិ ១ ឧបធិវិវេក សេចក្តីរម្ងាប់កិលេស គឺកិលេសនិព្វាន រំលត់ភ្លើងកិលេស ១ ។

ស. មនុស្សដូចម្តេចទើបឈ្មោះថា សប្បុរស ?

ឆ. មនុស្សដែលមានហិរិ ឱត្តប្ប សេចក្តីខ្មាសបាប ក្តៅនឹងបាប មិនធ្វើបាប ក្នុងទីស្ងាត់កំបាំង នឹងទីវាល ឈ្មោះថា សប្បុរស ។ មនុស្សដែលមិនមានឱត្តប្ប តែងធ្វើបាបក្នុងទីស្ងាត់កំបាំងនឹងទីវាល ឈ្មោះថា អសប្បុរស ។

ស. មនុស្សដូចម្តេច ទើបឈ្មោះថា មនុស្សពាល ?

ឆ. មនុស្សដែលមិនស្វែងរកប្រយោជន៍ទាំង ៣ គឺៈ ប្រយោជន៍ជាតិនេះ ១ ប្រយោជន៍ជាតិមុខ ១ ប្រយោជន៍ដ៏ប្រសើរ គឺព្រះនិព្វាន ១ ។ មនុស្សដែលមិនធ្វើប្រយោជន៍ទាំង៣ប្រការឲ្យបរិបូណ៌ ឈ្មោះថាមនុស្សពាល មនុស្សដែលញ៉ាំងប្រយោជន៍ទាំង ៣ ប្រការឲ្យបរិបូណ៌ ទើបឈ្មោះថា អ្នកមានប្រាជ្ញា ។

ស. ប្រយោជន៍ជាតិនេះ បានដល់អ្វី ?

ឆ. បានដល់សេចក្តីព្យាយាមឧស្សាហ៍មិនខ្ជិលច្រអូស ១



ជាអ្នកមានបញ្ញារក្សាទ្រព្យឲ្យចំរើនឡើង មិនឲ្យវិនាសទៅ ១ ជាអ្នកដឹងប្រមាណក្នុងការចិញ្ចឹមជីវិត មិនលើសមិនខ្វះ តាមទ្រព្យច្រើនតិច ១ ជាអ្នកសេពគប់កល្យាណមិត្រ ដែលមានចិត្តជាកុសល មិនប្រឡំទៅសេពគប់នឹងមនុស្សពាល ១ ទាំង៤ នេះថាជាប្រយោជន៍ជាតិនេះ ។

ស. ប្រយោជន៍ជាតិមុខ បានដល់អ្វី ?

ឆ. ប្រយោជន៍ជាតិមុខមាន៥ គឺៈ សទ្ធា សេចក្តីជឿបុណ្យបាប ១ សីលវិរតិចេតនា រក្សាកាយវាចា ១ សុតៈ បានស្តាប់ធម៌ទេសនា ១ ចាគៈ បានបរិច្ចាគទាន មានបាយទឹកជាដើម ១ បញ្ញា សេចក្តីពិចារណានូវធម៌ដែលជាកុសលនឹងអកុសល ឲ្យដឹងច្បាស់ ។

ស. ប្រយោជន៍ដ៏ប្រសើរ គឺព្រះនិព្វាននោះ ដូចម្តេចខ្លះ ?

ឆ. ព្រះនិព្វានគួរអាស្រ័យសេចក្តីព្យាយាម ចំរើនវិបស្សនាកម្មដ្ឋាន ឲ្យចាស់ក្លាឡើងក្នុងសន្តាន ជំរះចិត្តឲ្យបរិសុទ្ធចាកកិលេសមានរាគៈជាដើម ។

ស. មនុស្សដូចម្តេច ទើបឈ្មោះថាជាមនុស្សក្នុងព្រះពុទ្ធសាសនា ?

ឆ. មនុស្សដែលមានហិរិឱត្តប្ប ខ្មាសបាប ខ្លាចបាប តាំងនៅក្នុងសីលសមាធិបញ្ញា សេចក្តីបដិបត្តិក្នុងអដ្ឋង្គិកមគ្គទាំង ៨ ប្រការ ទើបឈ្មោះថាជាមនុស្សក្នុងព្រះពុទ្ធសាសនា។ មនុស្សដែលមិនមានហិរិឱត្តប្ប នឹងមិនមានសីលសមាធិបញ្ញា ឈ្មោះថាជាមនុស្សក្រៅសាសនា ។

ស. មនុស្សដូចម្តេច ឈ្មោះថាសម្មាទិដ្ឋិនឹងជាមិច្ឆាទិដ្ឋិ?

ឆ. មនុស្សដែលមានបញ្ញាពិចារណាឃើញនូវកម្ម គឺកុសលនឹងអកុសល ដែលសត្វធ្វើដោយកាយវាចាចិត្ត ជារបស់អ្នកធ្វើ ឲ្យផលដល់អ្នកធ្វើ ។ បំណែកកុសល ឲ្យផលជាសុខ បំណែកអកុសល ឲ្យផលជាទុក្ខ ។ ឃើញយ៉ាងនេះជាដើម ដរាបឃើញអរិយសច្ច ៤ ជាទីបំផុត ឈ្មោះថាសម្មាទិដ្ឋិ បើមិនបានពិចារណាឃើញដូចពោលមកនេះទេ អ្នកនោះឈ្មោះថាជាមិច្ឆាទិដ្ឋិ ។



ស. សេចក្តីឃើញខុស អាស្រ័យធម៌អ្វី ?

ឆ. អាស្រ័យអវិជ្ជា សេចក្តីល្ងង់វង្វេង ។

ស. ល្ងង់វង្វេងដោយធម៌អ្វី ?

ឆ. ល្ងង់ដោយមិនដឹងច្បាស់នូវសង្ខារ វង្វេងស្រឡាញ់នូវសង្ខារ ចិញ្ចឹមសង្ខារ ប្រាថ្នារកសង្ខារ ស្វែងរករបស់ដែលធ្លាប់បាន ធ្លាប់គប់ របស់ដែលមិនធ្លាប់បានមិនធ្លាប់គប់មិនស្វែងរក ។

ស. របស់អ្វីដែលធ្លាប់បានធ្លាប់គប់ ?

ឆ. កាមគុណទាំង ២ គឺៈ កិលេសកាម ១ វត្ថុកាម១។ កិលេសកាម បានដល់រូបសំឡេងក្លិនរសសម្ផស្ស ។ វត្ថុកាម បានដល់មាសប្រាក់ទ្រព្យរបស់ផ្សេង ៗ មានសំពត់ស្លៀកដណ្តប់ជាដើម របស់ទាំងអម្បាលនេះ យើងធ្លាប់បានធ្លាប់គប់មករាល់ ៗ ជាតិហើយ តែមិនទាន់អស់សេចក្តីប្រាថ្នា ខំស្វែងរកត ៗ ទៅទៀត ។ បំណែកធម៌ដែលមិនទាន់ធ្លាប់បាន មិនទាន់ធ្លាប់គប់ គឺមគ្គផលព្រះនិព្វាន ជាទីរលត់កងទុក្ខក្នុងសង្សារ

នាំគ្នាខិលប្រអូស មិនទាំស្វែងរក ទើបឈ្មោះថា អវិជ្ជា សេចក្ដីល្ងង់វង្វេង ក្នុងជំពូកធម៌នេះ ។

ស. ព្រះពុទ្ធអង្គបានត្រាស់ក្នុងលោកតែមួយអង្គ ៗ បើនឹងត្រាស់ម្ដងពីរព្រះអង្គមិនបានឬ ?

ឆ. មិនបានទេ បើព្រះពុទ្ធត្រាស់ម្ដងពីរព្រះអង្គព្រមគ្នា សត្វទាំងឡាយក៏នឹងបែកចេញជា ២ ពួក សត្វដែលរាប់អានព្រះពុទ្ធខាងណេះ ក៏នឹងពោលសរសើរថា ព្រះពុទ្ធអង្គនៃយើងល្អ ត្រាស់ទេសនាពីរោះជាងព្រះពុទ្ធអង្គខាងណោះ; សត្វដែលរាប់អានព្រះពុទ្ធអង្គខាងណោះ ក៏នឹងពោលសរសើរថា ព្រះពុទ្ធអង្គនៃយើងល្អ ត្រាស់ទេសនាពិរោះជាងព្រះពុទ្ធអង្គខាងណេះ ។ ដូច្នេះ សត្វទាំងឡាយ ក៏រវល់តែនឹងពោលផ្សេង ៗ គ្នា បែកជា២ ឬជា ៣ ពួកតទៅទៀត ។

ស. ព្រះពុទ្ធអង្គសំដែងធម៌ទេសនាដូចគ្នាឬទេ ?

ឆ. សំដែងធម៌ដូចគ្នា គឺសីលសមាធិបញ្ញា ។ សេចក្ដីបដិបត្តិផ្លូវសួគ៌និព្វានដូចគ្នា តែនិស្ស័យនៃសត្វទាំងឡាយមិន



ដូចគ្នាទេ, សត្វខ្លះជារាគចរិត ប្រព្រឹត្តទៅតាមរាគៈ; សត្វខ្លះជាទោសចរិត ប្រព្រឹត្តទៅតាមទោសៈ; សត្វពួកខ្លះជាមោហចរិត ប្រព្រឹត្តទៅតាមមោហៈ; សត្វពួកខ្លះជាវិតក្កចរិត ប្រព្រឹត្តទៅតាមវិតក្កៈ សត្វពួកខ្លះជាសទ្ធាចរិត ប្រព្រឹត្តទៅតាមសទ្ធា; សត្វពួកខ្លះជាបញ្ញាចរិត ប្រព្រឹត្តទៅតាមបញ្ញា; សត្វទាំងឡាយមាននិស្ស័យផ្សេង ៗ គ្នាដូច្នេះ សេចក្ដីឃើញពិតមិនដូចគ្នាទេ ព្រោះហេតុនោះ ព្រះពុទ្ធអង្គទើបមិនត្រាស់ដឹងក្នុងលោក ម្ដងពីរព្រះអង្គព្រមគ្នា ។

ស. សត្វទាំងឡាយដែលពោលភាសាផ្សេង ៗ គ្នានោះ ដោយហេតុអ្វី ?

ឆ. ភាសាដែលពោលផ្សេងគ្នាដូច្នោះនោះ ឈ្មោះថា ពោលដោយអគតិទាំង ៤ គឺ: ឆន្ទាគតិ ១ ទោសាគតិ ១ ភយាគតិ ១ មោហាគតិ ១ ។ ដែលចូលចិត្ត ក៏ពោលសរសើរ ដែលមិនចូលចិត្ត ក៏ពោលតិះដៀល ។ ពោលដោយសេចក្ដីខ្លាច ដោយសេចក្ដីវង្វេង; អគតិទាំង ៤ នេះជាផ្លូវ

នៃអបាយភូមិ ។

ស. អាមិសបូជា គួរដល់អ្នកណា មិនគួរដល់អ្នកណា?

ឆ. អាមិសបូជា គ្រហស្ថធ្វើគួរ ប៉ុន្តែភិក្ខុធ្វើមិនគួរទេ ដូចព្រះពុទ្ធដីកាដែលទ្រង់ត្រាស់នឹងព្រះអានន្ទ ក្នុងកាលជិតនឹងរំលត់ខន្ធចូលកាន់ព្រះនិព្វានថា ម្នាលអានន្ទ តថាគតសាងបារមី ៤ អសង្ខេយ្យនឹង ១ សែនកប្ប មិនបានប្រាថ្នាដើម្បីអាមិសបូជាទេ គឺប្រាថ្នាតែបដិបត្តិបូជាមួយដំពូកប៉ុណ្ណោះ ។ ព្រោះហេតុនោះ បានជាសំដែងថា ភិក្ខុមិនគួរធ្វើអាមិសបូជា គួរតែគ្រហស្ថមួយដំពូកធ្វើ; ចំណែកភិក្ខុឲ្យធ្វើតែបដិបត្តិបូជា; បើភិក្ខុទៅធ្វើអាមិសបូជា ដូចគ្រហស្ថហើយ ចំណែកខាងបដិបត្តិបូជាក៏នឹងសាបសូន្យទៅ ព្រោះអាស្រ័យការបញ្ចុះបញ្ចូលអ្នកស្រុករកលាភសក្ការៈ ជួយធ្វើការងារមានធ្វើស្រែចំការ ជួញប្រែ និងធ្វើពេទ្យព្យាបាលរោគ ឲ្យភេសជ្ជៈ ថ្នាំជាដើម នឹងធ្វើជំនួញ មានទិញយកលក់ថ្លៃជាទីបំផុត ខុសបាកធម៌វិន័យជាពុទ្ធបញ្ញត្តិប្រពៃណីព្រះពុទ្ធសាសនា ។



ស. បព្វជ្ជាមានគុណដូចម្ដេច ?

ឆ. មានគុណ ៥ ប្រការ គឺៈ បព្វជ្ជា ជាភេទដ៏ខ្ពស់-ធំ ដែលនឹងទ្រទ្រង់ទុកនូវព្រះអរហត្ត ១ បព្វជ្ជា ជាភេទបរិសុទ្ធ កើតសេចក្ដីជ្រះថ្លាដល់មនុស្សនឹងទេវតាទាំងពួង ១ បព្វជ្ជា ជាភេទដ៏វិសេស ដែលនឹងរម្ងាប់កិលេស មិនសេពគប់នូវមនុស្សពាល ១ បព្វជ្ជា ជាភេទប្រសើរ ឲ្យកើតនូវមគ្គនឹងផល ១ បព្វជ្ជា ជាភេទក្លៀវក្លាខ្សាហ៍ ដែលនឹងញ៉ាំងសីលសមាធិបញ្ញាឲ្យកើតឡើង ១ ត្រូវជា ៥ ប្រការ ។

ស. បព្វជ្ជា មានគុណ ៥ ប្រការដូច្នេះ អ្នកដែលទ្រង់ភេទបព្វជ្ជាហើយ ហេតុម្ដេចទើបសឹកបេញវិញ ?

ឆ. អ្នកដែលទ្រទ្រង់ភេទបព្វជ្ជា មានឧបនិស្ស័យតិច មិនក្លាហាន មានកិលេសដ៏ក្រាស់ មានបញ្ញាដ៏ទន់ទាប មិនពិចារណាឲ្យឃើញគុណក្នុងបព្វជ្ជា ឲ្យឃើញទោសក្នុងគ្រហាវាស ប្រៀបដូចមនុស្សអនាថា ខ្សត់ទ្រព្យអប្បញ្ញា ដល់បានសម្បត្តិជាព្រះរាជា ក៏រក្សាទុកមិនបាន ។

ស. បព្វជ្ជាមានប៉ុន្មានប្រការ ?

ឆ. មាន ៤(១) ប្រការ គឺៈ ឧបជីវិកា បួសក្នុងសាសនា អាស្រ័យចិញ្ចឹមជីវិតដោយសិល្បវិជ្ជាផ្សេង ៗ ផ្លូវគ្រហាវាស លួមចិញ្ចឹមជីវិតបានមួយជាតិ ១ ឧបកីឡិកា បួសលេង ៗ គឺបានខាងអ្នកបួសដែលចូលចិត្តតែនឹងល្បែងផ្សេង ៗ មានលេងបាស្កា នឹងអុកក្រឡាបត្រង្គជាដើម ១ ឧបទូសិកា បួសប្រទូសរ៉ាយសាសនា បានខាងអ្នកបួសដែលមិនយកចិត្តទុកដាក់បដិបត្តិតាមធម៌វិន័យ គឺប្រព្រឹត្តវិទ្ធាប្រឡេសប្រើស តាមទំនើងចិត្ត ផ្ទុយពីពុទ្ធប្បញ្ញត្តិនឹងពុទ្ធានុញ្ញាត ១ ឧបមុយ្ហិកា បួសដោយសេចក្ដីវង្វេងវេងវោងដូចក្របីខ្វាក់ភ្នែក ញាំញីសាសនា មិនស្គាល់នូវលទ្ធិសាសនា គឺមិនសូត្ររៀន មិនសិក្សាធម៌វិន័យ១ ឧបនិស្សរណិកា បួសសិក្សាសូត្ររៀនធម៌វិន័យ សង្រួមកាយវាចា ចំរើនភាវនាកម្មដ្ឋាន ដើម្បីនឹងធ្វើឲ្យជាក់ច្បាស់នូវព្រះនិព្វាន១ ។

(១) បើរាប់ឧបកិឡិកានិង ត្រូវជា ៥ ។



ស. សភាវៈដូចម្ដេចជាទីតាំងនៃមគ្គផលនិព្វាន ?

ឆ. សីលជាទីតាំងនៃសមាធិ ៗ ជាទីតាំងនៃបញ្ញា ៗ ជាទីតាំងនៃមគ្គផលនិព្វាន ។ អ្នកដែលនឹងសម្រេចមគ្គផលនិព្វាន ត្រូវអាស្រ័យសីល ដោយព្រះបាលីថា សីលេន និព្វុតឹ យន្តិ ជនទាំងឡាយនឹងទៅកាន់ព្រះនិព្វាន ដោយកម្លាំងនៃសីល បើមិនមានសីលហើយ ក៏ទៅកាន់ព្រះនិព្វានមិនបាន ។

ស. ព្រះនិព្វាននោះ មានស្ថានដូចម្ដេច ?

ឆ. ព្រះនិព្វាននោះ ជាទីរលត់ភ្លើងកិលេសភ្លើងទុក្ខ ។ ឯភ្លើងកិលេស គឺរាគៈទោសៈមោហៈ, ភ្លើងទុក្ខ គឺការកើត-ចាស់-ឈឺ-ស្លាប់ ដែលវិលវល់នៅក្នុងវដ្ដសង្សារ ។

ស. សភាវៈដូចម្ដេច ជាហេតុជាបច្ច័យឲ្យវិលវល់ ?

ឆ. តណ្ហាជាតួហេតុ អវិជ្ជាជាតួបច្ច័យ កុសលអកុសលជាតួវិបាក នាំបដិសន្ធិឲ្យកើតក្នុងកំណើតទាំង ៤ តាមយថាកម្ម ។

ស. នឹងយកធម៌អ្វីរំលត់អវិជ្ជាតណ្ហា ?

ឆ. យកបញ្ញាដែលស្គាល់ព្រះត្រៃលក្ខណ៍ ពិចារណាខន្ធទាំង ៥ គឺកងរូប-កងវេទនា-កងសញ្ញា-កងសង្ខារ-នឹងកងវិញ្ញាណ ឲ្យឃើញជា អនិច្ចំ មិនទៀង ទុក្ខំ ជាទុក្ខតែងបែកធ្លាយ អនត្តា មិនមែនខ្លួនប្រាណ បានព្រមទាំងបញ្ចក្ខន្ធមិនចូលទៅប្រកាន់ខ្ជាប់ដោយឧបាទាន ធ្វើចិត្តឲ្យជាញាណុបេក្ខា ទើបនឹងរំលត់អវិជ្ជាតណ្ហាបាន ។

ស. អវិជ្ជាតណ្ហាដែលរលត់ដោយបញ្ញា ដែលស្គាល់ព្រះត្រៃលក្ខណ៍នោះ ជាលោកិយឬលោកុត្តរៈ ?

ឆ. ជាលោកិយ, កាលបើបញ្ញាចាស់ក្លា ពិចារណាព្រះអរិយសច្ចទាំង៤ធម្មធាតុជាលោកិយ ទើបប្រែទៅជាលោកុត្តរ ។ សេចក្ដីថា បញ្ញាដែលពិចារណាឃើញច្បាស់ នូវអរិយសច្ចទាំង ៤ នោះ ជាលោកុត្តរបញ្ញា ។

ស. អរិយសច្ចទាំង ៤ បានដល់ធម៌អ្វីខ្លះ ?

ឆ. បានដល់បញ្ញាពិចារណាឃើញកងទុក្ខ មានជាតិទុក្ខជាដើម១ បញ្ញាពិចារណាឃើញហេតុដែលឲ្យកើតកងទុក្ខ គឺតួ



តណ្ហាទាំង ៣ មានកាមតណ្ហាជាដើម ១ បញ្ញាពិចារណាឃើញទីរលត់ទុក្ខ គឺព្រះនិព្វាន ១ បញ្ញាពិចារណាឃើញសេចក្ដីបដិបត្តិ គឺសីលសមាធិបញ្ញាជាផ្លូវព្រះនិព្វាន ១ ។

ស. សភាវៈដូចម្ដេច ឈ្មោះថា ព្រះនិព្វាន ?

ឆ. ទីរលត់កងទុក្ខគឺមិនកើត មិនចាស់ មិនឈឺ មិនស្លាប់នោះ ទើបឈ្មោះថា និព្វាន ។

ស. ធម៌អ្វីជាហេតុជាបច្ច័យនៃព្រះនិព្វាន ?

ឆ. ព្រះនិព្វាន មិនមានហេតុមិនមានបច្ច័យ; ព្រះនិព្វានជាអសង្ខតធម៌ គឺមិនមានហេតុមិនមានបច្ច័យប្រជុំតាក់តែង ។

ស. មគ្គផលមិនមែនជាហេតុជាបច្ច័យទេឬ ?

ឆ. មគ្គ គ្រាន់តែជារបស់សម្លាប់កិលេសឲ្យស្លាប់; ផលក៏គ្រាន់តែសោយនូវសុខដែលអស់កិលេសប៉ុណ្ណោះ នឹងបានជាហេតុជាបច្ច័យនៃព្រះនិព្វានក៏ទេ ។

ស. នឹងដឹងច្បាស់នូវព្រះនិព្វាននោះ ដោយហេតុអ្វី ?

ធ. ដឹងដោយសេចក្ដីដែលមិនមានកិលេសក្នុងសន្ដាន ព្រោះហេតុនោះ ព្រះអង្គកបិតាញទើបពោលថា បុថុជ្ជន ដែលមិនមានកិលេស អង្គុយជាមួយនឹងព្រះអរិយៈ នឹងចង្អុលថា ឯណាជាបុថុជ្ជន ឯណាជាព្រះអរិយៈ ក៏ជាមិនបាន ព្រោះមិនមានកិលេសដូចគ្នា ។

ស. ព្រះនិព្វានមានទីតាំងទីអាស្រ័យ មានពណ៌សណ្ឋានដូចម្ដេច ?

ធ. មិនមានទីតាំងទីអាស្រ័យ មិនមានពណ៌សណ្ឋាន គ្រាន់តែជាទីរលត់នៃកងទុក្ខប៉ុណ្ណោះ ប្រៀបដូចខ្យល់នឹងអាកាស មិនមានទីលំនៅទីអាស្រ័យ មិនមានពណ៌សណ្ឋានឲ្យប្រាកដទេ ។ មួយទៀត សត្វទាំងឡាយ ដែលមានរូបមានចិត្តវិញ្ញាណ អាស្រ័យកម្ម គឺកុសលនឹងអកុសលឲ្យកើតឡើង, ដើមរុក្ខលតាវល្លិជាដើម ដែលមិនមានចិត្តវិញ្ញាណអាស្រ័យឧតុ គឺរដូវឲ្យកើតឡើង ។ ឯព្រះនិព្វាន មិនមានអាស្រ័យអ្វី មិនមានហេតុបច្ច័យឲ្យកើតឡើងទេ ។ មួយទៀត



ព្រះនិព្វាន អ្នកដែលមានកិលេស មិនអាចដឹងដោយភ្នែក ត្រចៀក ច្រមុះ អណ្ដាត កាយ ចិត្តឡើយ ។

ស. បំណាច់បងសត្វទុកក្នុងវដ្ដសង្សារ មានប៉ុន្មាន ?

ធ. មាន ១០ គឺ មាតា ១ បិតា ១ ភរិយា ១ បុត្រ១ ញាតិ១ មិត្រ១ ទ្រព្យ១ លាភ១ យស ១ បញ្ចកាមគុណ ១ ត្រូវជា ១០ ។

ស. ទានដែលទាយកឲ្យហើយ នឹងឧទ្ទិសបំណែកកុសលដល់ពួកញាតិ មានមាតាបិតាជាដើម ដែលស្លាប់ទៅនោះ នឹងបានដល់ដែរឬទេ ?

ធ. បានដល់ក៏មាន មិនបានដល់ក៏មាន ។

ស. ទីឯណាដែលបានដល់ ទីឯណាដែលមិនបានដល់?

ធ. ទីដែលបានដល់នោះ គឺញាតិដែលស្លាប់ទៅកើតជាបរទត្តូបជីវីប្រេត មករង់ចាំទទួលបំណែកកុសលអំពីពួកញាតិ; ពួកញាតិធ្វើកុសលឧទ្ទិសឲ្យទើបបាន ។ សេចក្ដីថា កុសលដែលនឹងសម្រេចដល់ពួកប្រេតនោះ លុះតែដល់ព្រមដោយ

អង្គ៣ គឺទានដែលទាយកឲ្យដល់អ្នកមានសីល ១ ទាយកតាំងចិត្តឧទ្ទិសឲ្យដល់ប្រេត ១ ប្រេតនោះបានអនុមោទនា ១ ។ ទីដែលមិនបាននោះគឺៈ សត្វនរក ១ ប្រេតនោះមិនមែនជាបរទត្តូបជីវីប្រេត ១ អសុរកាយ ១ សត្វតិរច្ឆាន ១ មនុស្ស១ ទេវតា ១ មារ ១ ព្រហ្ម ១ ទាំងអស់នេះមិនបានមកទទួលចំណែកផលទេ ។

ស. ផលទានដែលទាយកឧទ្ទិសឲ្យដល់ប្រេតហើយ ប្រេតក៏មិនបានមកទទួលយកៈទៅ តើផលទាននោះនឹងទៅតាំងនៅឯណា? នឹងបានជារបស់អ្នកណា? អ្នកណានឹងទទួលយក?

ឆ. ផលទាននោះ ជារបស់ទាយកអ្នកឲ្យ; ទាយកអ្នកឲ្យជាអ្នកទទួលផល; ប្រៀបដូចវត្ថុទ្រព្យផ្សេង ៗ ដែលបុគ្គលឲ្យដល់ញាតិ នឹងមិត្រដែលមកកាន់ផ្ទះ; បើញាតិមិត្រមិនទទួលយករបស់នោះទេ របស់អស់នោះក៏ត្រឡប់បានមកជារបស់អ្នកឲ្យវិញ អ្នកដទៃនឹងមកយកទៅណាពុំបាន ។ មួយទៀត



បើនឹងឧទ្ទិសកុសលដល់មាតាបិតា ឲ្យឧទ្ទិសថាៈ ឥទំ មេ ទានំ មាតាបិតូនំ មេតានំ ហោតុ ។ បើឧទ្ទិសឲ្យដល់ពួកញាតិថាៈ ឥទំ មេ ទានំ ញាតីនំ មេតានំ ហោតុ ។

ស. ប្រេតដែលទទួលចំណែកកុសលហើយ នឹងសោយផលដូចម្តេច?

ឆ. បានសោយសេចក្តីសុខ គឺបានអាហារបាយទឹកបរិភោគជាដើម ហើយរួចចាកកំណើតប្រេតវិស័យ បានទៅកើតក្នុងសុគតិ មានមនុស្សជាដើម ដោយអំណាចកុសលដែលបានទទួលចំណែកផលបុណ្យនោះ ។

ស. ធ្វើបុណ្យហើយ ក៏ផ្សាយចំណែកបុណ្យទៅឲ្យអ្នកដទៃ ៗ ក៏អាចទទួលបាន ប៉ុន្តែបើធ្វើបាបវិញ ហើយផ្សាយចំណែកបាបទៅឲ្យអ្នកដទៃ តើអ្នកដទៃនោះបានទទួលឬទេ?

ឆ. មិនបានទេ ដ្បិតអំពើបាបមានផលតិច ផ្សាយទៅមិនបាន ប្រៀបដូចជាទឹកភ្លៀងមួយដំណក់ ធ្លាក់ចុះមកពីអាកាស មិនអាចនឹងទទឹកទូទៅក្នុងផ្ទៃផែនដីបាន ។ ចំណែក

កុសល មានផលច្រើន អាចផ្សាយទៅបាន ប្រៀបដូចភ្លៀងមេឃធំ អាចនឹងទទឹកទូទៅក្នុងផ្ទៃផែនដីបាន ។

ស. ធ្វើបុណ្យ ឲ្យផលទៅកើតក្នុងសុគតិ ធ្វើបាបក៏ឲ្យផលទៅកើតក្នុងនរក ហេតុម្តេចទើបពោលថា បាបមានផលតិច បុណ្យមានផលច្រើនវិញ ?

ឆ. បុណ្យកុសល បុគ្គលធ្វើដោយចិត្តសោមនស្ស លុះធ្វើហើយ ក៏មានចិត្តផូរផង់ជ្រះថ្លា បើកាលណាគិតដល់បុណ្យដរាបទៅ ក៏បានសេចក្តីជ្រះថ្លាគ្រប់ ៗ ខណៈ បុណ្យនោះក៏ចំរើនច្រើនឡើងទៅ ទើបពោលថា បុណ្យកុសលមានផលច្រើន ។ បំណែកធ្វើដោយចិត្តសៅហ្មង គឺសេចក្តីក្រោធលោភវង្វេង កាលធ្វើហើយ ក៏ឲ្យកើតសេចក្តីក្តៅក្រហាយ គិតនឹកកាលណា ក៏ឲ្យក្តៅចិត្តកាលណោះ ។

មួយទៀត បាបជារបស់អាក្រក់ មិនមានអ្នកណាចង់បាន សូម្បីនឹងបែងចែកឲ្យគេ ៗ ក៏មិនយក ។

ស. ការយល់សប្តិឃើញថា ធ្វើបុណ្យក្តី ធ្វើបាបក្តី



នឹងបានបុណ្យ ឬនឹងបានបាបខ្លះដែរឬទេ ?

ឆ. មិនបានបុណ្យមិនបានបាបទេ ព្រោះមិនមានចេតនានឹងសតិ សូម្បីជាភិក្ខុក៏មិនត្រូវអាបត្តិដោយការយល់សប្តិនោះ ។

ស. ទេវទូត មានប៉ុន្មានប្រការ ?

ឆ. មានពីរប្រការ គឺៈ ទេវទូតព្រះពោធិសត្វ៤ គឺមនុស្សចាស់ជរា ១ មនុស្សឈឺ ១ មនុស្សស្លាប់ ១ មនុស្សអ្នកបួស១ ត្រូវជា ៤ នេះប្រការ ១ ឯប្រការទី ២ គឺទេវទូតនៃព្រះយមរាជ មាន ៥ គឺ ទារកក្មេងតូច ១ មនុស្សចាស់ជរា ១ មនុស្សឈឺ១ មនុស្សស្លាប់ ១ មនុស្សអ្នកទោស ១ ត្រូវជា ៥ ។ សេចក្តីថា ព្រះពោធិសត្វឃើញទេវទូត ៤ យ៉ាង ទើបចេញបព្វជ្ជា ។ រីឯស្តេចយមរាជ តោងដណ្តឹងសួរទេវទូតទាំង ៥ ដល់សត្វនរកកាលចុះទៅដល់ជាដំបូង ។ សេចក្តីថា សត្វទាំងឡាយស្លាប់ហើយ ក៏ចុះទៅកាន់សំណាក់នៃស្តេចយមរាជមុន; ស្តេចយមរាជទើបសួរទេវទូតទាំង ៥ មានរកជាដើម បើសត្វជំពូកណាប្រាប់មិនបានហើយ នាយនិរយបាលក៏នាំទៅកាន់

នរក បើសត្វជំពូកណាប្រាប់ទេវទូតបានហើយ ក៏លែងទៅ ។

ស. សត្វទាំងឡាយដែលស្លាប់ហើយ ត្រូវទៅកាន់សំណាក់ស្តេចយមរាជឬ?

ឆ. ទៅតែសត្វដែលមានកម្មស្រាល ៗ បំណែកសត្វដែលមានកម្មធ្ងន់ ៗ គឺអនន្តរិយកម្មទាំង ៥ នឹងសត្វដែលជានិយតមិច្ឆាទិដ្ឋិអប្បាលនេះ ស្លាប់ហើយទៅកើតក្នុងនរក ដោយអំណាចនៃកម្ម មិនត្រូវទៅកាន់សំណាក់ស្តេចយមរាជ ។

ស. ភ័យក្នុងវដ្តសង្សារ មានប៉ុន្មានប្រការ?

ឆ. មាន ៤ ប្រការ គឺ ជាតិ សេចក្តីកើត ១ ជរា សេចក្តីចាស់ ១ ព្យាធិ សេចក្តីឈឺ ១ មរណៈ សេចក្តីស្លាប់ ១ ទាំង ៤ នេះជាភ័យធំក្នុងវដ្តសង្សារ ប្រៀបដូចជាចោរ ៤ នាក់រំពៃតាមបៀតបៀនសត្វនៅក្នុងភពទាំង ៣ ។

ស. ធ្វើម្តេចទើបនឹងរត់រួចអំពីចោរទាំង ៤ នាក់នេះបាន?

ឆ. ត្រូវអាស្រ័យសេចក្តីព្យាយាម១ អាស្រ័យខន្តី សេចក្តីអត់ធន់១ អាស្រ័យបញ្ញាពិចារណាឃើញកងទុក្ខ ១ អាស្រ័យ



សទ្ធា សេចក្តីជឿគុណព្រះរតនត្រៃ ១ ។ ព្រមដោយធម៌ទាំង ៤ នេះ ទើបនឹងរត់បាន ដ្បិតមាននិទានថា មានបុរសម្នាក់ រត់ឃ្លាបចោរ ៤ នាក់ វាដេញទៅដល់ទៀបមាត់ស្ទឹង បុរសនោះនឹងរកទូកឬក្បូនឆ្លងទៅមិនបាន ឃើញតែសាកអសុភដែលអណ្តែតមកជិតមាត់ប្រាំង បុរសនោះក៏លោតចុះទៅកៀកយកសាកអសុភ ជាទីអាស្រ័យ ហែលឆ្លងទឹកទៅបានដល់ត្រើយ ហើយក៏បោលនូវសាកអសុភ រត់រួចអំពីចោរទាំង ៤ នាក់ទៅបាន ។

ស. សាកអសុភនោះ បានដល់អ្វី?

ឆ. បានដល់រាងកាយរបស់យើង ដែលជារបស់គួរខ្ពើមរអើម មានក្លិនស្អុយឃើញនឹងភ្នែក ។ បុរសនោះ បានដល់ព្រះយោគាវចរ ដែលចំរើនព្រះកម្មដ្ឋាន សម្រេចដល់ព្រះនិព្វាន មិនមានកើត-ចាស់-ឈឺ-ស្លាប់ វៀរចាកវិលវល់នៅក្នុងវដ្តសង្សារ មានតែសេចក្តីសុខដ៏ប្រសើរនិរាសភ័យ ។

ស. នឹងបដិបត្តិដូចម្តេច ទើបនឹងបានព្រះនិព្វាន ,

ធ. ឲ្យបដិបត្តិយកដូចសត្វលលកនឹងទទា កុំយកដម្រាប់ដូចជ្រូកស្រុក ។ សេចក្តីថា សត្វលលកនឹងទទាទាំង២ នេះ បុគ្គលនឹងចិញ្ចឹមរក្សាទុកឲ្យបរិភោគចំណីឆ្អែតយ៉ាងណាក៏ដោយ ក៏នៅតែមានចិត្តគិតតែនឹងរត់ចេញចាកទ្រុងទៅជានិច្ច មិនបានគិតនឹងសម្ងំ ក្រាញនៅក្នុងទ្រុង ដូចម្តេចមិញ យើងទាំងឡាយដែលកើតមកជាមនុស្ស ទាំងស្ត្រីទាំងបុរស នៅក្នុងភពវដ្តសង្សារនេះ ក៏ត្រូវតែគិតប្រារព្ធរកឧបាយដែលនឹងចេញចាកជាតិចាកភពដូច្នោះដែរ ។ មួយទៀត ជ្រូកទាំងឡាយ បុគ្គលចិញ្ចឹមឲ្យបរិភោគឆ្អែតហើយ ក៏វង្វេងងេងងោងដេកលក់នៅក្នុងទ្រុង មិនគិតរត់ចេញចាកទ្រុងដូចម្តេចមិញ មនុស្សជាបុថុជ្ជនទាំងឡាយ ដែលវង្វេងទៅដោយអវិជ្ជាតណ្ហា នឹងកាមគុណទាំង ៥ ក៏ដូចគ្នានឹងជ្រូកស្រុកនោះដែរ ។

ស. ធ្វើដូចម្តេច ទើបនឹងឃើញគុណព្រះនិព្វាន ?

ធ. ធ្វើបញ្ញាឲ្យច្បាស់ក្លា ពិចារណានូវទោសក្នុងសង្ខារ



គឺសេចក្តីកើតចាស់ឈឺស្លាប់ ដែលវិលវល់នៅក្នុងភពទាំង ៣ មានកាមភពជាដើម លុះចិត្តនឿយណាយឆ្ងាយចាកកិលេសព័ន្ធព័ទ្ធចិត្ត គឺសេចក្តីចង់បានត្រេកអរក្នុងប្រយោជន៍លោកិយ គឺកាមសុខនោះហើយ ទើបនឹងឃើញគុណព្រះនិព្វាន ដូចផ្លេកបន្ទោរមួយភ្លែត ៗ ។

ស. ធ្វើដូចម្តេច បញ្ញានឹងច្បាស់ក្លា ?

ធ. ឲ្យមានសេចក្តីស្រឡាញ់ក្នុងកងការកុសល មានទានសីលជាដើម នឹងសេពគប់មនុស្សអ្នកប្រាជ្ញ ដែលជាបណ្ឌិតជាតិ ធ្វើដូច្នេះឯង ទើបនឹងកើតបញ្ញាច្បាស់ក្លាឡើងក្នុងសន្តាន ដូចព្រះពោធិសត្វនឹងបានត្រាស់ដឹងនូវពោធិញាណ ក៏អាស្រ័យនូវកងការកុសល ដែលព្រះអង្គបំពេញមកអស់កាលដ៏យូរ ។

ស. គុណព្រះនិព្វាននោះ តើដូចម្តេច ?

ធ. ព្រះនិព្វានមានគុណ គឺរំលត់បង់នូវសង្ខារទាំងពួង ដូចបាលីថា: សព្វសង្ខារសមថោ ព្រះនិព្វានជាទីរំលត់

នូវសង្ខារទាំងពួង ។

ស. អ្វីហៅថាសង្ខារ ?

ឆ. សង្ខារមាន ២ គឺសង្ខារធម៌ បានដល់បុណ្យបាប ១ សង្ខារលោក បានដល់ទឹកដីភ្លើងខ្យល់ជាដើម ១ ។

ស. ព្រះនិព្វាននៅជិតឬឆ្ងាយ ?

ឆ. មិនជិតមិនឆ្ងាយ នៅត្រង់ទីរលត់អវិជ្ជាទាំងឡាយ រលត់ជាតិរលត់ភពនេះឯង ហៅថា ព្រះនិព្វាន ។

ស. ព្រះសោតាលោកលះបានធម៌ប៉ុន្មាន ?

ឆ. លោកលះ សក្កាយទិដ្ឋិ សេចក្តីឃើញដ៍វៀវការវិធី មិច្ឆាបដិបត្តិ១ លោកលះវិចិកិច្ឆា សេចក្តីសង្ស័យក្នុងព្រះរតន-គុណ បុណ្យបាប ១ លោកលះសីលព្វតបរាមាស សេចក្តីស្ទាប អង្អែលនូវសីលព្វត្ត គឺសេចក្តីបដិបត្តិខាងក្រៅព្រះពុទ្ធសា-សនា ១ ។

ស. ព្រះសោតាមានប៉ុន្មានពួក ?

ឆ. មាន ៣ ពួក គឺ ឯកពិជីសោតា នឹងមកកើតក្នុង



កាមធាតុមួយជាតិទៀត ១ កោលំកោលសោតា នឹងមកកើតក្នុងកាមធាតុ ៦ ជាតិទៀត ១ សត្តក្ខត្តុំបរមសោតា នឹងមកកើតក្នុងកាមធាតុ ៧ ជាតិទៀតយ៉ាងក្រៃលែង ។

ព្រះសកិទាគាមី លោកលះកិលេសដូចព្រះសោតាដែរ ប៉ុន្តែលោកសង្កត់សង្កិន លះកាមឆន្ទៈ ព្យាបាទៈ ឲ្យស្តើងជាងព្រះសោតា ។ ព្រះអនាគាមី លោកលះកិលេសបាន ៥ គឺ សក្កាយទិដ្ឋិ១ វិចិកិច្ឆា១ សីលព្វត្ត១ កាមឆន្ទៈ១

ព្រះអរហត្ត លោកលះកិលេសបាន ១០ គឺៈ សក្កាយទិដ្ឋិ ១ វិចិកិច្ឆា ១ សីលព្វត្ត ១ កាមឆន្ទ ១ ព្យាបាទ ១ រូបរាគ ១ អរូបរាគ ១ មានះ ១ ឧទ្ធច្ចៈ ១ អវិជ្ជា ១ ។

ស. កាយនឹងចិត្តទាំង ២ នេះ ណាធំជាងណា ?

ឆ. មិនមានណាធំជាងណាទេ ជារបស់អាស្រ័យនូវគ្នានឹងគ្នា កាយបែកហើយ ចិត្តក៏រលត់; ចិត្តរលត់ហើយ កាយក៏បែក ប្រៀបដូចអណ្តាតប្រទីប អាស្រ័យនូវប្រឆេះនឹងប្រេង លុះអស់ប្រឆេះនឹងប្រេងហើយ អណ្តាតប្រទីបក៏រលត់ទៅ ។

ស. កាយនឹងចិត្ត អាស្រ័យធម៌អ្វី ?

ឆ. អាស្រ័យនូវសង្ខារ គឺបុណ្យនឹងបាបតាក់តែងឲ្យកើតឡើង ហើយក៏តាំងនៅតាមកម្លាំងនៃសង្ខារ ។

ស. មនុស្សដែលមិនបានមគ្គផលនោះ ដោយហេតុដូចម្តេច ?

ឆ. ដោយហេតុ ២ ប្រការ គឺៈ មនុស្សមានឧបនិស្ស័យតិច មិនគួរដល់មគ្គផល ១ ភិក្ខុត្រូវបារាជិក ក៏ដាច់បាកមគ្គផល ១ ។

ស. បារាជិក មានប៉ុន្មានប្រការ ?

ឆ. មាន ៤ ប្រការគឺៈ ភិក្ខុមានសីលទៅសេពមេថុន ១ ទៅលួចទ្រព្យដែលម្ចាស់គេហួងហែងរក្សាទុក មានដំឡៃតាំងពីមួយបាទ(១)ឡើងទៅ ១ សម្លាប់មនុស្សឲ្យស្លាប់ ១ ពោលអួតមគ្គផលដែលខ្លួនមិនបានដល់ ១ ទាំង ៤ នេះ ឈ្មោះថា បារាជិក ពោលដោយចំណែកភិក្ខុ ។

(១) ក្នុងវិន័យថា កាំងពី ៥ មាសកឡើងទៅ ។



ចំណែកគ្រហស្ថ បារាជិកមាន ៥ គឺ សម្លាប់បិតាឲ្យស្លាប់ ១ សម្លាប់មាតា ១ សម្លាប់ព្រះអរហន្ត ១ ធ្វើព្រះលោហិតុប្បាទ ១ ធ្វើសង្ឃភេទ ១ ទាំង ៥ នេះឈ្មោះថា បារាជិក ឬថា អនន្តរិយកម្ម ។

ស. ពាក្យថា បារាជិក នេះ ប្រែថាដូចម្តេច ?

ឆ. បារាជិក ប្រែថា អ្នកបាលបាញ់ព្រះពុទ្ធសាសនា គឺដាច់បាកមគ្គផលនេះឯង ។

ស. មនុស្សដែលត្រូវបារាជិកនោះ ហេតុម្តេចទើបមិនបានមគ្គផល ?

ឆ. បានជាមិនបានមគ្គផលនោះ ព្រោះអ្នកត្រូវបារាជិកនោះ ប្រៀបដូចមនុស្សកំបុតក្បាល ឬដូចត្នោតកំបុតក មិនអាចនឹងតឲ្យជាប់វិញបាន ឬដូចជាអង្កាម មិនអាចនឹងសាបព្រោះឲ្យដុះពន្លកល្អឡើងបាន ។

ស. ភិក្ខុត្រូវបារាជិកហើយ នឹងឲ្យធ្វើដូចម្តេច ?

ឆ. ឲ្យសឹកទៅជាគ្រហស្ថ បដិបត្តិជាឧបាសក រក្សា

ព្រះត្រៃសរណគមន៍ នឹងសីល ៥-៨ កម្មបថ ១០ ឬមួយនឹងបួសជាសាមណេរ បដិបត្តិយកផ្លូវសួគ៌ក៏បាន តែកុំកាន់ភេទជាភិក្ខុ ទៅរួមសំវាសនឹងភិក្ខុដទៃ ។ កាលណាកាន់ភេទរួមសំវាសហើយ ក៏នឹងឃាត់ផ្លូវមនុស្សសួគ៌និព្វានទាំងអស់ ។

ស. ធ្វើកុសលនឹងមានផលច្រើនដោយហេតុអ្វី ?

ឆ. ធ្វើកុសលនឹងមានផលច្រើន ដោយអំណាចសីល ។ ដ្បិតថា បរិច្ចាគទាន ធ្វើបូជា នឹងស្តាប់ធម៌ទេសនា ចំរើនភាវនាព្រះកម្មដ្ឋាន ឬនឹងសាងព្រះវិហារ-កុដិ នឹងអាវាស-ទីលំនៅ សីលជាគ្រឿងទំនុកបំរុងឲ្យមានផលច្រើន ។

ស. សីលនឹងបរិសុទ្ធដោយហេតុអ្វី ?

ឆ. សីលនឹងបរិសុទ្ធ អាស្រ័យសំវរៈ ៥ គឺ សីលសំវរៈ សេចក្តីសង្រួមក្នុងសីល ដែលខ្លួនសមាទាន ១ ឥន្ទ្រិយសំវរៈ សេចក្តីសង្រួមភ្នែក ត្រចៀក ប្រមុះ អណ្តាត កាយ ចិត្ត ១ ខន្តីសំវរៈ សេចក្តីសង្រួមតាំងខ្ជាប់ក្នុងខន្តី ១ វីរិយសំវរៈ សេចក្តីសង្រួបដោយព្យាយាម ១ បញ្ញាសំវរៈ សេចក្តីសង្រួមដោយ



បញ្ញា ១ ។

ស. ហេតុដែលនាំឲ្យយល់សប្តិ មានប៉ុន្មានប្រការ ?

ឆ. មាន ៦ប្រការ គឺៈ ធាតុកំរើក ១ សេម្ហៈកំរើក ១ រាគៈកំរើក ១ ទេវតាសំហរៈ ១ ប្រមាត់កំរើក ១ ចិត្តសន្សំធ្វើនូវបុណ្យ-បាបទុកច្រើន ១ ។

ស. កាលនឹងយល់សប្តិឃើញនោះ ភ្ញាក់ហើយឬកំពុងលក់ ?

ឆ. មិនភ្ញាក់មិនលក់ ព្រោះសេចក្តីលក់ស្និទ្ធ ចិត្តឃាងចុះទៅកាន់ភវង្គ ស្ងប់ស្ងៀមមិនបង្កើតនិមិត្ត សេចក្តីយល់សប្តិ បើភ្ញាក់ហើយ ចិត្តញាប់ញ័រ មិនកើតនិមិត្ត សេចក្តីយល់សប្តិ ។

ស. សេចក្តីលក់មានប៉ុន្មានប្រការ ?

ឆ. មាន ៣ ប្រការ គឺ អាទិ ខាងដើម ១ មជ្ឈិមំ ខាងកណ្តាល ១ បរិយោសានំ ទីបំផុត ១ ។ អាទិ ខាងដើមនោះ លក់នៅមានសតិ; មជ្ឈិមំ លក់ក្នុងកណ្តាលនោះ លក់មិនមានសតិនឹងចេតនា; បរិយោសានំ ទីបំផុតនោះ លក់ដោយ

ចិត្តយាងចុះកាន់ភវង្គស៊ប់ ចិត្តដូចជាព្រះអរិយៈចូលនិរោធ សេចក្តី ឋា លក់ក្នុងកណ្តាល ឲ្យកើតនិមិត្តក្នុងយល់សប្តិ ។

ស. មនុស្សដែលយល់សប្តិឃើញថា បានធ្វើបុណ្យ-បាបនោះ នឹងបានបុណ្យឬនឹងបានបាបខ្លះឬទេ ?

ឆ. មិនបានបុណ្យមិនបានបាបអ្វីទេ ដ្បិតមិនមានសតិនឹងចេតនា ជាហេតុដែលនឹងឲ្យកើតបុណ្យបាប ។ បុណ្យ-បាបអាស្រ័យនឹងចេតនា ព្រោះព្រះពុទ្ធអង្គត្រាស់ថា ចេតនាហំ ភិក្ខវេ បុញ្ញំ ទាបំ វទាមិ ប្រែថា ម្នាលភិក្ខុទាំងឡាយ តថាគតពោលថា បុណ្យនឹងបាប អាស្រ័យចេតនា ។

ស. សត្វទាំងឡាយស្លាប់ហើយ អាស្រ័យហេតុអ្វីដែលនាំឲ្យទៅកើតក្នុងភពថ្មី ?

ឆ. អាស្រ័យបុព្វនិមិត្ត ដែលកើតក្នុងមនោទ្វារ មាន ៣ ប្រការ គឺ កម្ម១ កម្មនិមិត្ត១ គតិនិមិត្ត១ ។ កម្មនោះបានដល់កុសលអកុសល ដែលសត្វទាំងឡាយធ្វើទុក នឹងរឭកបាន កាលជិតនឹងស្លាប់ ដូចជាភិក្ខុ ១ អង្គក្នុងសាសនា



ព្រះពុទ្ធកស្សប ធ្វើស្លឹកវែឲ្យដាច់ លុះដល់ជិតនឹងស្លាប់ ក៏រឭកដល់កម្មដែលខ្លួនបានធ្វើទុក លុះអស់ព្រះជន្មទៅ ក៏ទៅកើតជាសត្វតិរច្ឆាន ។ បំណែកកុសល ត្បៀងដូចចោរទាំង ៥០០ នាក់ ដែលបានទទួលសីល ៥ អំពីភិក្ខុដែលនៅក្នុងព្រៃ លុះជិតនឹងធ្វើកាលកិរិយា ក៏រឭកដល់សីលដែលខ្លួនរក្សាជាអារម្មណ៍ ស្លាប់ហើយក៏ទៅកើតក្នុងសុគតិ ។ កម្មនិមិត្តនោះ បំណែកបុណ្យ ឲ្យកើតក្នុងមនោទ្វារ ឃើញជាគ្រឿងសក្ការបូជា មានទានធូបផ្កាភ្ញីជាដើម ឬឃើញព្រះពុទ្ធរូប-ព្រះចេតិយជាដើម; បំណែកបាប ឃើញជាជាវិលំពែង នឹងគ្រឿងប្រហារសត្វ មានសំណាញ់នឹងអួនជាដើម ។ គតិនិមិត្តនោះ បំណែកកុសល ឲ្យឃើញជាវិមានមាសវិមានប្រាក់ជាដើម; បំណែកបាប ឲ្យឃើញអណ្តាតភ្លើងក្នុងនរក នឹងនាយនិរយបាលមានដៃកាន់អាវុធជាដើម ។

ស់. សត្វទាំងឡាយដែលស្លាប់ មានប៉ុន្មានប្រការ ?

ឆ. មាន ២ ប្រការ គឺ កាលមរណំ ស្លាប់ដោយ

អស់អាយុ ១ អកាលមរណំ ស្លាប់ដោយគេបាញ់គេគាប់សម្លាប់ជាដើម ឲ្យស្លាប់ក្នុងចន្លោះអាយុក្ខ័យ ១ ។

ស. អាយុក្ខ័យ នឹងរាប់ដូចម្តេច?

ឆ. រាប់តាមព្រះពុទ្ធសាសនាដែលកន្លងទៅ គឺសាសនាកន្លងទៅ ១០០ ឆ្នាំ អាយុមនុស្សថយចុះមក ១ ឆ្នាំ ឥឡូវនេះសាសនាកន្លងទៅ ២៥០៦ ឆ្នាំ អាយុមនុស្សកំណត់ ៧៥ ឆ្នាំជាអាយុក្ខ័យ ។

ស. ព្រះពុទ្ធសាសនាកំណត់ ៥ ពាន់ឆ្នាំនោះ ព្រះអង្គទ្រង់បញ្ញត្តក្នុងទីណា? ប្រារព្ធនូវបុគ្គលណា?

ឆ. ព្រះពុទ្ធអង្គគង់នៅវត្តជេតពន នគរសាវត្ថី; ទ្រង់ប្រារព្ធនូវព្រះសារីបុត្ត ព្រោះពេលនោះព្រះសារីបុត្តទូលសួរព្រះអង្គថា "ព្រះពុទ្ធអង្គទាំងឡាយក្នុងអតីតកាល ព្រះអង្គចូលនិព្វានហើយ សាសនធម៌ ពាក្យប្រដៅនឹងព្រហ្មចរិយៈ នឹងតាំងខ្ជាប់ឋិតថេរអស់កាលប៉ុន្មាន»? ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា "ម្នាលសារីបុត្ត ! ព្រះពុទ្ធអង្គក្នុងអតីតកាល មាន ៣ ព្រះអង្គ



គឺព្រះវិបស្សី, ព្រះសិខី, ព្រះវេស្សភូ ទាំង ៣ ព្រះអង្គនេះរលត់ខន្ធចូលកាន់និព្វានហើយ ធម៌វិន័យ សាសនា ព្រហ្មចរិយៈ ក៏អន្តរធានទៅ ព្រោះព្រះពុទ្ធអង្គមិនបានបញ្ញត្តសិក្ខាបទ មិនបានប្រតិស្ឋាន នវង្គសត្ថុសាសនៈ ប្រកបដោយអង្គ ៩ មានសុត្តំ គេយ្យំ ជាដើម ព្រះពុទ្ធសាសនាទើបបានសាបសូន្យទៅដោយឆាប់រហ័ស ប្រៀបដូចផ្កាឈើដែលបុគ្គលមិនបានក្រងដោយចេស ខ្យល់បក់មក ផ្កាឈើក៏ខ្ចាត់ខ្ចាយទៅ ។ ឯព្រះពុទ្ធ ៣ ព្រះអង្គទៀត គឺព្រះកកុសន្ធោ ព្រះកោនាគមនៈ ព្រះកស្សបៈ ទាំង ៣ ព្រះអង្គនេះ ព្រះអង្គរលត់ខន្ធចូលកាន់និព្វានហើយ សាសនាព្រហ្មចរិយៈនៃព្រះអង្គ ឋិតថេរអស់កាលយូរ ព្រោះព្រះពុទ្ធអង្គបញ្ញត្តសិក្ខាបទ នឹងតាំងទុកនូវនវង្គសត្ថុសាសនៈ មានសុត្តំ គេយ្យំ ជាដើម ប្រៀបដូចផ្កាឈើដែលបុគ្គលក្រងទុកល្អហើយ រមែងមិនខ្ចាត់ខ្ចាយទៅ ។

ស. សាសនានៃព្រះពុទ្ធអង្គទាំងឡាយ មានកំណត់ប៉ុន្មាន?

ឆ. សាសនាព្រះកកុសន្ធោ មានកំណត់ ៦០.០០០ ឆ្នាំ,

សាសនាព្រះកោនាគមនៈ មានកំណត់ ៤០.០០០ ឆ្នាំ, សាសនាព្រះកស្សប មានកំណត់ ២០.០០០ ឆ្នាំ. សាសនាព្រះគោតម មានកំណត់ ៥.០០០ ឆ្នាំ; សាសនាព្រះអរិយមេត្តេយ្យ មានកំណត់ ៨០.០០០ ឆ្នាំ ។

ស. សាសនានៃព្រះពុទ្ធទាំងឡាយ ម្ដេចក៏មិនកំណត់ឲ្យស្មើគ្នា ?

ឆ. កំណត់តាមនិស្ស័យសត្វទាំងឡាយ ដែលទ្រទ្រង់ទុកនូវសាសនា សេចក្ដីបដិបត្តិ តាមកម្លាំងសទ្ធានឹងបញ្ញា សេចក្ដីព្យាយាមច្រើន ក៏ទ្រទ្រង់ទុកនូវព្រះពុទ្ធសាសនាអស់កាលយូរ; បើសត្វទាំងឡាយមានសទ្ធា-បញ្ញា នឹងសេចក្ដីព្យាយាមតិច ក៏ទ្រទ្រង់ទុកនូវព្រះពុទ្ធសាសនាបានតិច ប្រៀបដូចរបស់ដែលមានកម្លាំងច្រើន ក៏នាំរបស់ទៅបានច្រើន របស់ដែលមានកម្លាំងតិច ក៏នាំរបស់ទៅបានតិច ដូចម្ដេចមិញ ព្រះពុទ្ធសាសនានឹងតាំងនៅបាន ក៏អាស្រ័យនូវឧបនិស្ស័យនៃសត្វដូច្នោះដែរ ។



ស. ធម៌អ្វីឲ្យជាឧបនិស្ស័យនៃសត្វ ?

ឆ. សទ្ធា សេចក្ដីជឿក្នុងគុណដែលគួរជឿ ១ បញ្ញា សេចក្ដីដឹងក្នុងគុណដែលគួរដឹង ១ វីរិយៈ សេចក្ដីព្យាយាមក្នុងគុណដែលគួរព្យាយាម ១ ទាំង ៣ នេះ ឲ្យកើតជាឧបនិ-ស្ស័យដល់សត្វ ។ ម្យ៉ាងទៀត ធម៌ទាំង ៧ គឺ សទ្ធា សេចក្ដីជឿ ១ សីល សេចក្ដីលះវៀរបាកបាប ១ ហិរិ សេចក្ដីខ្មាសបាប ១ ឱត្តប្បៈ សេចក្ដីក្ដៅនឹងបាប ១ សុតៈ ការស្ដាប់ធម៌ ១ ចាគៈ ការបរិច្ចាគទាន ១ បញ្ញា សេចក្ដីដឹងវិសេស ១ ទាំង ៧ នេះ ឲ្យកើតជាឧបនិស្ស័យដល់សត្វ ។

ស. ឧបនិស្ស័យមានប៉ុន្មានប្រការ ?

ឆ. មាន ៣ ប្រការ គឺៈ អលម្ពណូបនិស្ស័យ មានព្រះពុទ្ធគុណ ព្រះធម្មគុណ ព្រះសង្ឃគុណ នឹងទានសីលភាវនាជាអារម្មណ៍ ១ អនន្តរូបនិស្ស័យ បានដល់ចិត្តចេតសិកដែលរលត់មួយរំពេច ឲ្យកើតចិត្តចេតសិកទៀតតទៅ ១ បកតូបនិស្ស័យ ចំណែកបុណ្យ បានដល់សទ្ធា សីល ជាដើម ចំណែកបាប

បានដល់រាគៈ ទោសៈ មោហៈ ជាដើម ១ ។

ស. ឧបនិស្ស័យនឹងកើតឡើង អាស្រ័យហេតុអ្វី ?

ឆ. អាស្រ័យនូវចេតនា២យ៉ាងគឺៈ សហជាតចេតនា បានដល់ចេតសិកដែលកើតព្រមដោយកុសលចិត្តនឹងអកុសលចិត្ត ១ នានាខណិកចេតនា បានដល់កុសលអកុសលដែលខ្លួនធ្វើមកអំពីជាតិមុន ១ ។

ស. ព្រះពុទ្ធសាសនានឹងសាបសូន្យ ដោយហេតុអ្វី ?

ឆ. ព្រះពុទ្ធសាសនានឹងសាបសូន្យ ដោយបរិស័ទទាំង៤ គឺ ភិក្ខុ ១ ភិក្ខុនី ១ ឧបាសក ១ ឧបាសិកា ១ ទាំង ៤ នេះ មិនបានគោរពក្នុងវត្ថុទាំង ៧ គឺ មិនគោរពក្នុងព្រះពុទ្ធ ១ មិនគោរពក្នុងព្រះធម៌ ១ មិនគោរពក្នុងព្រះសង្ឃ ១ មិនគោរពក្នុងសិក្ខា ១ មិនគោរពក្នុងសមាធិ ១ មិនគោរពក្នុងសេចក្ដីមិនប្រមាទ១ មិនគោរពក្នុងបដិសណ្ឋារៈ ការក្រោករាក់ទាក់ទទួល១ មិនគោរពក្នុងវត្ថុទាំង ៧ នេះ ជាហេតុឲ្យព្រះពុទ្ធសាសនាសាបសូន្យទៅ មិនមានអ្នកដទៃធ្វើឲ្យសាបសូន្យទេ ប្រៀបដូច



ស្ដេចរាជសីហ៍ស្លាប់ហើយ សត្វដទៃ មិនអាចស៊ីសាច់ស្ដេចរាជសីហ៍នោះបាន វៀរលែងតែដង្កូវដែលកើតឡើងក្នុងខ្លួនស្ដេចរាជសីហ៍ នឹងញាំញីទាំស៊ីជាអាហារ ។

ស. ព្រះពុទ្ធសាសនានឹងរុងរឿងដោយហេតុអ្វី ?

ឆ. នឹងរុងរឿងដោយបរិស័ទទាំង ៤ គឺ ភិក្ខុ ១ ភិក្ខុនី១ ឧបាសក ១ ឧបាសិកា ១ ទាំង ៤ នេះ មានសេចក្ដីគោរពក្នុងព្រះពុទ្ធ ១ គោរពក្នុងព្រះធម៌ ១ គោរពក្នុងព្រះសង្ឃ ១ គោរពក្នុងសិក្ខា ១ គោរពក្នុងសមាធិ គឺចំរើនព្រះកម្មដ្ឋាន ១ គោរពក្នុងអប្បមាទធម៌ ១ គោរពក្នុងបដិសណ្ឋារៈ ការក្រោកទទួល ១ ។ កាលបរិស័ទទាំង ៤ មានសេចក្ដីគោរពក្នុងវត្ថុទាំង ៧ នេះ នៅដរាបណា ព្រះពុទ្ធសាសនាក៏រុងរឿងអស់កាលយូរអង្វែង ។ គោរពព្រះពុទ្ធព្រះធម៌ នឹងព្រះសង្ឃនោះ ឲ្យក្រាបសំពះធ្វើសក្ការបូជាសព្វៗ ថ្ងៃ កុំឲ្យដាច់ ។ គោរពក្នុងសិក្ខានោះ គឺ ការតាំងចិត្តសិក្សាសូត្ររៀនបារិបនាទាំង ២ គឺព្រះធម៌ព្រះវិន័យ មិនខ្ជិលប្រអូស បំពេញឥទ្ធិបាទ

ធម៌ទាំង ៤ ឲ្យបរិបូណ៌ជាដើម ។ គោរពក្នុងសមាធិ ឲ្យបំរើនព្រះកម្មដ្ឋាន, គោរពក្នុងសេចក្ដីមិនប្រមាទ ឲ្យមានសតិរឭកដល់សេចក្ដីចាស់ឈឺស្លាប់ជាដើម; គោរពក្នុងបដិសណ្ឋារៈ ការក្រោកទទួល គឺទទួលមនុស្សមានធុរៈ ដែលមកកាន់សំណាក់ខ្លួន ដោយអាមិសផ្សេង ៗ ឬដោយធម៌ គឺពោលពាក្យដែលប្រកបដោយធម៌វិន័យ ជាហេតុឲ្យមានសទ្ធាជ្រះថ្លានឹងធម្មសង្វេគ ជាបុញ្ញក្ខេត្ត ផ្លូវសួគ៌-និព្វាន ក្នុងអនាគតកាលខាងមុខ ដូចវិសជ្ជនាមកដូច្នេះ ។

---

## លោកសណ្ឋានកថា

តិណ្ណំ លោកានំ វសេសេនេវ អត្ថវណ្ណនា សំខេ-បតោ លោកសណ្ឋានកថាតិ វេទិតព្វាតិ ។

គ្រានេះនឹងសំដែងដំណារឿង មានវិធីលោកសណ្ឋានជាដើម។

ស. លោក មានផែនដីនឹងមនុស្សជាដើម អ្នកណាសាង?

ឆ. មិនមានអ្នកណាសាងទេ ។



ស. បើមិនមានអ្នកណាសាងទេ តើកើតឡើងដោយហេតុអ្វី ?

ឆ. កើតឡើងដោយសង្ខារ ។

ស. សង្ខារ មានប៉ុន្មានប្រការ ?

ឆ. សង្ខារមាន ២ ប្រការ គឺ សង្ខារធម៌ ១ សង្ខារ-លោក ១ ។ សង្ខារធម៌នោះចាត់ជា ៣ គឺៈ បុញ្ញាភិសង្ខារ បុណ្យកុសលដែលសត្វធ្វើដោយកាយវាចាចិត្ត ហើយតាក់តែងឲ្យផលនាំមកនូវសុខតាមកម្លាំង ១ អបុញ្ញាភិសង្ខារ អកុសលដែលសត្វសន្សំ ដោយកាយវាចាចិត្ត ហើយតាក់តែងឲ្យផលនាំមកនូវទុក្ខតាមកម្លាំង ១ អនេញ្ជាភិសង្ខារ បានដល់អរូបឈានសមាបត្តិ ដែលសត្វបំរើនឲ្យកើតឡើង ហើយតាក់តែងឲ្យផលទៅកើតក្នុងអរូបភព ១ ទាំង ៣ នេះ ឈ្មោះថាសង្ខារធម៌ ជាបច្ច័យតាក់តែងសត្វឲ្យកើតតាមកម្លាំង ។

សង្ខារលោកនោះ ចាត់ជា ២ ពួកគឺៈ ឧបាទិន្នកសង្ខារ សង្ខារដែលមានឧបាទានចូលទៅជិតកាន់យក បានដល់សត្វ

ដែលមានចិត្តមានវិញ្ញាណ ១ អនុបាទិន្នកសង្ខារ សង្ខារដែលមិនមានឧបាទានចូលទៅជិតកាន់យក បានដល់សម្ភារៈដែលមិនមានចិត្តមិនមានវិញ្ញាណ មានដីថ្មគ្រួសជាដើម ១ ។

ស. សង្ខារពួកណាជាអ្នកបង្កើតលោក ?

ធ.សង្ខារធម៌ដែលជាកុសល ជាអ្នកបង្កើតលោកឡើង។

ស. សង្ខារដែលជាកុសល មានប៉ុន្មានប្រការ ?

ធ. មាន ៤ ប្រការ គឺៈ កាមាវចរកុសល ១ រូបាវចរ-កុសល ១ អរូបាវចរកុសល ១ លោកុត្តរកុសល ១ ។

ស. សង្ខារធម៌ដែលជាកុសលញ៉ាំងលោកឲ្យកើតឡើងនោះ ដូចម្តេច ?

ធ. ព្រះពោធិសត្វដែលប្រាថ្នាជាព្រះពុទ្ធ- ព្រះបច្ចេក-ពោធិជាដើម ដរាបដល់សាវក-សាវិកា **នឹងបរមចក្រពត្តិ** ក្សត្រា ព្រាហ្មណ៍ សេដ្ឋី កុដុម្ពិក៍ ជា**អវសាន** កសាងពោធិ-ញាណ បំពេញទាន រក្សាសីល ៥ **សីល ៨** កម្មបថ ១០ បំរើនមេត្តាភាវនា ស្តាប់ព្រះធម៌**ទេសនា ធ្វើពុទ្ធបូជា** ធម្មបូជា



នឹងសង្ឃបូជា ជាដើម កសាងសន្សំកងការកុសល អស់ជាតិជាអនេក ដោយអំណាចកុសលនៃអ្នកទាំងអស់នេះ ជាបុញ្ញនិធិសន្សំទុកមកក្នុងសន្តាន ជាបុញ្ញាភិសង្ខារតាក់តែងឲ្យកើតលោក មានផែនដីជាដើម ។

ស. ឱកាសលោក កើតឡើងដោយបុញ្ញាភិសង្ខារហើយ ហេតុអ្វី ឱកាសលោកក៏ត្រឡប់វិនាសវិញ ?

ធ. ឱកាសលោកនឹងវិនាសទៅដោយអបុញ្ញាភិសង្ខារ គឺអកុសលដែលកើតឡើងអំពីលោភមូល ៨ ទោសមូល ២ មោ-ហមូល ២, ទាំង ១២ នេះជាមូល (ឬសគល់) នៃអកុសល, បុគ្គលធ្វើដោយចិត្តលោភ. ចិត្តខឹង, ចិត្តវង្វេង ឈ្មោះថា អបុញ្ញាភិសង្ខារ ។

ស. ឱកាសលោកវិនាសដោយលោភៈ ទោសៈ មោហៈនោះ ព្រោះហេតុអ្វី ?

ធ. សត្វក្រាស់ដោយរាគៈ ឲ្យកើតភ្លើងឆេះ ឱកាសលោកវិនាសដោយភ្លើង, សត្វក្រាស់ដោយទោសៈ ឲ្យកើតទឹក

ជន់លិច ឱកាសលោកវិនាសដោយទឹក, សត្វក្រាស់ដោយមោហៈ ឲ្យកើតខ្យល់បក់ ឱកាសលោកវិនាសដោយខ្យល់ ។ ឱកាសលោក ត្រូវវិនាសដោយភ្លើង ៧ ដង ត្រូវវិនាសដោយទឹកម្តង ត្រូវវិនាសដោយភ្លើង ៥៦ ដងគឺៈ ៧×៨, ត្រូវវិនាសដោយទឹក ៨ ដង រួមគ្នាត្រូវជា ៦៤ ដង ។

ស. ឱកាសលោកវិនាសម្តងៗនោះ មានចំនួនប៉ុន្មាន ?

ឆ. ឱកាសលោកនឹងវិនាសម្តង ៗ នោះ ចំនួនមួយសែនកោដិចក្រវាល ។

ស. ចក្រវាលនីមួយៗ ទំហំប៉ុន្មាន ?

ឆ. បើវាស់ដោយវែងត្រង់ទៅ ១២៣.៤៥០ យោជន៍។

ស. ចក្រវាឡនោះ មានសម្ភារៈអ្វីខ្លះ ?

ឆ. មានភ្នំព្រះសុមេរុនៅកណ្តាល, មានទ្វីបធំទាំង៤គឺ ជម្ពូទ្វីប ទទឹងមួយហ្មឺនយោជន៍, បំណែកព្រៃហិមពាន្ត ៣ ពាន់យោជន៍ ជាលំនៅនៃមនុស្ស ៣ ពាន់យោជន៍ ជាសមុទ្រ ៤ ពាន់យោជន៍ មានដើមព្រីងធំប្រចាំទ្វីប មនុស្សចិញ្ចឹមជីវិត



ដោយធ្វើស្រែ-ជួញប្រែជាដើម ។ ឧត្តរកុរុទ្វីប មានសណ្ឋាន ៤ ជ្រុង, ទទឹង ៨.០០០ យោជន៍ មានដើមកប្បព្រឹក្សប្រចាំទ្វីប, មនុស្សអាស្រ័យដោយដើមកប្បព្រឹក្ស មិនបាច់ធ្វើស្រែ កាប់ចំការ ជួញប្រែ មានរូបល្អ ៗ ទាំងស្រីទាំងប្រុស មានសីល ៥ ដូចគ្នា ស្លាប់ហើយមិនទៅនរក, ស្ត្រីមានគភ៌គ្រប់កំណត់៧ថ្ងៃ សម្រាលទារកចេញមក ក្មេងនោះជញ្ជក់តែម្រាមដៃគេ ៧ ថ្ងៃដើរបាន ។ អមរគោយានីទ្វីប មានសណ្ឋានដូចព្រះចន្ទខាងរនោច ទទឹង ៧.០០០ យោជន៍ មានដើមកទម្ពប្រចាំទ្វីប មានថ្មកែវភ្លើងឲ្យសម្រេចសេចក្តីប្រាថ្នា ដល់មនុស្សទាំងពួង, ពួកមនុស្សមានសីល ៥ ជានិច្ច ស្លាប់ហើយមិនទៅនរក ។ បុព្វវិទេហទ្វីប ទទឹង ១ ហ្មឺនយោជន៍ មានសណ្ឋានដូចវង់ព្រះចន្ទ មានដើមច្រេសប្រចាំទ្វីប មានប្រាសាទកែវ ៧ ប្រការ កំពស់ ១៥ យោជន៍ អាចឲ្យសម្រេចសេចក្តីប្រាថ្នាដល់មនុស្សទាំងអស់ ។ មានសីល ៥ មានអាយុ ១ ហ្មឺនឆ្នាំ លុះស្លាប់ហើយ មិនទៅកាន់នរក ។ មានទ្វីបតូចៗ

២.០០០ ហើយនឹងមានភ្នំចក្កវាឡព័ទ្ធដោយជុំវិញ ។

ស. ដីតាំងនៅលើរបស់អ្វី ?

ឆ. ផែនដីតាំងនៅលើទឹក ៗ តាំងនៅលើខ្យល់, ក្រោមខ្យល់ ជាអជ្ឈាកាស បន្ទោះទទេ ។

ស. ផែនដី-ទឹកនឹងខ្យល់ មានកំរាស់ប៉ុន្មាន ?

ឆ. ផែនដីកម្រាស់ ២៤០.០០០យោជន៍ ។ ទឹកកម្រាស់ ៤ សែន៨ម៉ឺនយោជន៍ ។ ខ្យល់កម្រាស់ ៩៦០.០០០ យោជន៍។

ស. កាលឱកាសលោកនឹងវិនាសនោះ តើដោយអាការដូចម្ដេច ?

ឆ. កាលឱកាសលោកនឹងវិនាសដោយភ្លើងនោះ មហាមេឃតាំងឡើងបណ្ដាលឲ្យភ្លៀងធ្លាក់ចុះ ទូទៅក្នុង១សែនកោដិចក្កវាឡ, មនុស្សទាំងឡាយក៏នាំគ្នាសាបព្រោះស្រូវ ៗ ក៏ដុះលូតលាស់ឡើង មហាមេឃក៏បន្លឺសំឡេងដូចសំឡេងនៃសត្វលា ហើយក៏រាំងបាត់ស្ងាត់ឈឹងទៅ លែងមានភ្លៀងធ្លាក់ចុះមកអស់សែននៃផ្ទៃដីច្រើន ហើយទឹកក្នុងស្រះជ្រោះត្រពាំងបឹងបួ



ក៏រីងអស់ ។ សត្វនឹងមនុស្សទាំងឡាយ ដែលអាស្រ័យទឹកភ្លៀងនឹងទេវតាដែលអាស្រ័យនូវផ្កាឈើជាដើម ក៏នាំគ្នាច្យុតទៅកើតក្នុងព្រហ្មលោក ។ ឯសត្វក្នុងអបាយភូមិមាននរកជាដើមដែលមានកម្មដ៏ស្រាល អស់កម្មហើយ បានអាស្រ័យកុសលបាស់ ជារបស់ដែលខ្លួនបានធ្វើទុក ក៏ច្យុតទៅកើតក្នុងព្រហ្មលោកទាំងអស់ ។

ស. សត្វមានទេវតានឹងមនុស្សជាដើម មានសត្វនរកជាទីបំផុត ស្លាប់ហើយទៅកើតក្នុងព្រហ្មលោកនោះ ទៅដោយផលកម្មអ្វី ?

ឆ. ទៅដោយផលនៃឈាន ។

ស. សត្វទាំងអម្បាលនោះ បានចំរើនឈានពីកាលណា ?

ឆ. កាលនៅទៀតមួយសែនឆ្នាំ ឱកាសលោកនឹងវិនាស មានទេវតា១អង្គឈ្មោះថា លោកព្យូហា មកស្រែកយំរំសាយកេសា ហើយក៏ហោះទៅប្រកាសប្រាប់ដល់មហាជនទាំងឡាយ សព្វទូទៅក្នុងទិសានុទិសថា មារិសា ៗ ម្នាលអ្នក

ទាំងឡាយអើយ នៅតែ ១ សែនឆ្នាំទៀតទេ ឱកាសលោក នឹងវិនាស អ្នកទាំងឡាយកុំប្រមាទ ។ ជនទាំងឡាយបាន ឮសំឡេងទេវតាប្រកាស ក៏នាំគ្នាឧស្សាហ៍កសាងសន្សំកងការកុសល មានឲ្យទានរក្សាសីលជាដើម លុះអស់ជន្មាយុ ក៏បានទៅកើតក្នុងសួគ៌ទេវលោក១ នាំគ្នាបំរើនកសិណ ក៏បានសម្រេចឈាន លុះទម្លាយខន្ធ ក៏ទៅកើតក្នុងព្រហ្មលោក ។ មួយវិញទៀត សត្វនរកប្រេតអសុរកាយនឹងសត្វតិរច្ឆាន ដែលអស់កម្មអកុសល ក៏មកកើតក្នុងឋានមនុស្ស បានកសាងកងការកុសលមានសីលទានជាដើម លុះអស់ជីវិតទៅ ក៏ទៅកើតក្នុងឋានសួគ៌ បានចំរើនឈានក្នុងឋានសួគ៌ហើយ ក៏បានទៅកើតក្នុងព្រហ្មលោក ។ ចំណែកសត្វនរកឈ្មោះនិយតមិច្ឆាទិដ្ឋិ ដែលមិនទាន់អស់កម្ម ៗ ក៏នាំទៅចក្កវាឡដទៃ អំពីកាលភ្លៀងរាំងដាច់អស់សែនឆ្នាំដ៏ច្រើន ទើបកើតព្រះអាទិត្យរះឡើងមកពីរដួង គ្រានោះ មិនមានយប់ ព្រោះដួងមួយលិចបាត់ទៅ ដួងមួយរះឡើងមក ព្រះអាទិត្យដែលបំភ្លឺលោកជាធម្មតា មាន



មេឃពពកផ្សែងនោះក៏បាត់ទៅ ព្រះអាទិត្យដែលរះមកថ្មី មានរស្មីក្តៅក្លា មិនមានមេឃពពកផ្សែង ព្រោះហេតុនោះ ស្ទឹងតូច ៗ ក៏រីងហួតហែងអស់ ដើមឈើធំៗ ក៏ងាប់គ្មានសល់ នៅតែស្ទឹងទាំង ៥ គឺៈ គង្គា ១ យមុនា ១ អចិរវតី ១ មហី ១ សរភូ ១ មិនទាន់រីង ។ លុះកន្លងយូរមក ព្រះអាទិត្យរះឡើង ១ ដួងទៀត ត្រូវជា ៣ ដួង, កន្លងយូរមក មានព្រះអាទិត្យ ៤ ដួងបានកើតឡើង ពេលនោះ ទឹកក្នុងស្រះអនោតត្តៈទាំង ៧ ក៏រីងអស់ ។ យូរមក ព្រះអាទិត្យ ៥ ដួងរះឡើង ទឹកក្នុងមហាសមុទ្រក៏រីងអស់ ត្រីទាំងឡាយ មានត្រីតិមង្គលជាដើម ក៏ស្លាប់អស់ ។ កន្លងយូរមក ព្រះអាទិត្យ ៦ ដួង ត្រូវរះឡើង គ្រានោះ ផែនដីក្នុង ១ សែនកោដិចក្កវាឡ ក៏ហុយផ្សែងទូទៅ ។ លុះយូរមក ព្រះអាទិត្យ ៧ ដួងក៏រះឡើង កាលព្រះអាទិត្យ ៧ ដួងរះឡើងព្រមគ្នាដូច្នោះ ក៏កើតជាអណ្តាតភ្លើងឆាបឆេះយ៉ាងសន្ធោសន្ធៅ ដោយអាស្រ័យខ្លាញ់ត្រីជាដើរ ។ គឺឆេះអំពីផែនពសុធាជំរាបឡើងទៅដល់ទេវតា ៦ ជាន់ ហើយ

ក៏ឆេះឡើងទៅទល់នឹងព្រហ្មលោក ឈ្មោះអភស្សរា ។ ភ្នំទាំងឡាយ មានភ្នំព្រះសុមេរុជាដើម ក៏ឆេះជាលំអិតសាបសូន្យអស់ទៅទាំង ១ សែនកោដិចក្កវាឡ លុះអស់កំញមហើយ ក៏រលត់ទៅ ត្រឡប់ជាអជ្ឈាកាសទទេ សព្វគ្រប់អន្ធើ បង្កើតជាអាកាសឲ្យងងឹតឈ្លប់ទៅ អស់កាលដ៏យូរ ។ មហាមេឃាសមុដ្ឋហិ គ្រានោះ មហាមេឃតាំងឡើងព្រម ហើយញុំាងភ្លៀងឲ្យធ្លាក់ចុះ ដំបូង ធ្លាក់តូច ៗ ប៉ុនដំណក់ទឹកសន្សើម ហើយក៏ធ្លាក់គ្រាប់ធំ ៗ ដរាបប៉ុនដើមត្នោត ពេញក្នុង ១ សែនកោដិចក្កវាឡ ខាងលើ ដល់ព្រហ្មលោក កើតខ្យល់បក់ខ្ទប់ទឹកទុកមិនឲ្យខ្ចាយស្រក់ចុះដល់ ទឹកក៏ស្រកស្រុតចុះមកបន្តិចម្តង ៗ ដរាបដល់ផ្ទៃផែនដីក៏រឹងទ័ណ្ឌខាងលើ ដូចជាទឹកបាយដែលគេដាក់ទុកឲ្យត្រជាក់ មានសម្បុរលឿង មានក្លិនក្រអូប មានរសផ្អែម ។

ស. ផែនដីកើតឡើងក្នុងទីណាមុន ?

ឆ. កើតឡើងក្នុងមជ្ឈិមប្រទេសមុន ។ ទីនោះជាទី



ដែលព្រះពុទ្ធអង្គចុះមកត្រាស់ ។

អធិប្បាយថាៈ មជ្ឈិមប្រទេសនោះ កាលនឹងវិនាស ក៏វិនាសខាងក្រោយ កាលនឹងកើតឡើងក៏កើតឡើងមុន ។ កាលនឹងកើតឡើងនោះ មានគុម្ពឈូក ១ កើតឡើងមុនជាបុព្វនិមិត្ត ជាទីកំណត់ដឹងថា បើកប្បឯណាព្រះពុទ្ធអង្គមិនចុះមកត្រាស់ទេ គុម្ពឈូកនោះក៏មិនផ្កាឡើយ ថាបើកប្បឯណាព្រះពុទ្ធអង្គចុះមកត្រាស់ ១-២-៣-៤ ឬ ៥ អង្គ ដូចក្នុងកប្បនេះ គុម្ពផ្កាឈូកក៏មានផ្កា ១-២-៣-៤ ឬ ៥ តាមចំនួនព្រះពុទ្ធអង្គដែលនឹងចុះមកត្រាស់នោះ ។

ស. ព្រះពុទ្ធដែលចុះមកត្រាស់ គ្រប់តែកប្បទៅឬ ?

ឆ. មិនចុះមកត្រាស់គ្រប់កប្បទេ ដ្បិតកប្បនោះមាន ២ គឺៈ

១- សុញ្ញកប្ប សូន្យទទេ មិនមានព្រះពុទ្ធចុះមកត្រាស់

២- អសុញ្ញកប្ប មានព្រះពុទ្ធចុះមកត្រាស់ ។ អសុញ្ញកប្បបែកជា ៥ គឺៈ សារកប្ប មានព្រះពុទ្ធមួយអង្គចុះមកត្រាស់ ១ មណ្ឌកប្ប មានព្រះពុទ្ធពីរព្រះអង្គចុះមកត្រាស់ ១ វរកប្ប មាន

ព្រះពុទ្ធ ៣ ព្រះអង្គមកត្រាស់ ១ សារមណ្ឌកប្ប មានព្រះពុទ្ធ ៤ ព្រះអង្គចុះមកត្រាស់ ១ ភទ្ទកប្ប មានព្រះពុទ្ធ ៥ ព្រះអង្គចុះមកត្រាស់ ១ ។ ព្រោះហេតុនោះ ផ្កាឈូកទើបកើតច្រើនខ្លះ តិចខ្លះ តាមព្រះពុទ្ធអង្គដែលចុះមកត្រាស់ ។

ស. ក្នុងផ្កាឈូកនោះ មានវត្ថុអ្វីខ្លះ ?

ឆ. មានត្រៃចីវរកើតសម្រាប់បុណ្យ នៃព្រះពុទ្ធអង្គនៅក្នុងផ្កាឈូក ហេតុដូច្នោះ កាលផែនដីចំរើនឡើងថ្មី ៗ មានក្លិនដ៏ក្រអូបឡើងទៅដល់ព្រហ្មលោក ។ ពេលនោះ ពួកមហាព្រហ្ម មួយអន្លើដោយព្រហ្មទាំងឡាយ ក៏ចុះមកកាន់ផែនដី កាលបើមិនឃើញផ្កាឈូក ក៏សោយសោកតូចចិត្តថា អន្ទោ វត ភោ លោកោ ម្នាលគ្នាយើងដ៏ចំរើន សត្វលោកនឹងងងឹតសាបសូន្យហើយ កាលបើបានឃើញផ្កាឈូក ក៏នាំគ្នាត្រេកអរ នាំនូវត្រៃចីវរទៅកាន់ព្រហ្មលោក ។ រីព្រហ្មទាំងឡាយដ៏សេស ក៏ច្យុតចុះមកកើតជាមនុស្សមានរូបកាយបរិសុទ្ធល្អដោយគ្រឿងប្រដាប់ មានអានុភាពហោះទៅក្នុងអាកាសបាន



មានរស្មីល្អភ្លឺផ្សាយចេញអំពីកាយ មានសីល ៥ បរិបូណ៌ មិនមានភេទប្រាកដជាស្រីឬប្រុស មានបីតិជាអាហារ មានអាយុ ១ អសង្ខេយ្យឆ្នាំ ។ គ្រាក្រោយមក មានសេចក្ដីប្រាថ្នានឹងបរិភោគរសផែនដី ក៏ពួតជាពំនូត ៗ ស៊ីជាអាហារ រស្មីក៏អន្តរធានបាត់ទៅ ត្រឡប់ឲ្យកើតជាងងឹត ពពួកមហាជនក៏ស្រែកយំបរិទេវនាការ រ៉ឹកខ្វល់ ។ គ្រានោះ សុរិយមណ្ឌលមានទទឹងនឹងបណ្ដោយ ៥០ យោជន៍ មានរស្មីរុងរឿងដោយអាការដ៏ក្ដៅ ផុសឡើងមកអណ្ដែតនៅក្នុងអាកាស មានពន្លឺភ្លឺទូទៅក្នុងចក្កវាឡ មនុស្សទាំងឡាយឃើញហើយ ក៏រីករាយត្រេកអរ ទើបឲ្យឈ្មោះថា ព្រះអាទិត្យ រហូតមកដល់សព្វថ្ងៃនេះ ព្រោះភ្លឺរុងរឿងក្នុងវេលាថ្ងៃ លុះដល់សម័យថ្ងៃល្ងាច ក៏ងងឹតអន្ធការ ពពួកមហាជនក៏តូចចិត្ត នាំគ្នាទួញយំបរិទេវនាការ ។ កាលណោះ មានចន្ទមណ្ឌលប្រកបដោយវិមានប្រាក់ទទឹងនឹងបណ្ដោយ ៤៩ យោជន៍ កើតឡើង មានរស្មីភ្លឺរុងរឿងក្នុងវេលាយប់ មនុស្សទាំងឡាយក៏ត្រេកអរ ទើបឲ្យឈ្មោះថា

ព្រះចន្ទ ។ កាលបើព្រះអាទិត្យនឹងព្រះចន្ទកើតឡើងហើយនោះ ក៏បង្កើតឲ្យមានពពួកផ្កាយ, ថ្ងៃ, យប់, យាម, ភ្នំព្រះសុមេរុ, មហាសមុទ្រ, ជ្រោះជ្រោយ, ទន្លេ, បឹងត្រពាំង, ស្ទឹង ថ្លុក នឹងព្រែកអូរ ផ្លូវទឹកហូរ ។

ស. ភ្នំព្រះសុមេរុនឹងមហាសមុទ្រជាដើមនោះ កើតឡើងដោយអាការដូចម្តេច ?

ឆ. ភ្នំព្រះសុមេរុជាដើម កាលនឹងកើតឡើងនោះ ប្រៀបដូចជាបុគ្គលដណ្តាំបាយឲ្យពុះឡើងព្រមគ្នា ក៏បង្កើតជាពពុះខ្ពស់ខ្លះ ទាបខ្លះ ស្មើគ្នាខ្លះ ។ ទីឯណាខ្ពស់ ក៏កើតជាភ្នំ ទីឯណាទាប ក៏កើតជាមហាសមុទ្រ-ទន្លេ-ស្ទឹង-បឹងបួ ទីឯណាស្មើគ្នា ក៏បង្កើតជាទ្វីប ។ ឯពួកតារាផ្កាយនោះ អាចារ្យពួកខ្លះពោលថា កែវកំពូលវិមាននៃទេវតា ។

ស. កាលព្រះអាទិត្យព្រះចន្ទញ៉ាំងលោកឲ្យភ្លឺហើយ តទៅមុខទៀតនោះ មានហេតុដូចម្តេចខ្លះ ?

ឆ. មនុស្សទាំងឡាយនាំគ្នាត្រេកអរ ហើយនាំគ្នាបរិ.



ភោគរសផែនដី ។ តាំងពីកាលនោះមក រាងកាយ ពណ៌សម្បុរ ទ្រង់ទ្រាយ ក៏ប្លែក ៗ គ្នា អាក្រក់ខ្លះ ល្អខ្លះ ហើយកើតមានទិដ្ឋិប្រកាន់ខ្លួនប្រាណផ្សេង ៗ គ្រានោះ រសផែនដីដែលក្រអូបផ្អែមជាអាហារ ក៏បាត់ទៅ កើតជារំកាប់ក្រោមដី មនុស្សទាំងឡាយក៏ស៊ីជាអាហារ ។ លុះកន្លងយូរទៅ ក៏កើតមានមានះទិដ្ឋិច្រើនឡើង រំកាប់ក្រោមដីក៏បាត់ទៅ វល្លិប្រទាលក៏កើតឡើង មនុស្សនាំគ្នាបរិភោគវល្លិ ៗ ក៏បាត់ទៅ កើតជាស្រូវសាលីសម្បុរស មិនមានអង្កាម កុណ្ឌក មានក្លិនក្រអូប ផ្លែជាអង្ករសំរិត មនុស្សទាំងឡាយក៏នាំគ្នាបេះមកបំអិនបរិភោគ បើបេះវេលាព្រឹក លុះពេលល្ងាចក៏កើតឡើងដូចដើម ៗ សេចក្តីថា ការបំអិនបាយដោយអង្ករនៃស្រូវសាលីនោះ ងាយណាស់ គឺបេះមកដាក់ក្នុងភាជន៍ហើយ លើកឡើងដំកល់លើផែនថ្មសិលា ក៏ឆ្អិនភ្លាម កាលឆ្អិនហើយ មនុស្សនឹងបរិភោគមិនចាំបាច់រកម្ហូបមកផ្សំទេ នឹកចង់រសឆ្ងាញ់បែបណា អាហារក៏ឲ្យកើតរសឆ្ងាញ់បែបនោះ កាលបើជនទាំងឡាយបរិភោគអាហារ

ដ៏ជ្រោកជ្រាក ក៏បង្កើតជាមូត្រគូថ អាចម៍នោមដ៏លាមកឡើង
ក្នុងពោះ មានមុខដំបៅជាប្រហោង ឲ្យបញ្ចេញនូវមូត្រគូថ
បើជាតិមុនធ្លាប់កើតជាស្រី ក៏កើតភេទជាស្រី បើជាតិមុន
ធ្លាប់កើតជាប្រុស ក៏កើតភេទជាប្រុស ។ កាលកើតឡើង
ប្រាកដជាស្រីជាប្រុសហើយ ក៏សំឡឹងមើលនូវគ្នានឹងគ្នា ឲ្យ
កើតសេចក្ដីក្ដៅក្រហាយក្នុងកាមគុណ រាគៈក៏កើតឡើងយ៉ាង
ក្លាហាន ដរាបដល់សេពមេថុនធម្មជាទីបំផុត ។ ពពួកមនុស្ស
ធ្វើផ្ទះមិនបានធ្វើជញ្ជាំងបាំងបិទ ជនឯណាដែលក្រាស់ដោយ
រាគបរិត ក៏សេពមេថុនក្នុងទីវាល មនុស្សដែលមានសេចក្ដី
ខ្មាសអៀនអន់ ក៏តិះដៀលថា យកជម្រាប់ដូចសត្វតិរច្ឆាន ។
អំពីកាលណោះមក ក៏ធ្វើជញ្ជាំងបាំងបិទឲ្យជិត មានទ្វារបង្អួច
សម្រាប់បើកបិទដរាបមក កាលបើមនុស្សទាំងឡាយសង់
ផ្ទះឡើងហើយ មនុស្សដែលខ្ជិលច្រអូស ក៏នាំគ្នាសន្សំស្រូវ
ទុកច្រើន ៗ ដោយសេចក្ដីលោភ ។ តាំងពីថ្ងៃនោះមក ស្រូវ
សាលីក៏មានអង្កាមកុណ្ឌក ទៅច្រូតមកម្ដងក៏បាត់ទៅ មិនកើត



ផលឡើងទៀតដូចអំពីមុន ។ គ្រានោះ មនុស្សទាំងឡាយ ក៏
បែងចែកខេត្តដែននៃស្រែស្រូវសាលី ដល់គ្នានឹងគ្នាជាបំណែកៗ
មនុស្សមានចិត្តជាអកុសល ទៅលបលួចស្រូវសាលីរបស់អ្នក
ដទៃ លុះម្ចាស់របស់គេចាប់បាន ក៏ជេរប្រទេច ២-៣ ដង
ហើយលែងទៅ ។ ដល់ពេលក្រោយមក ចាប់បានហើយវាយ
ដំប្រំបាក់ ហើយលែងទៅ កាលអទិន្នាទានកើតឡើងហើយ
មុសាវាទ និយាយកុហកបញ្ឆោតនូវគ្នានឹងគ្នា ក៏កើតឡើង
គ្រានោះ មនុស្សទាំងឡាយ ក៏បាននូវសេចក្ដីក្ដៅក្រហាយច្រើន
ទើបសន្និបាតប្រជុំគ្នាពោលថា គ្នាយើងទាំងពួង បានសេចក្ដី
ក្ដៅក្រហាយដូច្នេះ តើយើងត្រូវធ្វើដូចម្ដេច ? កាលបើប្រឹក្សាគ្នា
ទៅ ក៏ឃើញព្រមគ្នាថា ព្រះបរមពោធិសត្វ ឋិតនៅក្នុងយុត្តិធម៌
គួរយើងទាំងឡាយ លើកឡើងនូវព្រះពោធិសត្វឲ្យជាធំ ជាអ្នក
ប្រដៅនូវគ្នានឹងគ្នា ។ កិរិយានៃព្រះពុទ្ធជាម្ចាស់នៃយើងក្នុងខាង
ដើមភទ្ទកប្បនេះ ប្រកបដោយសីល ៥-៨ នឹងកម្មបថ១០ ទើប
ទ្រង់ឲ្យឱវាទ ពាក្យប្រដៅដល់មហាជនជាច្រើន ព្រោះហេតុ

នោះ មនុស្សទាំងឡាយ ទើបលើកព្រះបរមពោធិសត្វឡើងជាស្ដេច សម្មតិរាជ ឲ្យឋិតនៅក្នុងទីមានយសដ៏ធំ នឹងបានសង្កត់សង្កិននូវមនុស្សពាល ក៏ថ្វាយនូវអង្ករនៃស្រូវសាលីម្នាក់ ៗ កន្លះបាំង ។

តាមគម្ពីរធម្មសាស្ត្រថា កាលព្រះបរមពោធិសត្វសោយរាជសម្បត្តិជាស្ដេច សម្មតិរាជ មានព្រះរាជឱរស ៤ ព្រះអង្គ ។ ឱរសទាំង ៤ នេះ កាលចំរើនធំឡើង ក៏បានសោយរាជសម្បត្តិក្នុងទ្វីបទាំង ៤ ។ ចំណែកព្រះរាជឱរសនៅក្នុងជម្ពូទ្វីបនេះ មានព្រះរាជបុត្រ ១០ ព្រះអង្គ ទើបបែងជម្ពូទ្វីបនេះទៅជា ១១ ចំណែក ឲ្យដល់ព្រះរាជឱរសមួយចំណែក ៗ មួយអង្គ លុះយូរមក ព្រះរាជបុត្រទាំង ១០នោះ មួយអង្គ ៗ មានព្រះរាជបុត្រ ១០ទៅទៀត ហើយក៏បែងជម្ពូទ្វីបជា ១០១ ចំណែក ចែកឲ្យមួយអង្គ ៗ មួយចំណែក លុះយូរមក មានរូបរាងកាយ ភាសានិយាយក៏ផ្សេង ៗ ទាំង ១០១ នោះមកដរាបដល់សព្វថ្ងៃនេះ ។ គ្រានោះ មានមហាព្រហ្មមួយអង្គ ឈ្មោះ ព្រហ្មទេវៈ ច្យុតចុះ



មកកើតក្នុងត្រកូលអាមាត្យនៃស្ដេចសម្មតិរាជ លុះបានអាយុ ១៥ ឆ្នាំ ក៏បានទទួលរាជការជួសបិតា លុះយូរមកឃើញជនទាំងឡាយ កើតវិវាទទាស់ទែងគ្នាជាច្រើន មានសេចក្ដីប្រាថ្នានឹងទំនុកបំរុងដល់ក្សត្រនឹងមហាជន ទើបទូលលាចេញបួសជាឫសីនៅក្នុងព្រៃហិមពាន្ត បានសម្រេចឈានអភិញ្ញាហោះទៅក្នុងអាកាសបាន លុះយូរមក ក៏មានសេចក្ដីស្រឡាញ់នាងកិន្នរីជាភរិយានៃវិជ្ជាធរ បានរួមអភិរម្យសមរសស្មោះសរតាមប្រពៃណី ក៏ប្រសូតបុត្រ ១ ព្រះអង្គ នាម ភទ្ទកុមារ បុត្រទី ២ នាម មនោសារបិយោរស ព្រហ្មទេវតាបសក៏ចិញ្ចឹមទុក ៗ លុះភទ្ទកុមារធំឡើង ក៏បួសជាឫសី បានឈានលោកីយហោះទៅកាន់ភ្នំចក្កវាឡ រៀនរបៈចប់អស់ត្រៃវេទអាគមមន្តវិជ្ជាទាំងពួងហើយ ត្រឡប់មកនាំមនោសារ ជាប្អូនទៅកាន់សំណាក់ សម្មតិរាជ ថាយកគម្ពីរត្រៃវេទជាដើម ហើយក៏សឹកចេញមកធ្វើរាជការ នឹងមនោសារជាប្អូន ស្ដេចសម្មតិរាជ ទ្រង់តាំងមនោសារជាអ្នកពិភាក្សាសេចក្ដីប្ដឹងផ្ដល់

នៃពលរដ្ឋ មនោសារក៏កាត់សេចក្ដីដោយយុត្តិធម៌ មនុស្ស
នឹងទេវតាក៏សរសើរជាច្រើន ។ មានកាលមួយថ្ងៃនោះ មាន
បុរសពីរនាក់ ដាំត្រសក់ជិតគ្នា មានភ្លឺខណ្ឌកណ្ដាល ត្រសក់
ខាងណោះវារឆ្លងមកខាងណេះ ត្រសក់ខាងណេះវារឆ្លងទៅ
ខាងណោះ ។ បុរសទាំងពីរនាក់ បេះត្រសក់ ក៏កើតទៅជាទាស់
ទែងគ្នា ក៏នាំគ្នាមកប្ដឹងមនោសារ ៗ ក៏កាត់សេចក្ដីថា ត្រសក់
នៅក្នុងចំការអ្នកណា ក៏ជារបស់អ្នកនោះ ។ មនោសារកាត់
សេចក្ដីដូច្នេះមិនយុត្តិធម៌សោះ ទើបបុរសម្នាក់មិនព្រមចូលចិត្ត
ក៏នាំសេចក្ដីនោះទៅក្រាបបង្គំទូលដល់ព្រះបាទសម្មតិរាជៗ ទ្រង់
បង្គាប់ឲ្យអាមាត្យទៅពិនិត្យដល់ទីកន្លែងកើតហេតុ អាមាត្យ
ទៅពិនិត្យឃើញថា ដើមត្រសក់ឆ្លងទៅឆ្លងមក ក៏ឲ្យលើក
ដើមត្រសក់ទៅដាក់កន្លែងដើម ហើយក៏កាត់សេចក្ដីថា ត្រសក់
នៅក្នុងចំការអ្នកណា ជារបស់អ្នកនោះចុះ ។ បុរសទាំង ២
ក៏ព្រមចូលចិត្ត ស្រែកឲ្យសព្ទសាធុការពរ តិះដៀលមនោសារ
ដោយប្រការផ្សេង ៗ ។ មនោសារបានឮមនុស្សទាំងឡាយ



តិះដៀល ក៏មករំពឹងគិតថា យើងធ្វើការក្នុងទីនេះ ប្រកបទៅ
ដោយមោហៈ ទើបបានជាគេតិះដៀល ។ លុះគិតហើយ
ក៏ចេញទៅបួសជាឫសី បានសម្រេចលោកិយឈាន ក៏ហោះ
ទៅកាន់ភ្នំចក្កវាឡ ឃើញគម្ពីរបាលីធម្មសាសន៍ជាអក្សរ ជាប់
នៅនឹងភ្នំចក្កវាឡ មនោសារ ក៏កំណត់សំគាល់ចាំទុកក្នុង
ចិត្ត នាំមកតាំងទុកជាគម្ពីរធម្មសាសន៍ សម្រាប់ពិភាក្សាកាត់
សេចក្ដី នឹងការលត់ពិន័យ ក្នុងដំណើរគតិរបស់តុលាការនឹង
បទព្រះអយ្យកាសម្រាប់ក្សត្រ ដែលបានសោយរាជសម្បត្តិ ។
សង្កត់សង្កិនទូវមនុស្សពាល ឲ្យរាស្ត្របានសេចក្ដីសុខត្រជាក់
ចិត្តដោយយុត្តិធម៌ប្រពៃណី គឺមនុស្សល្អលើកឡើងដំកើងយស
ឯមនុស្សអាក្រក់ ត្រូវសង្កត់សង្កិនជាដើម មនោសារ ចាត់
ចែងគម្ពីរព្រះធម្មសាសន៍នេះរួចហើយ ក៏នាំទៅថ្វាយសម្ដេច
ព្រះសម្មតិរាជ ៗ ក៏លើកទូវគម្ពីរធម្មសាសន៍ នឹងបទអយ្យកា
ឡើងជាច្បាប់សម្រាប់តុលាការ រហូតដល់សព្វថ្ងៃនេះ បើចង់
ដឹងសេចក្ដីពិស្ដារ ចូរទៅមើលគម្ពីរលោកសណ្ឋាន នឹងគម្ពីរ

មហាវង្ស នឹងទេវទូតសូត្រនោះចុះ ។

ស. អក្សរគម្ពីរធម្មសាសន៍ជាដើម អ្នកណាមកសរសេរទុក?

ឆ. អាចារ្យបំពួកខ្លះពោលថា ទេវតាអាយុវែងដឹងហេតុ អាក្រក់ល្អនឹងមានកម្មនិយមខាងមុខ មកបណ្ដាលឲ្យកើតឡើង បំណែកខាងព្រះសូត្រលោកពោលថា គឺអកុសលដែលចាត់ជាសង្ខារមកបណ្ដាលឲ្យកើតឡើង ។

ស. សត្វលោកបង្កើតឡើងហើយ នាំគ្នាប្រកាន់សាសនាដូចម្ដេច?

ឆ. ប្រកាន់ព្រហ្មញ្ញសាសនា ។

ស. ព្រហ្មញ្ញសាសនានោះ ប្រកាន់ដូចម្ដេច?

ឆ. ប្រកាន់មហាព្រហ្មថាជាធំ នាំគ្នាបូជាភ្លើង គឺនាំមកនូវវត្ថុផ្សេង ៗ មានសប្បិប្រេងជាដើម ហើយចាក់ទៅជាវង់មណ្ឌល ដោយខ្សែអម្បោះសីមាជុំវិញ ប្រកបគរគំនរភ្លើងកណ្ដាលផ្ទៃ នាំនូវរបស់ផ្សេង ៗ ដាក់ក្នុងភ្លើង ហើយក៏នាំគ្នាថ្វាយបង្គំបូជាមហាព្រហ្មដូច្នេះក៏មាន ។ ជំពួកខ្លះ លះផ្ទះចោលចេញទៅ



បួសជាឫសីធ្វើការបូជាភ្លើង ស៊ីតែផ្លែឈើ មើមឈើ រក្សាសីល ៥ បំរើននូវកសិណឈាន អភិញ្ញាឈានក៏មាន ជំពួកខ្លះប្រកាន់បណ្ដែតបាប ទៅងូតទឹកក្នុងស្ទឹងអចិរវតីក៏មាន ជំពួកខ្លះប្រកាន់ទេវតា អារក្ស ដ៏ស័ក្ដិសិទ្ធិ ដែលឋិតនៅលើដើមឈើនឹងភ្នំជាដើមក៏មាន ជំពួកខ្លះ ប្រកាន់សាសនាព្រះឥស្សរ នឹងអវតារក៏មាន នឹងធ្វើការមង្គលហើយ ក៏ធ្វើការបន់ស្រន់បូជាក្រុងពាលី បួងសួងបូជាដរាបដល់សម្លាប់សត្វបូជាយញ្ញ តាមគ្នាមកក៏មាន ប្រកាន់មិនស៊ីសាច់ត្រី សត្វមានជីវិតថា មានបាបកម្មក៏មាន ប្រកាន់សំពះព្រះអាទិត្យព្រះចន្ទនឹងទិសទាំង៤ មានទិសខាងលិចជាដើមក៏មាន ប្រកាន់ដរាបចុះមកដល់ឫក្សល្អ យាមល្អ គ្រោះល្អ គ្រោះកាចក៏មាន នឹងប្រកាន់ត្រៃភេទវេទមន្ត អាគម គាថា តាមលំអានគ្រូអាចារ្យ ដែលបានសូត្ររៀនតៗគ្នាមកក៏មាន ទាំងអម្បាលនេះ ឈ្មោះថាព្រហ្មញ្ញសាសនា ។

ស. សាសនាមានតែ ១ ឬច្រើន?

ឆ. មាន ២ គឺ: ព្រហ្មញ្ញសាសនា១ សាមញ្ញសាសនា១

សាមញ្ញសាសនានោះ ជាសាសនាព្រះពុទ្ធអង្គ សំដែងផ្លូវសួគ៌ ផ្លូវនិព្វាន ដល់ពពួកសត្វទាំងឡាយ គឺបានដល់សីល ១ សមាធិ ១ បញ្ញា ១ ។

ស. សីលមានលក្ខណៈធ្វើដូចម្តេច ?

ឆ. សីល មានវិរតិចេតនា លះវៀរមិនធ្វើបាប ដោយកាយវាចាជាលក្ខណៈ ១ សមាធិ មានធ្វើចិត្តឲ្យដំកល់ខ្ជាប់ក្នុងព្រះកម្មដ្ឋាន លះបាបដ៏អាក្រក់ ដែលបង្កើតក្នុងចិត្ត គឺនិវរណៈទាំង ៥ មានកាមឆន្ទៈជាដើមជាលក្ខណៈ ១ បញ្ញា ពិចារណានូវរូបនឹងនាម ដែលជាអនិច្ចំ ទុក្ខំ អនត្តា បែករំលែកសង្ខារឲ្យកើតនិព្វិទាញាណ សេចក្តីនឿយណាយកាត់កងអាសវៈ ជារបស់ត្រាំក្នុងសន្តាន ឲ្យអស់ទៅជាលក្ខណៈ ១ ។

ស. សភាវៈដូចម្តេច ជាតួសីល ?

ឆ. ចេតនាជាតួសីល ដូចមានព្រះពុទ្ធដីកាត្រាស់ទុកថា ចេតនាហំ ភិក្ខវេ សីលំ វទាមិ ម្នាលភិក្ខុទាំងឡាយតថាគតសំដែងថា ចេតនាគិតលះវៀរចាកបាបទាំងពួង ឈ្មោះថាសីល។



ស. សីលនឹងកើតនឹងឋិតនៅដោយហេតុអ្វី ?

ឆ. សីលនឹងកើតឡើង ដោយហិរិនឹងឱត្តប្បៈ គឺសេចក្តីខ្មាសបាប នឹងសេចក្តីតក់ស្លុតរន្ធត់នឹងបាប ។ សីលនឹងឋិតនៅដោយសំវរៈ គឺសេចក្តីសង្រួមប្រយ័ត្នកាយវាចា ។

ស. មនុស្សមិនមានសីល ឈ្មោះថាជាមនុស្សអ្វី ?

ឆ. មនុស្សដែលមិនមានសីលនោះ ឈ្មោះថាមនុស្សក្រៅសាសនា ព្រោះសីល សមាធិ បញ្ញាទាំង ៣ នេះ ចាត់ជាសាសនា ដោយបាលីថា អាទិកល្យាណំ ធម៌ដែលព្រះអង្គត្រាស់ទេសនាពីរោះខាងដើម បាននឹងសីល ១ មជ្ឈេកល្យាណំ ធម៌ដែលព្រះអង្គត្រាស់ទេសនា ពីរោះក្នុងកណ្តាល បាននឹងសមាធិ ១ បរិយោសានកល្យាណំ ធម៌ដែលព្រះអង្គត្រាស់ទេសនា ពីរោះក្នុងទីបំផុត បាននឹងបញ្ញា ១ ព្រោះហេតុនោះ មនុស្សដែលមានសទ្ធា គិតធ្វើបុណ្យឲ្យទានសាងវិហារជាដើម តែមិនមានសីល ក៏នៅជាមនុស្សខាងក្រៅសាសនា ដូចជាព្រះបាទធម្មាសោករាជ ទ្រង់

មានសទ្ធាសាងព្រះវិហារ ៨ ហ្មឺន ៤ ពាន់ សាងព្រះចេតិយ ៨ ហ្មឺន ៤ ពាន់ ធ្វើការឆ្លងថ្វាយត្រៃចីវរបរិក្ខារ ដល់ព្រះអរហន្តជាច្រើន លុះស្រេចស្ដេចទៅសួរព្រះមោគ្គល្លី ដែលជាអង្គព្រះអរហន្តថា ខ្ញុំបានជាញាតិនឹងព្រះសាសនាឬទេ ? ព្រះមោគ្គល្លីថ្វាយព្រះពរថា មហាបពិត្រធ្វើកុសលទាំងអម្បាលនេះ ក៏មិនបានជាញាតិក្នុងព្រះសាសនា ព្រោះជាការបរិច្ចាគខាងក្រៅ មិនទាន់បានតាំងនៅក្នុងសីល ៥ សីល ៨ ដែលជារបស់បរិច្ចាគខាងក្នុង ។ ព្រោះហេតុដូចនេះហើយ មនុស្សសព្វថ្ងៃ ក្នុងកាលបរិច្ចាគទាន ត្រូវនាំគ្នាទទួលសីលជាមុន ដើម្បីឲ្យខ្លួនជាមនុស្សតាំងនៅក្នុងព្រះពុទ្ធសាសនា ។ ទាននោះមានផលក្លាហានច្រើនៗឡើងទៅ ដរាបដល់មាននិស្ស័យបានព្រះនិព្វានជាទីបំផុត ។

ស. សីល មានប៉ុន្មានប្រការ ?

ឆ. សីលមាន ៣ ប្រការ គឺ: ចុឡ្លសីល១ មជ្ឈិមសីល១ មហាសីល១ ។ ចុឡ្លសីលនោះ បានដល់សីល៥



គឺ: បាណាតិបាតា វេរមណី វៀរចាកសម្លាប់សត្វដែលមានជីវិត ឲ្យស្លាប់ដោយខ្លួនឯងនឹងប្រើអ្នកដទៃឲ្យសម្លាប់១ អទិន្នាទានា វេរមណី វៀរលួចលាក់បំបាត់នូវរបស់អ្នកដទៃ ដែលម្ចាស់គេហួងហែងដោយខ្លួនឯង នឹងមិនប្រើគេឲ្យលួចលាក់ ១ កាមេសុ មិច្ឆាចារា វេរមណី វៀរប្រព្រឹត្តកន្លងប្រវេណីក្នុងស្ត្រីដែលមានអ្នកដទៃហួងហែងទុក ឬបើស្ត្រី វៀរប្រព្រឹត្តក្បត់ប្ដីស្វាមី១ មុសាវាទា វេរមណី វៀរនិយាយកុហកភូតភរបញ្ឆោតអ្នកដទៃ ១ សុរាមេរយមជ្ជប្បមាទដ្ឋានា វេរមណី វៀរចាកហេតុជាទីតាំងនៃសេចក្ដីប្រមាទ គឺក្រេបផឹកនូវសុរានឹងមេរ័យ ១ ទាំង ៥ នេះ ឈ្មោះថាចុឡ្លសីល ។ មជ្ឈិមសីលនោះ គឺសីល ៨ ដែលរក្សាក្នុងថ្ងៃ ៥ កើត ៨ កើត ១៤ កើត ១៥ កើត នឹង ៥-៨-១៤-១៥ រោចគឺ: អព្រហ្មចរិយា វេរមណី វៀរសេពនូវមេថុនធម្ម ដែលជាសត្រូវដល់ព្រហ្មចរិយៈ ១ វិកាលភោជនា វេរមណី វៀរចាកបរិភោគអាហារក្នុងវេលាខុស គឺតាំងតែពីព្រះអាទិត្យជ្រេទៅ

ហើយ រហូតដល់អរុណរះបកជាថ្មី ១ នច្ចគីតវាទិត-
វិសូកទស្សនមាលាគន្ធវិលេបនធារណមណ្ឌនវិភូស-
នដ្ឋានា វេរមណី វៀរមើលស្ដាប់ ប្រគំ ច្រៀងរាំ នឹងល្បែង
ផ្សេង ៗ នឹងវៀរប្រដាប់តាក់តែងរាងកាយ ដោយវត្ថុផ្សេង ៗ
នូវលាបលខ្លួនដោយគ្រឿងក្រអូប មានម្សៅប៉ែនទួនជាដើម១
ឧច្ចាសយនមហាសយនា វេរមណី វៀរដេកអង្គុយលើគ្រែ
តាំងដ៏ខ្ពស់-ធំហួសប្រមាណ នឹងពូកទ្រនាប់ ញាត់ដោយគរ
ឬសំឡី នូវកម្រាលល្អវិចិត្រហើយដោយប្រាក់នឹងមាស ១ ។
រាប់យកបាណា១ អទិន្នាទាន១ មុសា១ សុរា១ មកបញ្ចូល
ផង ត្រូវជា ៨ ។ ទាំង ៨ នេះឈ្មោះឧបោសថសីល ។
ឬយវិញទៀត សីល ១០ នៃសាមណេរ ១ នឹងកម្មបថ ១០
គឺកាយកម្ម៣ វចីកម្ម៤ មនោកម្ម៣ ។ កាយកម្ម៣នោះគឺ:
វៀរបាកសម្លាប់សត្វ១ វៀរលួចទ្រព្យគេ ១ វៀរកន្លងប្រពៃណី
ក្នុងស្ត្រី-បុរសដែលគេហួងហែងទុក ១ វចីកម្ម ៤ នោះ គឺ:
វៀរបាកនិយាយកុហក ១ វៀរពោលពាក្យញុះញង់អ្នកដទៃ ១



វៀរពោលពាក្យជេរប្រទេចផ្ដាសាដល់ជាតិត្រកូលវង្សអ្នកដទៃ ១
វៀរនិយាយពាក្យឡេះឡោះ ពាក្យរោយរាយឥតប្រយោជន៍១ ។
មនោកម្ម ៣ នោះ គឺ: មិនលោភសំឡឹងរំពៃចង់បានរបស់គេ១
មិនព្យាបាទគិតគុំគង្គួនគេឲ្យវិនាស ១ មិនមានសេចក្ដីយល់
ឃើញខុស បាកធម្មវិន័យក្នុងពុទ្ធសាសនា ១ ទាំងអស់នេះ
ឈ្មោះហៅ មជ្ឈិមសីល ៗ មហាសីល ឬានដល់សីល ៤ គឺ:
បាដិមោក្ខសំវរសីល មានសេចក្ដីសង្រួមប្រុងប្រយ័ត្នក្នុងសិក្ខា-
បទ ២២៧ មួយ ឥន្ទ្រិយសំវរសីល សេចក្ដីសង្រួមនូវឥន្ទ្រិយ
ទាំង ៦ គឺ: ភ្នែក ត្រចៀក ប្រមុះ អណ្ដាត កាយ ចិត្ត ១ អាជីវ-
បារិសុទ្ធិសីល មានការស្វែងរកបច្ច័យចិញ្ចឹមជីវិតបរិសុទ្ធ តាម
ព្រះពុទ្ធប្បញ្ញត្តិ ១ បច្ចយសន្និស្សិតសីល គឺពិចារណាបច្ច័យ
ទាំង ៤ មានចីវរជាដើម ១ ។

ស. សីលមានវិរតិប៉ុន្មានប្រការ ?

ឆ. វិរតិមាន ៣ ប្រការ គឺ: សម្បត្តវិរតិ វៀរដោយ
កាលដ៏ដល់ព្រម គឺជួបប្រទះនឹងសត្វគួរសម្លាប់ មិនសម្លាប់ ១

ប្រទះទ្រព្យគេគួរលួច មិនលួច១ ជួបនឹងស្ត្រីគួរធ្វើកាមេ មិនធ្វើ១ គួរនឹងនិយាយកុហក មិនកុហក ១ គួរនឹងផឹកសុរានឹងមេរ័យ មិនផឹក ១ ។ សមាទានវិរតិ វៀរដោយសមាទាន គឺទទួលយកអំពីសំណាក់នៃអ្នកដទៃ មានភិក្ខុជាដើម១ ។ សមុច្ឆេទ-វិរតិ វៀរដោយព្រះអរិយមគ្គ កាត់កិលេសបាបធម៌ដាច់ចាកសន្ដាន គឺព្រះអរិយបុគ្គល ១ ។

ស. សីលមានអង្គប៉ុន្មាន ?

ឆ. សីលបាណាតិបាត មានអង្គ៥គឺៈ បាណោ សត្វមានជីវិតរស់នៅ ១ បាណសញ្ញិតា សេចក្ដីសំគាល់ថាសត្វមានជីវិត ១ ឧបក្កមោ មានសេចក្ដីព្យាយាមដោយចេតនាដែលនឹងសម្លាប់សត្វ ១ វធកចិត្តំ មានចិត្តគិតសម្លាប់នូវសត្វឲ្យស្លាប់ ១ តេន មរណំ សត្វដល់នូវសេចក្ដីស្លាប់ដោយចេតនានោះ១ ។ សីលអទិន្នាទាន មានអង្គ ៥ គឺៈ បរបរិគ្គហិតំ របស់អ្នកដទៃហួងហែងទុក ១ បរបរិគ្គហិត-សញ្ញី សំគាល់ថាជារបស់អ្នកដទៃហួងហែង ១ ថេយ្យចិត្តំ



មានចិត្តគិតនឹងលួចយក ១ ឧបក្កមោ មានសេចក្ដីព្យាយាមនឹងលួចយក ១ តេន ហរណំ លួចយករបស់បានមកដោយបើយចិត្តនោះ ១ ។ សីលកាមេ មានអង្គ ៤ គឺៈ អគ-មណីយដ្ឋានំ ស្ត្រីដែលមិនគួរនឹងសេពគប់ គឺស្ត្រីមានអ្នកដទៃហួងហែងទុក ១ ឧបក្កមោ សេវនំ សេពមេថុនដោយសេចក្ដីព្យាយាម ១ តស្មិំ សេវនចិត្តំ ចិត្តគិតសេពមេថុននឹងស្ត្រីនោះ១ មគ្គេន មគ្គប្បដិបាទនំ ញុំាងមគ្គនឹងមគ្គឲ្យដល់គ្នា១ ។ សីលមុសាវាទ មានអង្គ ៤ គឺៈ អតថំ វត្ថុ រឿងដែលពោលមិនពិតត្រង់ ១ - វិសំវាទនចិត្តំ ចិត្តគិតនឹងពោលពាក្យឲ្យខុស ១ តជ្ជោ វាយាមោ ព្យាយាមនឹងពោលឲ្យខុសដោយចិត្តនោះ ១ បរស្ស តទត្ថវិជាននំ ញុំាងអ្នកដទៃឲ្យដឹងច្បាស់នូវសេចក្ដីនោះ១ ។ សីលសុរា មានអង្គ៤ គឺៈ មជ្ជភាវោ ភាវៈនៃទឹកស្រវឹង ១ បាតុកម្យតាចិត្តំ ចិត្តគិតប្រាថ្នាដើម្បីផឹកនូវទឹកស្រវឹង ១ តជ្ជោ វាយាមោ ព្យាយាមនឹងផឹកដោយចិត្តនោះ ១ បិវិត្វា បហំសនំ ផឹកហើយកើតសេចក្ដីរីករាយ ១។

សីលវិកាលភោជនៈ មានអង្គ ៣ គឺៈ វិកាលេ វេលាប្រព្រឹត្ត កន្លងនូវកាលគួរ ១ យាវកាលិកំ ជារបស់គួរបរិភោគក្នុងកាលដ៏គួរ១ អជ្ឈោហរណំ លេបចូលទៅកន្លងបំពង់ក១ ។ សីលនច្ចគី មានអង្គ ៣ គឺៈ នច្ចគីតំ ចម្រៀងរាំរបាំជារបស់លលួងសត្វលោក ១ កត្តុកម្យតាចិត្តំ ចិត្តប្រាថ្នាដើម្បីមើលនឹងស្ដាប់ ១ សុតទស្សនំ ទៅមើលទៅស្ដាប់នូវរាំនឹងច្រៀង ១ ។ សីលមាលា មានអង្គ ៣ គឺៈ មាលាគន្ធាទិវត្ថុមានកម្រងផ្កា នឹងគ្រឿងក្រអូប គ្រឿងលាបជាដើម ១ ធារណានុគា មានសេចក្ដីប្រាថ្នាចូលចិត្តនឹងសៀតទ្រង់ប្រដាប់តាក់តែង ១ ធារណំ សៀតទ្រង់នូវផ្កាឈើនឹងគ្រឿងក្រអូប១ ។ សីលឧច្ចា មានអង្គ ៣ គឺៈ ឧច្ចាសយន-មហាសយនំ ទីដេក-អង្គុយដ៏ខ្ពស់ដ៏ប្រសើរ ១ បរិភោគ-ចិត្តំ ចិត្តគិតនឹងបរិភោគ គឺដេកអង្គុយ ១ បរិភោគករណំ ធ្វើនូវសេចក្ដីបរិភោគ គឺដេកឬអង្គុយ ១ ។ សីលជាតរូប មានអង្គ ៣ គឺៈ ជាតរូបរជតំ របស់ជាប្រាក់មាសរូបិយៈ១



អត្តនោ សន្តកំ ជារបស់នៃខ្លួន ១ បដិគ្គណ្ហាតិ ទទួលយកដោយខ្លួនឯង ឬប្រើគេឲ្យទទួល ១ ។

ស. បុគ្គលដែលរក្សាសីលបរិសុទ្ធ មានអានិសង្សដូចម្ដេច?

ឆ. នឹងមានអានិសង្ស ៥ យ៉ាង គឺៈ ភោគសម្បទា នឹងបរិបូណ៌ដោយភោគសម្បទ មិនវិនាសដោយភ័យផ្សេង ៗ មានចោរលួចជាដើម១ កិត្តិសទ្ទោ នឹងបានសេចក្ដីសរសើរ នឹងសេចក្ដីសុខកាយសុខចិត្ត នូវលាភសក្ការៈតាមកាល ១ អសម្មុឡ្ហោ កាលំ ករោតិ មិនបានវង្វេងហើយធ្វើមរណ-កាល ព្រោះមានសតិសម្បជញ្ញៈខាងមុខ ១ សគ្គំ ឧបបជ្ជតិ ស្លាប់ហើយទៅកើតក្នុងស្ថានសួគ៌ ១ វិសារទោ ជាមនុស្សមានបញ្ញាក្លៀវក្លាក្នុងកណ្ដាលបរិស័ទ ១ ។ មួយទៀត ផលដែលមិនសម្លាប់សត្វ ឲ្យផលមានរូបល្អ អាយុវែងយឺនយូរ ១ ផលដែលមិនលួចទ្រព្យគេ ឲ្យផលមានរូបល្អ មានទ្រព្យហើយមិនមានវិនាសដោយហេតុផ្សេង ៗ មានចោរលួចជាដើម ១ ផលដែលមិនប្រព្រឹត្តកាមេ ឲ្យផលមានរូបល្អ មានបុត្រាបុត្រី

ភរិយា ស្វាមី ទាសាទាសី មិនមានអ្នកដទៃប្រទូសរ៉ាយ តាមអំពើចិត្តរៀងខ្លួនបាន ១ ផលដែលមិនពោលមុសាវាទ ឲ្យផលមានរូបល្អ មានសំឡេងពីរោះ មិនមានអ្នកដទៃមកមួលបង្កាច់ ពោលឲ្យបានសេចក្ដីក្ដៅក្រហាយចិត្ត ១ ផលដែលមិនផឹកសុរាមេរ័យ ឲ្យផលបានរូបល្អ សំឡេងពីរោះ មានបញ្ញាឆ្លាតបេះបរោ មិនមែនជាមនុស្សឆ្កួតលីលា គ ថ្លង់ ខុសបាកមនុស្សទាំងពួង ១ ។

ទោសដែលសម្លាប់សត្វឲ្យស្លាប់ ទៅកើតក្នុងអបាយភូមិ លុះសេសសល់ផលកម្ម ឲ្យផលមកកើតជាមនុស្សមានអាយុខ្លី គឺស្លាប់ក្នុងកាលនៃខ្លួន ឋិតនៅក្នុងបឋមវ័យ ១ ទោសដែលលួចទ្រព្យគេ ឲ្យផលទៅកើតក្នុងអបាយភូមិ លុះសេសសល់ផលកម្ម ឲ្យផលទៅកើតជាមនុស្សក្រីក្រលំបាកអនាថា មានទ្រព្យសម្បត្តិ ក៏វិនាសអស់ដោយចោរលួចជាដើម ១ ទោសកាមេ ឲ្យផលទៅកើតក្នុងអបាយភូមិ លុះសេសសល់ផលកម្ម ឲ្យផលទៅកើតជាមនុស្សខ្ទើយ សូម្បីកើតជាសត្វ



ក៏ត្រូវគេក្រៀវដូចគោជាដើម បើមកកើតជាមនុស្ស បានបុត្រា បុត្រី ភរិយា ស្វាមី ក៏ទូន្មានប្រដៅបានដោយក្រ មានអ្នកដទៃមកលបលួចធ្វើការអាក្រក់ តាមអំពើចិត្តខ្លួន ១ ទោសមុសាវាទ ឲ្យផលទៅកើតក្នុងអបាយភូមិ លុះសេសផលកម្ម ឲ្យផលទៅកើតជាមនុស្ស មានក្លិនស្អុយចេញពីមាត់ និយាយសេចក្ដីអ្វី មិនមានអ្នកដទៃប្រកាន់ជឿជាក់ មានតែអ្នកដទៃ យកសេចក្ដីខុស មិនពិត មកនិយាយល់លួង ចោទប្រកាន់ទោសផ្សេង ៗ ឲ្យបង់ទ្រព្យសម្បត្តិ ១ ទោសផឹកសុរា ឲ្យផលទៅកើតក្នុងនរករងទុក្ខវេទនា នាយនិរយបាលបំផឹកនូវទឹកទង់ដែង ទឹកធ្លាក់ដល់ក ធ្លាយដល់ពោះ, ពោះវៀនដាច់ខ្ទាត់ខ្ទាយ ។ កម្មមិនទាន់អស់ដរាបណា ក៏សោយទុក្ខដរាបនោះ កាលបើរួចអំពីនរក មកកើតជាមនុស្ស ដោយសេសសល់ផលកម្មនោះក៏ក្លាយទៅជាមនុស្សឆ្កួតលីលា ខុសមនុស្សទាំងពួង ១ ។

ស. នរក បុគ្គលណាសាង ?

ឆ. មិនមានបុគ្គលណាសាងទេ ។

ស. បើមិនមានបុគ្គលណាសាង តើកើតឡើងដោយហេតុអ្វី ?

ឆ. កើតឡើងដោយហេតុ គឺអកុសលកម្ម ដែលធ្វើអាក្រក់ដោយកាយវាចាចិត្ត ឈ្មោះថា អបុញ្ញាភិសង្ខារតាក់តែងឲ្យកើតឡើង សម្រាប់ទូន្មានសត្វ ដែលមានចិត្តបាបអាក្រក់ តាមទោសានុទោសដ៏ធ្ងន់និងស្រាល ។

ស. នរក មានប៉ុន្មាន ?

ឆ. នរកធំ មាន ៨ រណ្ដៅ ៗ ដំបូងឈ្មោះសញ្ជីវនរក សត្វសោយទុក្ខវេទនា គឺនាយនិរយបាលប្រហារដោយអាវុធកាប់កាត់ជាកំណាត់តូចកំណាត់ធំ មានខ្យល់បក់មកឲ្យកើតឡើង សោយទុក្ខតទៅ ដោយទោសបាណាតិបាត គឺសម្លាប់សត្វអំពីជាតិមុន មានអាយុវែង ៥០០ ឆ្នាំជាកំណត់ ។ រាប់ជាឆ្នាំក្នុងឋានមនុស្ស ត្រូវជា ៩ លានឆ្នាំ ទើបស្មើនឹង ១ ថ្ងៃ ១ យប់ក្នុងនរកនោះ ។



រណ្ដៅទី ២ ឈ្មោះកាលសូត្រនរក សត្វសោយទុក្ខវេទនាដេកលើផ្ទាំងដែកក្រហម ផ្ទាត់ដោយខ្សែបន្ទាត់ដែក ឲ្យដាច់ជាកំណាត់ ៗ ហើយក៏កើតឡើងវិញសោយទុក្ខតទៅ ដោយទោសដែលពោលពាក្យមុសាវាទ អំពីជាតិមុន អាយុវែង ១.០០០ ឆ្នាំជាកំណត់ រាប់ជាឆ្នាំមនុស្ស ៣ កោដិ ៩ លានឆ្នាំ ត្រូវថ្ងៃ ១ យប់ ១ ក្នុងនរកនោះ ។

រណ្ដៅទី ៣ ឈ្មោះសំឃាដនរក សត្វសោយទុក្ខដោយភ្នំភ្លើងរមៀលមកកិនកំទេចកាយនៃសត្វ ឲ្យល្អិតជាធូលីទៅ កម្មមិនទាន់អស់ ក៏កើតឡើងវិញសោយទុក្ខទៀត ។ ដោយទោសដែលដុតសត្វទាំងរស់ ឲ្យស្លាប់ក្នុងគំនរភ្លើង មានអាយុវែង ពីរពាន់ឆ្នាំជាកំណត់ រាប់ជាឆ្នាំក្នុងមនុស្សបាន ១៤ កោដិ ៤ លានឆ្នាំ ទើបត្រូវជាថ្ងៃ ១ យប់ ១ ក្នុងនរកនោះ ។

រណ្ដៅទី ៤ ឈ្មោះរោរុវនរក សត្វសោយទុក្ខ មានឈូកដែកដ៏មុត សត្វអង្គុយក្នុងផ្កាឈូក មានដៃនឹងជើងបូលទៅក្នុងផ្កាឈូកពាក់កណ្ដាល ៗ ភ្លើងឆេះទាំងខាងក្រោម

ភាងលើឲ្យវិនាស កម្មមិនទាន់អស់ ក៏កើតឡើងវិញ ឲ្យសោយទុក្ខតទៅទៀត ដោយទោសអទិន្នាទាន លួចទ្រព្យគេអំពីជាតិមុន នឹងសាក្សីកោង មានអាយុវែង ៤ ពាន់ឆ្នាំ រាប់ជាឆ្នាំក្នុងមនុស្ស បាន ១៧ កោដិ ៦ លានឆ្នាំ ទើបត្រូវជាថ្ងៃ១ យប់ ១ ក្នុងនរកនោះ ។

រណ្ដៅទី ៥ ឈ្មោះមហារោរុវនរក សត្វសោយទុក្ខ មានឈូកដែកធំមុត នាយនិរយបាលឲ្យឡើងអង្គុយលើផ្កាឈូក ហើយយកញញួរដែក ឆេះក្រហមជារណ្ដាតភ្លើង វាយក្បាលឲ្យបែកទំលាយ មិនទាន់អស់កម្ម ក៏កើតឡើងវិញ សោយទុក្ខវេទនាតទៅ ដោយទោសលួចទ្រព្យសង្ឃ នឹងទោសកាមេសុ-មិច្ឆាចារ អាយុវែង ៨ ពាន់ឆ្នាំ រាប់ជាឆ្នាំក្នុងមនុស្សនេះ២៣០ កោដិ ៤ លានឆ្នាំ ទើបត្រូវជាថ្ងៃ ១ យប់ ១ ក្នុងនរកនោះ ។

រណ្ដៅទី ៦ ឈ្មោះតាបនរក សត្វសោយទុក្ខ មានឈើស្លូលដែកធំ ប៉ុនដើមត្នោត ឆេះជារណ្ដាតភ្លើង ចាក់កាយសត្វឲ្យឆ្អិន មានឆ្កែមកខាំស៊ី កម្មមិនទាន់អស់ ក៏កើតឡើង



វិញ សោយទុក្ខតទៅ ដោយទោសដែលផឹកសុរាមេរ័យ នឹងប្រទូសរ៉ាយ មាតាបិតា-សមណព្រាហ្មណ៍ជាអ្នកមានសីល នឹងមិនមានសេចក្ដីគោរពក្នុងព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ មានអាយុវែង ១៦ ពាន់ឆ្នាំ រាប់ជាឆ្នាំក្នុងមនុស្ស ៩២០ កោដិ ៦ លាន ទើបត្រូវជា ១ ថ្ងៃ ១ យប់ក្នុងនរកនោះ ។

រណ្ដៅទី ៧ ឈ្មោះមហាតាបនរក សត្វសោយទុក្ខច្រើន នាយនិរយបាលដេញឲ្យឡើងលើភ្នំរងើកភ្លើង មានខ្យល់បក់ឲ្យធ្លាក់ចុះមក មានឈើស្លូលជាវិការៈនៃដែក ប៉ុនដើមត្នោត ចាក់កាយ ១ ដើមក៏មាន ពីរដើមក៏មាន ៣ ក៏មាន អកុសលមិនទាន់អស់ ក៏កើតឡើងវិញ សោយទុក្ខតទៅ ដោយទោសកាលខ្លួនកើតជាស្ដេច សម្លាប់មនុស្សមិនយុត្តិធម៌ នឹងទោសជាចៅក្រមជំរះសេចក្ដីមិនយុត្តិធម៌ ឃើញតែសំណូក មនុស្សដែលចាញ់ ឲ្យឈ្នះ មនុស្សដែលឈ្នះ ឲ្យចាញ់ នឹងជំរះក្ដីដោយអគតិ ៤ គឺៈ ឆន្ទាគតិ ទោសាគតិ, មោហាគតិ, ភយាគតិ មិនជំរះដោយបទព្រះអយ្យកានឹងធម្មសាសន៍ នឹង

ទោសពោលតិះដៀលពុទ្ធវចនៈរបស់ព្រះពុទ្ធអង្គ នឹងទោសជាភិក្ខុឡុះឡោះ មិនរក្សាសីលឲ្យបរិសុទ្ធ អាយុវែងពាក់កណ្ដាលកប្ប ។

រណ្ដៅទី ៨ ឈ្មោះអវីចិនរក សត្វសោយទុក្ខវេទនាដោយអណ្ដាតភ្លើងរុងរឿង ដុតសត្វឲ្យឆេះទាំងយប់ទាំងថ្ងៃមិនចេះរលត់ឡើយ កម្មមិនទាន់អស់ ក៏សោយទុក្ខតទៅទៀត។ ដោយទោស ដែលសម្លាប់មាតាបិតា សម្លាប់ព្រះអរហន្តប្រទូសរ៉ាយព្រះពុទ្ធអង្គ ញុះញង់សង្ឃឲ្យបែកបាក់គ្នា នឹងមនុស្សធ្វើបាបជានិច្ច ដរាបអស់ជីវិត នឹងភិក្ខុត្រូវបារាជិកបិទបាំងទុក នឹងទោសប្រទូសរ៉ាយនាងភិក្ខុនីដែលជាអរហន្ត ។ កម្មទាំងអម្បាលនេះ ជាកម្មធ្ងន់ ឲ្យទៅកើតក្នុងអវីចិ មានអាយុ ១ កប្ប តែកម្មក្រៅនេះ បើធ្វើដោយចិត្តក្លៀវក្លា ក៏អាចនឹងឲ្យទៅកើតក្នុងអវីចិបាន តែមិនទៀង ឬបើទៅកើតក៏មានអាយុតិចចុះមក ។ ឯព្រះទេវទត្ត អាយុ ១ កប្ប មានកាយកំពស់ ១ យោជន៍ ជើងជាន់លិចចុះទៅក្នុងផែនដី



ជាវិការៈនៃដែកក្រហម ត្រឹមកជើង ខាងក្បាល ត្រឹមគុម្ពត្រចៀក, ត្រឹមកដៃទាំងពីរ មានដែកស្រួចប៉ុនដើមត្នោត ចាក់ដោតទំលុះកាយ ។ អណ្ដាតភ្លើងឆេះប្រសព្វមកទាំង ៤ ទិស, ខាងលើ ឆេះប្រសព្វចុះមកដល់ក្រោម, ខាងក្រោម ឆេះប្រសព្វដល់ខាងលើ ឆេះកាយព្រះទេវទត្តក្រហមដូចដែកដុតទាំងថ្ងៃទាំងយប់ ។

ស. សត្វនរក មានរបស់អ្វីជាអាហារ ?

ឆ. មានកម្មជាអាហារចិញ្ចឹមជីវិតសត្វនរកមិនឲ្យស្លាប់ ឬស្លាប់ហើយ ក៏ឲ្យកើតឡើងវិញ សោយទុក្ខតទៅទៀត ។

ស. សត្វក្នុងនរក កាលនឹងកើតឡើងនោះ មានមាតាបិតា ឬមិនមាន ?

ឆ. មិនមានមាតាបិតាទេ ដែលកើតឡើងដោយអកុសលកម្មឲ្យកើត ធំឡើងតែម្ដង ។

ស. នរក មានទំហំប៉ុន្មាន ?

ឆ. នរកធំទាំង ៨ រណ្ដៅ ទំហំទទឹងនឹងបណ្ដោយ

១យោជន៍ដិបគ្នា មានសណ្ឋានដូចហិប មានទ្វារទាំង ៤ អន្លើៗ

ស. នរក មានតែ ៨ រណ្ដៅប៉ុណ្ណោះទេឬ?

ឆ. នរកធំ មាន ៨ រណ្ដៅ ប៉ុន្តែក្នុងរណ្ដៅនីមួយៗ មានបរិវារ ៥៦ រណ្ដៅ ព័ទ្ធជុំវិញខាងក្រៅ មានស្ដេចយមរាជ ៨ ជានាយក មានអាមាត្យ និងនាយនិរយបាលជាអ្នកបំរើ ។

ស. នាយនិរយបាល ដែលធ្វើការក្នុងនរកនោះ មិនក្ដៅទេឬ?

ឆ. មិនក្ដៅទេ ព្រោះមានកម្មធ្វើទុក ឲ្យកើតជានាយនិរយបាលសម្រាប់ប្រហារសត្វនរក ។

ស. ធ្វើកម្មដូចម្ដេច ទើបបង្កើតជានាយនិរយបាល?

ឆ. មានសេចក្ដីត្រេកអរក្នុងកម្មអាក្រក់នៃអ្នកដទៃ ឃើញគេសម្លាប់ម្រឹគ បំពុលត្រីបានច្រើនៗ ក៏មានចិត្តត្រេកអរតាម ឬដឹងថា គេសម្លាប់ពស់កាចក្រពើកាច ក៏មានចិត្តត្រេកអរ ។

ស. ស្ដេចយមរាជជំរះសេចក្ដីសត្វនរកនោះ ជំរះដូចម្ដេច?

ឆ. កាលបើសត្វធ្លាក់ចុះទៅដល់ស្ដេចយមរាជៗ សួរ



ទេវទូតទាំង ៥ ប្រការ គឺសួរថា កាលអ្នកទាំងពួងនៅក្នុងមនុស្សលោក បានឃើញទេវទូតទាំង ៥ ខ្លះឬទេ? សត្វដែលមាននិស្ស័យធ្លាប់បានពិចារណាទេវទូតទាំង ៥ អំពីនៅក្នុងមនុស្ស ក៏រឭកបាន ទើបប្រាប់ស្ដេចយមរាជៗ ក៏លែងទៅ សត្វដែលមិនមាននិស្ស័យ ក៏ស្ងៀមនៅ ស្ដេចយមរាជទើបសួរថា អ្នកទាំងពួង កាលនៅក្នុងមនុស្ស បានកសាងកុសលអ្វីទុកខ្លះ? សត្វដែលបានធ្វើកុសលទុក ក៏រឭកបាន ទើបប្រាប់ដល់ស្ដេចយមរាជៗក៏លែងទៅ សេសសល់តែសត្វដែលរឭកពុំបាន ស្ដេចយមរាជទើបប្រាប់ថា កម្មដែលអ្នកបានធ្វើទុកមកក៏ច្រើន អ្នកក៏ត្រូវទៅតាមកម្ម ថាហើយក៏អង្គុយស្ងៀម នាយនិរយបាលក៏ដឹងអាការៈ ចូលទៅទាញកន្ត្រាក់សត្វទាំងនោះទៅប្រហារ ហើយបោះចុះទៅក្នុងរណ្ដៅនរក តាមកម្មរបស់សត្វដែលបានធ្វើទុកមកនោះ ។ ពោលមកនេះដោយចំណែកសត្វដែលមានកម្មស្រាល បើសត្វដែលមានកម្មធ្ងន់ ស្ដេចយមរាជមិនត្រូវសួរ អំណាចកម្មនាំទៅនរកតែម្ដង ។

ស. ទេវទូតទាំង ៥ នោះ បានដល់របស់អ្វី ?

ឆ. បានដល់ក្មេង ៗ ដែលដេកផ្ងារ នៅលើសំពត់ទ្រនាប់ ១ មនុស្សចាស់ជរា ១ មនុស្សមានជម្ងឺ ១ មនុស្សស្លាប់ ១ មនុស្សអ្នកទោស ១ ។

ស. សត្វនរកនោះ នឹងមានគេទៅជួយឲ្យរួចទុក្ខបានខ្លះឬទេ ?

ឆ. មិនមានអ្នកណាជួយបានទេ សូម្បីព្រះមហាមោគ្គល្លានមានឫទ្ធិច្រើន ក៏ជួយមិនបានដែរ គ្រាន់តែចុះទៅជួយឲ្យបានសេចក្ដីសុខមួយភ្លែត ៗ ប៉ុណ្ណោះ ព្រះមហាថេរក៏វិលត្រឡប់មកវិញ សត្វក៏សោយទុក្ខតទៅ ។

ស. ទានការកុសលដែលញាតិធ្វើហើយ ឧទ្ទិសឲ្យ នឹងបានដល់សត្វនរកខ្លះឬទេ ?

ឆ. មិនបានទេ ព្រោះសត្វនោះសោយទុក្ខវេទនាក្លៀវក្លា មិនមានចិត្តស្ងប់ ទទួលអនុមោទនាចំណែកការកុសលបាន កាលណាបើបានមកកើតជាបរទត្តូបជីវីប្រេត មានទោសស្រាល ទើបទទួលចំណែកកុសលបាន ។



ស. នរកនោះ តាំងនៅក្នុងទីណា ? នៅលើផែនដី ឬក្នុងផែនដី ?

ឆ. តាំងនៅក្រោមជម្ពូទ្វីប រៀង ៗ គ្នាជាលំដាប់ ៗ ចុះដរាបដល់អវិចិជាទីបំផុត នឹងថានៅលើដី ក៏ទេ នឹងថានៅក្រោមដី ក៏ទេ ទីនោះជាចន្លោះទទេ មិនមានទេវតាទេវបុត្រឡើយ ។

ស. ភ្នំត្រីកូដ តាំងនៅក្នុងទីណា ?

ឆ. តាំងនៅខាងក្រោមភ្នំព្រះសុមេរុ ។

ស. ភ្នំព្រះសុមេរុ ទំហំប៉ុន្មាន ?

ឆ. កំពស់ ៨៤.០០០ យោជន៍ ទំហំវាស់ដោយមូល ២៤០.០០០ យោជន៍ លិចចុះទៅក្នុងសមុទ្រ ៨៤.០០០ យោជន៍ ។

ស. សត្វធ្លាក់ទៅនរកនោះ ធ្លាក់ចុះទៅក្នុងរណ្ដៅធំមុនឬរណ្ដៅតូចមុន ?

ឆ. តាមកម្មរបស់សត្វ បើសត្វធ្វើបាបដោយចិត្តជា

ដំបូង ហើយកម្មក៏ស្រាលចុះមក ៗ ឲ្យធ្លាក់ទៅក្នុងនរកធំមុន ហើយទើបត្រឡប់មកធ្លាក់ក្នុងនរកជាបរិវារក្រោយ ។ បើសត្វធ្វើបាបដោយចិត្តទន់មុនហើយ ត្រឡប់ក្លៀវក្លាឡើងជាខាងក្រោយ ឲ្យសត្វធ្លាក់ទៅក្នុងនរកជាបរិវារមុន ទើបឲ្យទៅធ្លាក់ក្នុងនរកធំជាងក្រោយ ។ បើធ្វើបាបដោយចិត្តទន់ ឬក្លៀវក្លាតែម្តង ក៏ធ្លាក់ទៅក្នុងនរកដំបន់ឯណានីមួយ ។

ស. លោកន្តរនរកនោះ តាំងនៅក្នុងទីណា ?

ជ. តាំងនៅក្នុងចន្លោះភ្នំចក្កវាឡទាំង ៣ ។ ទីនោះជាចន្លោះទទេ ទំហំ៨ពាន់យោជន៍ មិនមានរបស់អ្វីបិទបាំងសត្វក្នុងលោកន្តរនរកនោះ មិនមានបក្ខវិញ្ញណា ដ្បិតទីនោះងងឹតជានិច្ច ព្រះអាទិត្យព្រះចន្ទបំភ្លឺមិនដល់ ព្រះពុទ្ធមកត្រាស់ម្តង បានឃើញគ្នាមួយភ្លែត ៗ ដូចផ្លេកបន្ទោរ កាយសត្វក្នុងលោកន្តរ ទំហំ ៣ គាវុត គឺ ៣០០ សិន មានក្រចកដ៏វែងដូចចប តោងសសៀរតាមភ្នំចក្កវាឡ ដូចសត្វប្រចៀវ កាលបើ



ជួបប្រទះគ្នា ក៏ចាប់ហែកសាច់គ្នាស៊ី របូតធ្លាក់ចុះទៅក្នុងទឹកក្រូត ក៏រលាយកាយខ្ទេចល្អិតអស់ទៅ ហើយក៏កើតឡើងសោយទុក្ខតទៅទៀត ។

ស. សត្វដែលធ្លាក់ទៅក្នុងលោកន្តរនោះ ព្រោះធ្វើកម្មអ្វី?

ជ. សត្វដែលជានិយតមិច្ឆាទិដ្ឋិ ប្រកាន់ថាលោកនេះទៀង, លោកខាងមុខមិនមាន, គុណមាតាបិតា មិនមាន សួគ៌នរក មិនមាន. ស្លាប់ហើយសូន្យ, បុណ្យបាប មិនមាន, ប្រកាន់ថា ខ្លួនធ្លាប់កើតជាមនុស្ស ក៏កើតជាមនុស្សដដែល, ធ្លាប់កើតជាសត្វ ក៏កើតជាសត្វ ។ ការប្រកាន់បែបនេះ លុះស្លាប់ហើយ ក៏ទៅបង្កើតក្នុងលោកន្តរនរក ។

ស. សត្វទៅកើតក្នុងលោកន្តរហើយ កាលណានឹងរួចចាកទុក្ខ ?

ជ. មិនមានកំណត់ ព្រះពុទ្ធអង្គមិនព្យាករ ។

ស. សត្វដែលធ្លាក់ទៅក្នុងនរកសោយទុក្ខនោះ សភាវៈអ្វីដែលធ្លាក់ទៅសោយទុក្ខ ?

ឆ. ធម្មជាតុ ៧ ប្រការ ដែលសោយទុក្ខ ។

ស. ធម្មជាតុ ៧ បានដល់អ្វី ?

ឆ. បានដល់ភវង្គ សេចក្ដីកើត ១ មនោ សេចក្ដីបង្អោន ១ ចិត្ត សេចក្ដីគិត ១ សញ្ញា សេចក្ដីកត់សំគាល់ ១ វិញ្ញាណំ សេចក្ដីដឹងច្បាស់ ១ សង្ខារំ សេចក្ដីតាក់តែង ១ វេទនា សេចក្ដីសោយ ១ ។

ស. ធម្មជាតិដូចម្ដេច ដែលនាំឲ្យសត្វកើត ?

ឆ. បាប នាំទៅបង្កើតក្នុងនរក បុណ្យ នាំទៅបង្កើតក្នុងឋានសួគ៌ ។

ស. ធ្វើបាបហើយ ត្រឡប់ទៅធ្វើបុណ្យកុសលឲ្យច្រើនៗ ដោះបាបបានឬមិនបាន ?

ឆ. សាសនាព្រះពុទ្ធអង្គនៃយើង មិនទេសនាប្រដៅសត្វថា ធ្វើបុណ្យលាងបាបបានទេ, បំណែកបុណ្យ ក៏ទៅតាមបុណ្យ, បំណែកបាប ក៏ទៅតាមបាប ដូចទឹកលាយនឹងប្រេង ចូលគ្នាមិនបាន ។ បំណែកសាសនាដទៃៗ មាន



ព្រះយេស៊ូជាដើម គេថា លាងបាបបាន ។

ស. ដែលឈ្មោះថា ប្រេតៗនោះ មានរូបកាយដូចម្ដេច ? នៅក្នុងទីណា ?

ឆ. សត្វដែលរួចអំពីនរកមកហើយ តែមិនទាន់អស់ផលកម្ម សេសផលឲ្យមកកើតជាប្រេតនៅលើផែនដី មាននៅលើភ្នំគិជ្ឈកូដជាដើម ឲ្យសោយទុក្ខផ្សេងៗ មានភ្លើងឆេះទាំងយប់ទាំងថ្ងៃ មានសេចក្ដីស្រេកឃ្លានជានិច្ចខ្លះ ដើររកស៊ីរបស់ស្អុយរលួយខ្លះ ឱទាំស៊ីសាច់ខ្លួនឯងខ្លះ ដើរចាំទទួលបំណែកកុសលអ្នកដទៃខ្លះ សោយទុក្ខក្នុងវេលាថ្ងៃខ្លះ ក្នុងវេលាយប់ខ្លះ ផ្សេងៗគ្នាច្រើនណាស់ រាប់មិនអស់ ។

ស. សេចក្ដីទុក្ខនៃសត្វក្នុងនរកនោះ មានកំណាត់ដូចម្ដេច ?

ឆ. មានកំណាត់ ៧ ប្រការ គឺៈ កក្ខលា ក្ដៅអាក្រក់ណាស់ នឹងធន់មិនបាន ១ តិព្វា ក្ដៅខ្លាំងណាស់ នឹងធន់មិនបាន ១ កដុកា ក្ដៅក្រហាយជានិច្ច ១ ឧសិកា ក្ដៅ

ដោយអណ្ដាតភ្លើងជាទិច្ច ១ កម្បិតា កាយក្ដៅញាប់ញ័រជាទិច្ច ១ សន្តុបត្តិ ក្ដៅរោលរាលទូទៅក្នុងរាងកាយទាំងមូល ១ កន្និឥបរិនេវមុខា មានតែសេចក្ដីយំស្រែកកន្ទក់កន្ទេញជាប្រធាន ១ ។ មួយទៀត ព្រះពុទ្ធអង្គទ្រង់ត្រាស់នឹងព្រះអានន្ទថា ម្នាលអានន្ទ ! ព្រះមហាក្សត្រឲ្យប្រហារចោរទាំងឡាយដោយដាវ មួយថ្ងៃ ៣០០ ដាវ គឺវេលាព្រឹក ១០០ ថ្ងៃត្រង់ ១០០ ល្ងាច ១០០ ក៏ជាជាងសត្វក្នុងនរក ១០០ គុណ ព្រោះប្រហារគ្រប់ហើយ ក៏មានវេលាឈប់ខ្លះ ដែលសត្វសោយទុក្ខក្នុងនរកនោះ មិនមានចន្លោះឈប់ឈរឡើយ ។

ស. សត្វដែលទៅនរកនឹងទៅសួគ៌នោះ តើទៅខាងណាច្រើនជាង ?

ឆ. សត្វទៅនរកច្រើនជាង ដ្បិតព្រះអានន្ទបានទូលសួរព្រះពុទ្ធអង្គ ៗ ទ្រង់ត្រាស់ឧបមាដោយព្រះហស្ត ដែលចុកចុះក្នុងផែនដី មានធូលីជាប់នឹងចុងក្រចកមកតិចណាស់



ធូលីដែលជាប់នៅនឹងផ្ទៃផែនដីនោះ ច្រើនណាស់ មិនបានប្រមាណ ។ ព្រះពុទ្ធអង្គទ្រង់ត្រាស់ថា ម្នាលអានន្ទ សត្វដែលទៅកើតក្នុងសុគតិ តិចណាស់ ដូចធូលីដែលជាប់នៅនឹងចុងក្រចក សត្វដែលទៅអបាយ ច្រើនណាស់ ដូចធូលីដែលនៅលើផែនដី ។

ប្រការមួយទៀត បុរាណាចារ្យសំដែងសេចក្ដីថា សត្វដែលទៅនរក ដូចរោមគោ សត្វដែលទៅសុគតិ ដូចស្នែងគោ សេចក្ដីនេះក៏ឃើញមែន ដ្បិតមនុស្សដែលមានសីល ៥-៨ តិចណាស់ ។ ដែលមិនមានសីល ៥-៨ ច្រើនណាស់ រាប់មិនបាន ។ មួយទៀត អ្នកដែលទៅកាន់សុគតិ ក៏ទៅដោយអំណាចនៃផលសីល ។

ស. ឋានសួគ៌ បុគ្គលណាសាង ?

ឆ. មិនមានបុគ្គលណាសាងឡើយ ។

ស. បើមិនមានបុគ្គលណាសាង តើកើតឡើងដោយហេតុអ្វី ?

ឆ. កើតឡើងដោយកាមាវចរកុសល ដែលមហាជនធ្វើ មានឲ្យទានរក្សាសីលជាដើម ។

ស. ឋានសួគ៌ មានប៉ុន្មានជាន់ ?

ឆ. មាន ៦ ជាន់ គឺៈ ចាតុម្មហារាជិកា ជាដំបូង មានទេវតា ៤ អង្គជាធំ គឺៈ ព្រះបាទធតរដ្ឋ ជាធំលើគន្ធព្វ នៅខាងទិសបូព៌ា ១ ព្រះបាទវិរុឡ្ហកៈ ជាធំលើកុម្ភណ្ឌ នៅខាងទិសទក្សិណា ១ ព្រះបាទវិរូបក្ខៈ ជាធំលើនាគទាំងពួង នៅខាងទិសបស្ចិម ១ ព្រះបាទកុវេរុរាជ ជាធំលើយក្ខនៅខាងទិសឧត្តរ ១ ។ វិមាននៃចាតុម្មហារាជិកាទាំង ៤ ដ៏ហើយដោយប្រាក់ តាំងនៅលើកំពូលភ្នំយុគន្ធរ ទាំង ៤ ទិស កំពស់ពីផែនដីឡើងទៅ ៤ ហ្មឺន ២ ពាន់យោជន៍ ។ ស្ដេចចាតុម្មហារាជិកាទាំង ៤ ព្រះអង្គ ជានាយបញ្ជីធំ ត្រួតត្រាមនុស្សដែលធ្វើបាបបុណ្យច្រើនឬតិចប៉ុន្មាន ក៏បញ្ជូនបញ្ជីទៅតាមទី គឺមនុស្សធ្វើបាប ក៏បញ្ជូនទៅឲ្យស្ដេចយមរាជ ឯមនុស្សដែលធ្វើបុណ្យ ក៏បញ្ជូនទៅឲ្យព្រះឥន្ទ្រាធិរាជ ។ ស្ដេច



ចាតុម្មហារាជិកា មានអាយុ ៥០០ ឆ្នាំទិព្វ រាប់ជាប្រៃយប់ក្នុងមនុស្សនេះ ៩ លាន ៥០ ឆ្នាំមនុស្ស ត្រូវជា ១ យប់ ១ ថ្ងៃក្នុងឋាននោះ ។

ជាន់ទី ២ ឈ្មោះតាវតិង្ស ទទឹង ១ ហ្មឺនយោជន៍ តាំងនៅលើកំពូលភ្នំព្រះសុមេរុ ដ៏ហើយដោយកែវ ៧ ប្រការ ។ វេជយន្តប្រាសាទ មានកំពស់ ១.០០០ យោជន៍ ដ៏ហើយទៅដោយមាសមានមុខ៤ មានកណ្ដឹងដ៏ហើយដោយមាស ដោយជុំវិញ មានឆត្រមាសកំពស់ ៣ យោជន៍ បោះជុំវិញ មានអគ្គមហេសី ៤ គឺនាងសុជាតា១ នាងសុនន្ទា១ សុចិត្តា១ នាងសុធម្មា១ ។ មាននាងអប្សរ ២ កោដិ ៥ លានជាបរិវារ ។ ព្រះឥន្ទមានកាយកំពស់ ៣ គាវុត មានរស្មីផ្សាយចេញ ចម្ងាយ ១២ យោជន៍ មានគ្រឿងប្រដាប់ទម្ងន់ ៦០ រទេះ មានសួនផ្កា ទំហំ ៥០០ យោជន៍ ស្រះបោក្ខរណី ទំហំ ៥០០ យោជន៍ ដ៏ហើយទៅដោយខ្សាច់ប្រាក់-មាស មានដើមបារិច្ឆត្តព្រឹក្សទំហំ ១០០ យោជន៍ កំពស់ ១០០ យោជន៍ ជាឈើប្រចាំភព

មានផែនថ្មបណ្ឌុកម្ពល បណ្ដោយ ៦០ យោជន៍ ទទឹង ៥០ យោជន៍ កម្រាស់ ១៥ យោជន៍ បល្ល័ង្ក កំពស់ ១ យោជន៍ ក្នុងវិមានត្រៃត្រឹង្សនោះ ប្រកបដោយរបាំរាំច្រៀងផ្គុំប្រគំជានិច្ច មានចុឡាមណីចេតិយជាទីបូជា មានអាយុ ១ ពាន់ឆ្នាំទិព្វ រាប់ឆ្នាំក្នុងមនុស្សនេះ ៣ កោដិ ៦ លានឆ្នាំ ជា ១ ថ្ងៃ ១ យប់ក្នុងជាន់ត្រៃត្រឹង្សៈ វាស់ពីផែនដីឡើងទៅ ៨ ម៉ឺន ៤ ពាន់យោជន៍ ។

ស. ព្រះឥន្ទ្រ បានសាងកុសលអ្វី ?

ឆ. បានសាងថ្នល់ ផ្លូវ សាលា ជីកស្រះ បំរើមាតាបិតា គោរពអ្នកចាស់ព្រឹទ្ធាចារ្យ ពោលពាក្យសច្ចៈ ប្រកបដោយធម៌ មិនពោលពាក្យញុះញង់ បង្កាច់បង្ខូចអ្នកដទៃ ពោលតែពាក្យពីរោះទន់ផ្អែម មិនពោលពាក្យទ្រគោះ មិនកំណាញ់ លះទ្រព្យឲ្យជាទាន មានខន្តី អំណត់មិនខឹង ចងពៀរ មិនព្យាបាទជាទីបំផុត ។

ទី ៣ ជាន់យាមា វិមានកែវផ្លេកអណ្ដែតនៅក្នុងអាកាស កាយទេវតានោះ កំពស់ ៨ ពាន់ព្យាម អាយុ ២ ពាន់ឆ្នាំ



ទិព្វ រាប់ឆ្នាំក្នុងមនុស្ស ៤ កោដិ ៤ លាន ២ សែនឆ្នាំ ទើបបាន ១ ថ្ងៃ ១ យប់ក្នុងយាមា កំពស់ពីត្រៃត្រឹង្សឡើងទៅ ៤ ម៉ឺន ២ ពាន់យោជន៍ មានសម្បត្តិនឹងសុខច្រើនជាងត្រៃត្រឹង្ស ។

ទី ៤ ជាន់តុសិត វិមានកែវមណី ខ្ពស់ឡើងទៅអំពីជាន់យាមា ៦៤.០០០ យោជន៍ មានអាយុ ៤.០០០ ឆ្នាំទិព្វ មានបរិវារ ១ សែនកោដិ មានរស្មីកាយភ្លឺផ្សាយទៅ ១២ យោជន៍ ។ រាប់ថ្ងៃ ១ យប់ ១ ក្នុងមនុស្ស ៥ កោដិ ៦ លាន នឹង ១ សែនឆ្នាំ ទើបបានជាយប់ ១ ថ្ងៃ ១ ក្នុងតុសិត ដោយអានិសង្សរក្សាឧបោសថសីល ៨ ប្រការជាដើម ។

ទី ៥ ជាន់និម្មានរតី វិមានកែវ ៧ ប្រការ ខ្ពស់ឡើងទៅអំពីតុសិត ៣ សែន ៣ ម៉ឺន ៦ ពាន់យោជន៍ ទេវតាមានកំពស់ ៣៦.០០០ ព្យាម មានអាយុ ៨.០០០ ឆ្នាំទិព្វ រាប់ថ្ងៃ ១ យប់ ១ ក្នុងមនុស្ស ២០៣ កោដិ នឹង ១៨០ ឆ្នាំ ទើបបានជា ១ ថ្ងៃ ១ យប់ ក្នុងជាន់និម្មានរតី ។

ទី ៦ ជាន់បរនិម្មិតវសវត្តី វិមានកែវ ៩ ប្រការ ខ្ពស់

ឡើងទៅអំពីនិម្មានរតី ៦២២.០០០ យោជន៍ កាយទេវតា កំពស់ ៦១,០០ ព្យាម អាយុ ១៦.០០០ ឆ្នាំទិព្វ រាប់ថ្ងៃ១យប់១ ក្នុងមនុស្ស ១៨ កោដិ ៦០០ ឆ្នាំ ទើបបានជាយប់ ១ថ្ងៃ១ ក្នុងជាន់នោះ មានព្រះបាទវិសវត្តីមារទេវបុត្រជាធំជាងទេវតាទាំងពួង ។

ស. ទេវតាមានតែ ៦ ជាន់ប៉ុណ្ណោះឬ ?

ឆ. ទេវតានៅមានច្រើន បំណែកដែលរាប់ជាន់ ៗ មានតែ ៦ ជាន់ប៉ុណ្ណោះ ។

ស. មានច្រើននៅទីណាទៅ ?

ឆ. ភូមិទេវតា នៅលើផែនដី, គង្គាទេវតា នៅលើមហាសមុទ្រធំតូច ស្ទឹង ទន្លេ នៅក្នុងរោង សាលា ដើមឈើធំ នឹងអាកាសជាដើម ។

គ្រានេះ នឹងសំដែងដោយអាយុព្រហ្ម ១៦ ជាន់ ដំបូងព្រហ្មបារិសជា អាយុមួយកប្ប បែងចេញជា ៣ បំណែក បំណែក ១ ជាអាយុនៃព្រហ្មជាន់ដំបូង ។ គំរប់ ២ ព្រហ្ម



បរោហិតា អាយុកន្លះកប្ប ។ គំរប់ ៣ មហាព្រហ្ម អាយុ ១កប្ប ។ ទាំង ៣ ជាន់នេះ កំពស់បាន ១ លាន ៨ សែន ៣ ហ្មឺន ៦ ពាន់យោជន៍ បំណែកក្នុងភូមិ បឋមជ្ឈាន ។ គំរប់ ៤ បរិត្តាភាព្រហ្ម អាយុ ២ កប្ប ។ គំរប់ ៥ អប្បមាណាភាព្រហ្ម អាយុ ៤ កប្ប ។ គំរប់ ៦ អាភស្សរាព្រហ្ម អាយុ ៨ កប្ប ៣ ជាន់នេះ បំណែកក្នុងភូមិទុតិយជ្ឈាន ។ គំរប់ ៧ បរិត្តសុភាព្រហ្ម អាយុ ១៦ កប្ប ។ គំរប់ ៨ អប្បមាណសុភាព្រហ្ម អាយុ ៣២ កប្ប ។ គំរប់ ៩ សុភកិណ្ហកាព្រហ្ម អាយុ ៦៤ កប្ប ទាំង ៣ ជាន់ កំពស់ ២ លាន ៥ សែន ២ ហ្មឺន៦ពាន់ នឹង១រយយោជន៍ បំណែកក្នុងភូមិតតិយជ្ឈាន ។ គំរប់ ១០ វេហប្ផលាព្រហ្ម អាយុ ៥០០ កប្ប ។ គំរប់ ១១ អសញ្ញីព្រហ្ម មិនមានចិត្តវិញ្ញាណ អាយុ ៥០០ កប្ប នៅស្មើនឹងវេហប្ផលា ។ គំរប់ ១២ អវិហាព្រហ្ម អាយុ ១.០០០ កប្ប ។ គំរប់ ១៣ អតប្បាព្រហ្ម អាយុ ២.០០០ កប្ប ។ គំរប់ ១៤ សុទស្សាព្រហ្ម អាយុ ៤.០០០ កប្ប ។ គំរប់ ១៥ សុទស្សីព្រហ្ម

អាយុ ៨.០០០កប្ប ។ គំរប់១៦ អកនិដ្ឋព្រហ្ម អាយុ១៦.០០០កប្ប។ កំពស់ ៨.៦៤៣.២០០ យោជន៍ ។ ព្រហ្មទាំង,៧ ជាន់នេះ ប្រចក្នុងចតុត្ថជ្ឈាន បើទំលាក់ផែនថ្មប៉ុនកំពូលប្រាសាទ ចុះមក ចំនួន ៣ ខែ ៨ ថ្ងៃ នឹង ២០ នាទី ទើបដល់ផែនដី ។

ចំណែកអរូបព្រហ្ម ៤ ជាន់ ព្រហ្មជាន់ដើម មានអាយុ ២ ហ្មឺនមហាកប្ប ។

ព្រហ្មគំរប់ ២ អាយុ ៤០.០០០ មហាកប្ប ។

ព្រហ្មគំរប់ ៣ មានអាយុ ៦០.០០០ មហាកប្ប ។

ព្រហ្មគំរប់ ៤ មានអាយុ ៨៤.០០០ មហាកប្ប ។

ស. សត្វដែលទៅកើតក្នុងព្រហ្មលោកនោះ ដោយ គុណដូចម្តេច ?

ឆ. ទៅដោយឈាន ។

ស. ឈានមានប៉ុន្មានប្រការ ?

ឆ. ឈានមាន ២ ប្រការ គឺៈ អារម្មណូបនិជ្ឈាន បាន ខាងឈានលោកិយ របស់ឫសីមុនីក្រៅសាសនា ១ លក្ខណូ-



បនិជ្ឈាន បានដល់ឈានព្រះពុទ្ធអង្គ ហៅថាលោកុត្តរឈាន១។

ស. ឈានទាំង ២ មានលក្ខណៈដូចម្តេច ?

ឆ. លោកិយឈាន មានលក្ខណៈកាន់យកនូវពណ៌ខៀវ ស ក្រហម លឿង នឹងបីតិសុខជាអារម្មណ៍ សង្កត់កិលេស ក្នុងសន្តាន ឲ្យរម្ងាប់ជាវិក្ខម្ភនប្បហាន អាស្រ័យបីតិជាអភិញ្ញា ហោះទៅក្នុងអាកាសបាន តែមិនមែនជាផ្លូវមគ្គ ផល និព្វាន មិនមែនជាសមុច្ឆេទប្បហាន កាត់កិលេសឲ្យដាច់បាន ។ គ្រាន់តែសោយសុខក្នុងបីតិឈាន លុះទំលាយសង្ខារហើយ ទៅកើតក្នុងព្រហ្មលោកជាទីបំផុត ហើយឲ្យវិលវល់ស្លាប់កើត ទៅក្នុងសង្សារវដ្ត ដូចជាព្រហ្មដែលចុះមកកើតក្នុងខាងដើម ភទ្ទកប្បជាតំណមកដល់សត្វថ្ងៃនេះ ។

មួយទៀត លោកិយឈានជារបស់វិនាសបាប់ ដូចជា ទេវទត្ត បានឈានសមាបត្តិជាលោកិយ ដឹងចិត្តនៃសត្វ ហើយ ធ្វើបាដិហារិយ៍ ហោះទៅទូន្មានព្រះបាទអជាតសត្រូវ ឲ្យជ្រះ ថ្លា ហើយប្រដៅឲ្យព្រះបាទអជាតសត្រូវសម្លាប់បិតា ។ តាំង

ពីនោះមក ព្រះទេវទត្តក៏សូន្យបាកឈាន ។ រឿងមួយទៀតថា មានសាមណេរមួយរូប បានលោកិយឈាន ហោះទៅបិណ្ឌបាត បានឃើញកូនក្រមុំជាងដំបាញ ក៏ចូលចិត្តកើតសេចក្ដីស្រឡាញ់ត្រេកអរ លោកិយឈានរបស់លោក ក៏សាបសូន្យទៅ ពឹងត្រឡប់មកវិញក៏មិនរួច ។

លោកុត្តរឈាននោះ មិនបានកាន់យកនូវវិណ្ណាសណ្ឋានបីតិសុខ កាលបើចិត្តជាឯកគ្គតាសមាធិហើយ ក៏កំណត់ពិចារណានាមរូបថា នាមរូបំ អនិច្ចំ ខយដ្ឋេន ថានាមធម៌គឺវេទនា សញ្ញា សង្ខារ វិញ្ញាណ នឹងរូបធម៌ មានសក់ រោមក្រចក ធ្មេញជាដើម មិនទៀង មានសេចក្ដីប្រែប្រួលទៅជាធម្មតា នាមរូបំ ទុក្ខំ ភយដ្ឋេន នាមរូបនាំមកនូវទុក្ខព្រោះហេតុប្រាកដទៅដោយភយន្ដរាយផ្សេងៗ នាមរូបំ អនត្តា អសារកដ្ឋេន នាមរូបជាអនត្តា ព្រោះហេតុមិនមានខ្លឹមសារ មិនបានប្រព្រឹត្តទៅក្នុងអំណាចអ្នកណា ការដែលពិចារណាខន្ធទាំង ៥ គឺៈ រូប វេទនា សញ្ញា សង្ខារ



វិញ្ញាណក្នុងផ្លូវបញ្ញានេះ ឈ្មោះថា វិបស្សនាញាណ ជាធម៌ឲ្យកើតសេចក្ដីនឿយណាយឆ្ងាយចាកសេចក្ដីស្រឡាញ់ សេចក្ដីក្រោធ លោភ ទឹង វង្វេង ជាអង្គបញ្ញា សេចក្ដីដឹងក្នុងសង្ខារ ទើបបាននាមថា លោកុត្តរឈាន ឯលោកុត្តរឈានមាន ៤ គឺ បឋមជ្ឈាន មានអង្គ ៥ វិតក្កោ លើកចិត្តឡើងកាន់ព្រះកម្មដ្ឋាន ១ វិចារោ ពិចារណាព្រះកម្មដ្ឋាន ១ បីតិ សេចក្ដីឆ្អែតកាយឆ្អែតចិត្ត ១ សុខំ សេចក្ដីសុខកាយសុខចិត្ត ១ ឯកគ្គតា ចិត្តតាំងខ្ជាប់ក្នុងព្រះកម្មដ្ឋាន ១ ។ ទុតិយជ្ឈាន មានអង្គ ៣ គឺៈ បីតិ ១ សុខ ១ ឯកគ្គតា ១ ។ តតិយជ្ឈាន មានអង្គ ២ គឺៈ សុខ ១ ឯកគ្គតា ១ ។ ចតុត្ថជ្ឈាន មានអង្គ ២ គឺៈ ឧបេក្ខា ១ ឯកគ្គតា ១ ។

ឈ. បុគ្គលដែលឃើញអ្នកដទៃធ្វើការកុសល ហើយមានចិត្តជ្រះថ្លា អនុមោទនា នឹងមានផលដូចម្ដេច ?

ឆ. បុគ្គលដែលមានសេចក្ដីត្រេកអរក្នុងការកុសល នៃអ្នកដទៃ ហើយអនុមោទនានោះ បាត់ជាកាមាវចរកុសល

ឲ្យផលទៅកើតជាទេវតា ក្នុងឋានព្រហ្មបារាជិកា សោយសម្បត្តិសុខក្នុងវិមានប្រាក់ មាននាងអប្សរចោមរោមជាយសបរិវារ មានគ្រឿងប្រដាប់ល្អឱភាស ព្រោងព្រាយដោយរស្មី ។

ស. ឱកាសលោក នឹងវិនាសដោយទឹកនឹងខ្យល់នោះដូចម្តេច ?

ឆ. ឱកាសលោកនឹងវិនាសដោយទឹកនឹងខ្យល់នោះ គឺប្លែកគ្នាខ្លះ ដូចគ្នាខ្លះ នឹងវិនាសដោយភ្លើង ក្នុងទីនេះនឹងពោលនូវវិធីដែលប្លែកគ្នា ។

ឯឱកាសលោកដែលនឹងវិនាសដោយទឹកនោះ មានមហាមេឃតាំងឡើងមុន ដរាបដល់ព្រះអាទិត្យកើតឡើង ២ វង់ សោ ទារុណកោ មហាមេឃោ គ្រានោះ មហាមេឃទឹកក្រុតបង្កើតឡើងឲ្យភ្លៀងទឹកក្រុតគ្រាប់តូច ៗ ធ្លាក់ចុះមកមុន ហើយក៏ធំឡើងៗ ដរាបលិចទាំងមួយសែនកោដិចក្កវាឡ ដើមឈើ ផែនដី នឹងភ្នំទាំងឡាយ ក៏វិនាសល្អិតខ្ទេចទៅ ដូចជាដុំអំបិល ពោះបុះក្នុងទឹក លិចអំពីមនុស្ស ឡើងហួតដល់សុភកិណ្ហាព្រហ្ម។



កាលដល់កំណត់ ក៏រីងស្ងួតអស់ទៅ ជាអាកាសទទេ ងងឹតទាំងមួយសែនកោដិចក្កវាឡ លុះដល់កំណត់នឹងតាំងឡើង ក៏តាំងឡើងដូចសំដែងហើយអំពីខាងក្រោយ ។ កំណត់ភ្លៀងទឹកក្រុតធ្លាក់ចុះមកមួយអសង្ខេយ្យ, ជាអាកាសទទេ ងងឹតមួយអសង្ខេយ្យ ដរាបដល់នឹងតាំងកកើតជាផែនដី លុះដល់មានព្រះចន្ទ ព្រះអាទិត្យកើតឡើងមក ១ អសង្ខេយ្យ សេចក្តីចំរើនក៏បេះតែចំរើនឡើងជាលំដាប់ ៗ គ្នា ដូចពាក្យដែលសំដែងមកហើយនោះ ។

គ្រានេះ នឹងសំដែងអំពីឱកាសលោក ដែលវិនាសដោយខ្យល់ ដែលដូចគ្នា មិនបានពោលទេ នឹងពោលតែសេចក្តីដែលប្លែកគ្នាថា មានមហាមេឃតាំងឡើងមុន លុះដល់ព្រះអាទិត្យកើតឡើង ២ វង់ សោ វាតោ ឧដ្ឋាតិ បង្កើតជាខ្យល់ទឹកក្រុតបក់មកដំបូង ក៏បក់ស្រាល ៗ យូរមក ខ្លាំងឡើង ៗ គួចយកធូលី ខ្សាច់ ក្រួស ថ្ម ដើមឈើ ភ្នំតូច-ធំ ឲ្យអណ្តែតទៅក្នុងអាកាស វិនាសមិនបានធ្លាក់ចុះមក ទើបខ្យល់

ភ្លាំងខាងក្រោមផែនដី បក់ផែនដីឲ្យត្រឡប់ឡើង ហើយអណ្តែតទៅក្នុងអាកាស ផែនដីកម្រាស់ ២៤០.០០០ យោជន៍ក៏បែកខ្ចាត់ខ្ចាយជាកំណាត់ ៗ ១ យោជន៍ខ្លះ ពីរយោជន៍ខ្លះ ហើយក៏វិនាសបាត់ទៅក្នុងអាកាស តាំងអំពីមនុស្សឡើងទៅដល់ព្រហ្ម ៩ ជាន់ កាលដល់កំណត់ហើយ ខ្យល់ក៏សាបសូន្យទៅ ឲ្យជាអាកាសទទេ ងងឹតទៅទាំងមួយសែនកោដិបក្កវាឡ កាលនឹងតាំងឡើង ក៏តាំងឡើងជាលំដាប់ ៗ គ្នាដូចសំដែងមកហើយនោះ ។ មួយវិញទៀត មហាកប្បតាំងឡើងហើយ មានកប្បតូច ៗ ៣ ទៀត គឺ រោគន្តរកប្ប ឲ្យសត្វទាំងឡាយស្លាប់ដោយរោគផ្សេង ៗ ជាច្រើន ព្រោះសត្វក្រាស់ដោយមោហៈ ១ សត្ថន្តរកប្ប ឲ្យសត្វទាំងឡាយកាប់ចាក់សម្លាប់គ្នានឹងគ្នា ស្លាប់ជាច្រើន ព្រោះសត្វក្រាស់ដោយទោសៈ ១ ទុព្ភិក្ខន្តរកប្ប ឲ្យកើតរបស់ដែលប្រើប្រាស់ចិញ្ចឹមជីវិតថ្លៃណាស់ ព្រោះសត្វក្រាស់ដោយលោភៈ ១ ។

ស. មនុស្សក្នុងជម្ពូទ្វីបនេះ មានភាសានិយាយផ្សេងៗ



គ្នា នឹងនិយាយ ឬនឹងប្រព្រឹត្តកាយវាចា សេចក្តីសុចរិតក៏ខុស ៗ គ្នា រូបរាងកាយ អធ្យាស្រ័យក៏ខុស ៗ គ្នា មិនដូចទ្វីបទាំង៣ មានឧត្តរកុរុទ្វីបជាដើម ព្រោះហេតុដូចម្តេច ?

ជ. ក្នុងដើមភទ្ទកប្ប ព្រះបាទសម្មតិរាជ បែងជម្ពូទ្វីបជា ១០១ ចំណែក ឲ្យកូននឹងចៅម្នាក់ ៗ ទៅនៅក្នុងចំណែកនីមួយ ៗ ។ ជនទាំងអម្បាលនោះ ធ្លាប់ទៅមករកគ្នា លុះអស់បុណ្យមាតាបិតាទៅ ក៏មិនបានទៅមករកគ្នា មនុស្សទាំងអម្បាលនោះ ប្រាថ្នានឹងប្រព្រឹត្តដូចម្តេច ក៏ប្រព្រឹត្តទៅតាមអំពើចិត្តនៃខ្លួនជាពួក ៗ ។ ឯមនុស្សទាំងអម្បាលនោះ សឹងប្រកបដោយលោភៈ ទោសៈ មោហៈ ទិដ្ឋិ មានៈ ច្រើនក្នុងសន្តាន ព្រោះហេតុនោះ រាងកាយ សង្ខារ នឹងសេចក្តីប្រព្រឹត្តអាក្រក់ ល្អ ទើបមិនដូចគ្នា ។ មនុស្សក្នុងទ្វីបទាំង ៣ នោះជាបុត្ររបស់ព្រះបាទសម្មតិរាជ មួយអង្គ ៗ ទៅនៅទ្វីបមួយ ៗ ជាពួកជាមួយគ្នា នឹងប្រព្រឹត្តអ្វីក៏ប្រព្រឹត្តស្មើគ្នា ព្រោះហេតុនោះ ទ្វីបទាំង ៣ ទើបមានសេចក្តីសុខច្រើន ។

ស. ឱកាសលោកតាំងឡើងហើយ ព្រះពុទ្ធអង្គនឹងចុះមកត្រាស់ក្នុងកាលណា ?

ឆ. រាប់ដោយអាយុសត្វ ១ អសង្ខ្យៃ ។ ក្នុង ១ រយឆ្នាំបិយចុះ ១ ឆ្នាំ ដរាបដល់សត្វអាយុ ១០ ឆ្នាំ ហើយទ្វេចំរើនឡើងទៅបន្តិច ៗ ដល់អសង្ខ្យៃ ហើយបិយចុះមកដល់ ៦ ហ្មឺនឆ្នាំ ហៅថា អន្តរកប្ប ប្រមាណផែនដីដុះឡើងកំពស់ ១ យោជន៍ ។ ព្រះពុទ្ធអង្គព្រះនាមកុកុសន្ធោ កើតឡើងមក ត្រាស់ជាដំបូង ប្រដៅសាសនា គឺ សីល សមាធិ បញ្ញា បង្ហាញផ្លូវសួគ៌ផ្លូវនិព្វាន ព្រះជន្ម ៦០.០០០ ឆ្នាំ មានដើមកាមព្រឹក្ស ២ ដើម ឲ្យសម្រេចប្រយោជន៍ដល់មហាជនទាំងពួង លុះព្រះអង្គរំលត់ខន្ធចូលកាន់និព្វានហើយ កំណត់សាសនាទុក ៦ ០.០០០ ឆ្នាំ ស្មើនឹងព្រះជន្មព្រះអង្គដែរ ។

លុះកន្លងមក ផែនដីដុះខ្ពស់ឡើង ១ យោជន៍ ព្រះពុទ្ធអង្គគំរប់ ២ ព្រះនាមកោនាគមនោ បានមកត្រាស់ប្រដៅសត្វដោយសីល សមាធិ បញ្ញា ឲ្យសត្វទាំងឡាយសម្រេចផ្លូវសួគ៌-



និព្វាន មានព្រះជន្ម ៤០.០០០ ឆ្នាំ ព្រះអង្គចូលនិព្វាន ក៏កំណត់សាសនាទុក ៤០.០០០ ឆ្នាំ ស្មើនឹងព្រះជន្មព្រះអង្គដែរ ។

លុះកន្លងមក ផែនដីដុះខ្ពស់ឡើង ១ យោជន៍ ព្រះពុទ្ធអង្គគំរប់ ៣ ព្រះនាមកស្សបោ បានមកត្រាស់ក្នុងលោក ប្រដៅសត្វដោយព្រះសទ្ធម្ម គឺ សីល សមាធិ បញ្ញា ឲ្យសត្វទាំងឡាយសម្រេចក្នុងផ្លូវសួគ៌-និព្វាន មានព្រះជន្ម ២០.០០០ ឆ្នាំ ព្រះអង្គរំលត់ខន្ធចូលបរិនិព្វាន កំណត់សាសនា ២ ហ្មឺនឆ្នាំ ស្មើនឹងព្រះជន្ម ។

លុះកន្លងមក ផែនដីដុះឡើង ១ យោជន៍ ព្រះពុទ្ធអង្គព្រះនាមគោតមោ បានត្រាស់ក្នុងលោក ប្រដៅសត្វដោយសីល សមាធិ បញ្ញា ឲ្យសត្វសម្រេចក្នុងផ្លូវសួគ៌-និព្វាន មានព្រះជន្ម៨០ឆ្នាំ ព្រះអង្គរំលត់ខន្ធចូលបរិនិព្វាន កំណត់សាសនាទុក ៥.០០០ ឆ្នាំ ច្រើនជាងព្រះជន្មព្រះអង្គ ។

ស. ព្រះពុទ្ធអង្គព្រះនាមគោតមោ កើតឡើងក្នុងប្រទេសណា ? ជាជាតិអ្វី ? មាតាបិតាឈ្មោះអ្វី ? កើតនៅឆ្នាំខែ

ថ្ងៃណា ?

ឆ. ព្រះអង្គកើតក្នុងមជ្ឈិមប្រទេស ជាកណ្ដាលទ្វីប ជាជាតិអរិយកៈ និយាយភាសាមគធៈ កើតក្នុងនគរកបិលភ័ស្តុ ជាបុត្រក្សត្រ បិតាព្រះនាមសុទ្ធោទនៈ មាតាព្រះនាមសិរីមហាមាយាទេវី ជាអគ្គមហេសីនៃព្រះបាទសិរិសុទ្ធោទនៈ ព្រះអង្គច្យុតចុះមកបាកតុសិត កាន់យកបដិសន្ធិ នៅថ្ងៃព្រហស្បតិ៍ ពេញបូណ៌មីខែអាសាឍ ឆ្នាំរកា នៅក្នុងព្រះឧទរនៃព្រះមាតា ១០ ខែ ទៅប្រសូតនៅលម្ពិនីវ័ន ជាបន្លោះនគរទេវទហៈ នឹងកបិលភ័ស្តុ នាឆ្នាំច ខែពិសាខ ថ្ងៃពុធ ។ ប្រសូតហើយយាងទៅបាន ៧ ជំហាន ផែនដីញាប់ញ័រ ព្រះមាតាប្រសូតព្រះរាជបុត្របាន ៧ ថ្ងៃ ទំលាយខន្ធទៅកើតក្នុងតុសិត ។ ព្រះអង្គសោយសុខនៅក្នុងប្រាសាទទាំង ៣ ។ ទ្រង់ព្រះនាមព្រះសិទ្ធត្ថរាជកុមារ ព្រះជន្មបាន ១៦ ឆ្នាំ មានព្រះអគ្គមហេសីព្រះនាមពិម្ពា មានព្រះឱរស ១ ព្រះអង្គ ព្រះនាមរាហុល ។ បានសោយរាជសម្បត្តិជាក្រសត្រិយ៍ដ៏ប្រសើរ ។



ស. ព្រះបរមពោធិសត្វអាស្រ័យហេតុអ្វី ទើបចេញបព្វជ្ជា?

ឆ. ព្រះអង្គអាស្រ័យទេវទូតទាំង ៤ គឺ ឃើញមនុស្សចាស់ជរា ១ មនុស្សឈឺ ១ មនុស្សស្លាប់ ១ ឃើញភេទបព្វជ្ជា ១ ។ ព្រះអង្គឃើញទេវទូតទាំង ៤ នេះ ទើបចេញបព្វជ្ជា ។

ស. កាលព្រះអង្គយាងទៅនោះ ព្រះអង្គបានអ្វីជាយានជំនិះ?

ឆ. ព្រះអង្គឡើងគង់លើសេះកណ្ឋកៈ រត់ទៅក្នុងវេលាយប់ ជាមួយនាយឆន្នអាមាត្យ ឆ្លងស្ទឹងអនោមានទី ហើយទើបកាត់ព្រះកេសា ទ្រង់ភេទបព្វជ្ជា ធ្វើពិព្យាយាមអស់ ៦ ព្រះវស្សា ក៏បានសម្រេចព្រះពោធិញាណ ក្រោមដើមពោធិព្រឹក្សប្របផ្ទេរស្ទឹងនេរញ្ជរា ជាអង្គព្រះសាស្ដា ប្រដៅសត្វក្នុងផ្លូវសួគ៌-និព្វាន ដោយធម៌ជាខ្លឹមសារ គឺ សីល សមាធិ បញ្ញា ។

ស. ព្រះអង្គបានត្រាស់ជាព្រះពុទ្ធនោះ ដោយធម៌អ្វី ?

ឆ. ព្រះអង្គបានត្រាស់ដោយកម្លាំងព្រះបញ្ញាបារមី ចាស់ក្លា ពិចារណាសង្ខារ ហើយក៏ជ្រើសរកហេតុ រកបច្ច័យ ទីកើតទីរលត់ នៃសង្ខារ ។ លុះបានបញ្ញាញាណចាស់ក្លា ជ្រាប

ច្បាស់សំខារហើយ ក៏កើតនិព្វិទា សេចក្ដីនឿយណាយក្នុងសំខារ ទើបដល់វិរាគធម៌ ព្រះអរិយៈនូវវិមុត្តិធម៌ គឺព្រះអរិយ-ផល ផុតបាកកិលេសជាសមុច្ឆេទប្បហាន មានខន្ធសន្ដានដ៏បរិសុទ្ធ ។

ស. ព្រះពុទ្ធអង្គបង្កើតមុន ឬព្រះធម៌បង្កើតមុន ?

ឆ. ព្រះពុទ្ធអង្គកើត ២ ដង គឺកើតដោយរូបកាយ បាននឹងខន្ធ ៥ អាយតនៈ ធាតុ ឥន្ទ្រិយ ១ កើតដោយនាមកាយ គឺ សីល សមាធិ បញ្ញា មគ្គ ផល ១ ។ ចំណែកកើតដោយរូបកាយនោះ នៅមិនទាន់បានជាព្រះពុទ្ធ លុះដល់កើតនាមកាយទើបបានជាព្រះពុទ្ធ ព្រោះហេតុនោះឯង ទើបដឹងថា ព្រះធម៌កើតហើយ ទើបកើតព្រះពុទ្ធ ។

ស. ព្រះពុទ្ធអង្គជាធំ ឬព្រះធម៌ជាធំ ?

ឆ. ព្រះធម៌ជាធំ ដ្បិតមានបាលីថា សទ្ធម្មោ គរុកាតព្វោ ប្រែថា ព្រះពុទ្ធអង្គទាំងឡាយ ជាអ្នកគោរពនូវព្រះធម៌ទាំងអស់។

ស. សភាវៈដូចម្ដេច ឈ្មោះថាធម៌?



ឆ. ធម៌មាន ៣ គឺៈ បរិយត្តិធម៌ ធម៌ដែលសូត្ររៀនបានដល់ព្រះសូត្រ ព្រះវិន័យ ព្រះបរមត្ថ ១ បដិបត្តិធម៌ បានដល់សីល សមាធិ បញ្ញា ១ បដិវេធធម៌ បានដល់មគ្គ ផលនិព្វាន ១ ។

ស. កាលព្រះពុទ្ធអង្គមិនទាន់បានត្រាស់ ព្រះធម៌នៅក្នុងទីឯណា ?

ឆ. ព្រះធម៌នៅជិត ៗ នេះឯង តែមិនមានអ្នកឯណាដឹងច្បាស់ ព្រោះអវិជ្ជាបិទបាំងបញ្ញាឲ្យរលត់ទៅ មិនឲ្យដឹងច្បាស់សីល សមាធិ បញ្ញា ខន្ធ ៥ អាយតនៈ ធាតុ ឥន្ទ្រិយ៍ នឹងមិនឲ្យដឹងច្បាស់ បុណ្យបាប ហេតុឲ្យកើតបុណ្យ ហេតុឲ្យកើតបាប នឹងទុក្ខ ហេតុកើតទុក្ខ ទីរលត់ទុក្ខ នឹងផ្លូវរលត់ទុក្ខមិនឃើញធម៌ទាំងអម្បាលនោះ ព្រោះអវិជ្ជា ។

ស. ដែលឈ្មោះថា បុណ្យបាប នឹងហេតុនៃបុណ្យបាបនោះ បាននឹងអ្វី ?

ឆ. បុណ្យនោះ គឺៈ មនសា ចេ បាននឹងចិត្តដែលជ្រះថ្លា

ក្នុងគុណព្រះរតនត្រៃជាដើម ១ សំវេគោ បាននឹងសេចក្តី សង្វេគតក់ស្លុតចិត្តក្នុងសង្សារ ១ តេ សុចរិតា សេចក្តី សុចរិតទាំង ៣ គឺៈ កាយសុចរិត ១ វចីសុចរិត ១ មនោ សុចរិត ១ ទាំងអម្បាលនេះ ឈ្មោះថា បុណ្យ ។ ហេតុ នៃបុណ្យនោះ គឺៈ អលោភោ នាម ហេតុ សេចក្តីមិនលោភ ជាហេតុឲ្យបរិច្ចាគទានបាន ១ អទោសោ សីលភ ហេតុ សេចក្តីមិនក្រោធ ជាហេតុឲ្យរក្សាសីលបាន ១ អមោហោ នាម ហេតុ សេចក្តីមិនវង្វេង ជាហេតុឲ្យចំរើនភាវនា បាន ១ ។ បាបនោះ បានដល់ការមិនជ្រះថ្លា ១ មិនមាន សេចក្តីសង្វេគ ១ មិនមានសេចក្តីសុចរិតដោយកាយវាចាចិត្ត ១ ។ ហេតុនៃបាប បាននឹងសេចក្តីលោភ ១ សេចក្តីទឹង ១ សេចក្តីវង្វេង ១ ។ កងទុក្ខ បានដល់សេចក្តីកើត ចាស់ ឈឺ ស្លាប់ជាដើម១ ហេតុដែលកើតកងទុក្ខ បានដល់តណ្ហាទាំង ៣ មានកាមតណ្ហាជាដើម១ ទីរលត់នៃកងទុក្ខ បាននឹងព្រះនិព្វាន១ ផ្លូវដែលនឹងរលត់នៃកងទុក្ខ បាននឹងសីល សមាធិ បញ្ញា ១ ។



ស. ព្រះពុទ្ធអង្គបានត្រាស់ហើយ ទេសនាប្រោសអ្នក ណាមុន ?

ឆ. ព្រះអង្គត្រាស់ទេសនាព្រះធម្មចក្កប្បវត្តនសូត្រ ទៀប នគរពារាណសី ប្រោសបញ្ចវគ្គិយភិក្ខុទាំង ៥ មុន ហើយ ទើបទេសនាប្រោសព្រះយសកុលបុត្រជាលំដាប់ ដរាបដល់ ប្រោសព្រះបាទពិម្ពិសារៈ ស្តេចគង់នៅក្នុងវេឡុវនារាម ប្រោស ព្រះមោគ្គល្លាននឹងព្រះសារីបុត្រ អគ្គសាវកទាំងពីរហើយ ប្រជុំ ព្រះអរហន្ត ១២៥០ អង្គ ក្នុងថ្ងៃពេញបូណ៌មីខែមាឃ ហើយ យាងទៅនគរកបិលភស្តុ ប្រោសព្រះបិតានឹងព្រះញាតិវង្សទាំង ពួង ។ លុះបាន ៧ ព្រះវស្សា ទៅគង់នៅក្នុងនរសាវត្ថី ធ្វើ បាដិហារិយ៍ទូន្មានតិត្ថិគ្រណ្ឌ ព្រះអង្គយាងឡើងទៅចាំវស្សា នៅឋានត្រៃត្រឹង្ស ត្រាស់ទេសនាព្រះសត្តប្បករណាភិធម្ម ៧ ព្រះគម្ពីរ សងគុណព្រះមាតាអស់ ៣ ខែ លុះចេញវស្សា ទ្រង់ យាងចុះបាកតាវតិង្សមកកាន់នគរសង្កស្សៈ បើកលោក ឲ្យ មនុស្ស នឹងទេវតា នឹងសត្វនរក ឃើញនូវគ្នានឹងគ្នា ហើយ

យាងប្រោសសត្វឲ្យបានផ្លូវសួគ៌-និព្វាន ដរាបដល់ព្រះជន្មាយុ
នៃព្រះអង្គបាន ៨០ ឆ្នាំ ទើបទទួលនិមន្តស្ដេចមារ ដាក់បង់
ព្រះជន្មាយុសង្ខារ ក្នុងថ្ងៃពេញបូណ៌មី ខែមាឃ ហើយនាំ
ព្រះសង្ឃទៅកាន់នគរកុសិនារា ទ្រង់ប្រឈូនទៅតាមផ្លូវ នាំ
ព្រះសង្ឃទៅកាន់សាលវនោទ្យាន ព្រះអង្គរំលត់ខន្ធបរិនិព្វាន
ក្នុងចន្លោះដើមពាំងទាំងគូ នៃស្ដេចស្វាមល្លរាជ ក្នុងឆ្នាំម្សាញ់
បញ្ចស័ក ខែពិសាខ ថ្ងៃអង្គារ ទៀបព្រឹក ។ ព្រះសង្ឃនឹង
ស្ដេចមល្លរាជ ព្រមគ្នាធ្វើបុណ្យថ្វាយព្រះភ្លើង ស្រេចហើយ
អញ្ជើញព្រះធាតុចូលព្រះនគរ គ្រានោះ មានក្រសត្រិយ៍ទាំង ៧
លើកពលយោធាមកសុំព្រះធាតុ ក៏បែងព្រះធាតុជា ៨ ចំណែក
ចែកគ្នា ។ គ្រានោះ ព្រះមហាកស្សបប្រារព្ធរឿង សុភទ្ទភិក្ខុ តិះ
ដៀលព្រះពុទ្ធសាសនា ទើបប្រឹក្សាព្រះសង្ឃ នឹងលើកបឋមៈ
សង្គាយនា ព្រះសង្ឃទាំងឡាយ ក៏ព្រមចិត្តគ្នា ទើបជ្រើស
រើសព្រះអរហន្ត ៥០០ អង្គ ដែលដល់ព្រមដោយបដិសម្ភិទា
ញាណ នាំទៅលើកបឋមសង្គាយនាក្នុងនគររាជគ្រឹះ ។



R= 2000